ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង

Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 05-Dec-2012, 16:00
CMS/CFO: Uch Arun

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

**សាធារណៈ**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១២**

**ម៉ោង ០៩: ០៦នាទី**

**សវនាការលើកទី១៣៤**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម ធូ មណី

ចៅក្រម យូរ ឧត្តរា

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ហ្វីលីព រ៉ូជឺ *(Mr. Roger Phillips)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង

លោក វីល្លៀម ស្មីត *(Mr. William SMITH)*

កញ្ញា សុង ឆវ័ន្ត

លោក ឌេល លីសាក់ *(Mr. Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី *(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវាស *(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក ពេជ អង្គ

លោក សំ សុគង់

លោក វ៉េន ពៅ៖

លោកស្រី ជេត វណ្ណលី

លោកស្រី ស៊ីន សុវ៉ន

លោក ហុង គឹមសួន

លោក ឡោ ជុនធី

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

លោកស្រី សួ សុទ្ធាវី

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក ម៉ៃខល កាណាវាស | អង់គ្លេស |
| លោក អេនឌ្រូ អ៊ីនូហ្ស៊ី | អង់គ្លេស |
| លោក ហ្សាស្ពើ ប៉ៅ | អង់គ្លេស |
| លោក គង់ សំអុន | ខ្មែរ |
| លោក សំ សុគង់ | ខ្មែរ |
| លោក វីល្លៀម ស្មីត | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក ពេជ អង្គ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោកស្រី ទឹង សុខា (TCCP-188) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅដើមបណ្តឹងរដ្ឋប្បវេណី៖ លោកស្រី ទឹង សុខា** (TCCP-188)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ....................................................................ទំព័រ ២៦

សួរដោយលោក សំ សុគង់ ផ្តើមពី ....................................................................ទំព័រ ២៨

សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ផ្តើមពី ..............................................ទំព័រ ៤៣

សួរដោយលោក ឌេល លីសាក់ ផ្តើមពី ....................................................................ទំព័រ ៦៦

សួរដោយលោក ហ្សាស្តេ ប៉ោ ផ្តើមពី ....................................................................ទំព័រ ៧២

# កិច្ចដំណើរការនីតិវិធី

[០៩:០៦:៥៣]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ តាមកាលវិភាគដែលបានគ្រោងទុកសវនាការនៅថ្ងៃនេះអង្គជំនុំជម្រះកំណត់ស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-188។

លោក ឌុច ផារី ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមាន ភាគីនិងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ!

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន! គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះមានវត្តមាន លើកលែងតែជនជាប់ចោទអៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួន នៅខាងក្រោមបន្ទប់សវនាការ ដោយមូលហេតុសុខភាព។ ដើមបណ្តឹងរដ្ឋប្បវេណីដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងសវនាការថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-188។ ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ រីឯដើមបណ្តឹងរដ្ឋប្បវេណីបម្រុងសម្រាប់សវនាការថ្ងៃនេះ គឺដើមបណ្តឹងរដ្ឋប្បវេណី ដែលមានរហស្សនាម TCCP-108។ សូមអរគុណលោកប្រធាន។

[០៩:០៨:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។

នៅថ្ងៃនេះ តាមសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១២ បានសម្រេចថា អង្គជំនុំជម្រះអាចបង្គាប់ឲ្យជនជាប់ចោទចូលរួម -- អៀង សារី ចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធី ពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ អនុលោមតាមវិធាន៨១(៥) នៃវិធានផ្ទៃក្នុង នៅពេលដែលអង្គជំនុំជម្រះយល់ឃើញថា ការបង្គាប់បែបនេះ គឺជាផលប្រយោជន៍នៃយុត្តិធម៌ លើកលែងតែពេលដែលជនជាប់ចោទជ្រើសរើសការបង្ហាញវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ហើយនៅក្នុងអំឡុងពេលកាលពីម្សិលមិញនេះ គឺក្រុមមេធាវីការពារក្តី តាមរយៈមេធាវីការពារក្តី លោក

អៀងសារី បានដាក់ពាក្យដកហូតនូវលិខិតលះបង់សិទ្ធិរបស់គាត់ក្នុងការមានវត្តមាននៅក្នុងបន្ទប់សវនាការ ហើយគាត់មានបំណងចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងបន្ទប់ដោយផ្ទាល់ ជាពិសេសនៅក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សីនិងដើមបណ្តឹងរដ្ឋប្បវេណី លើកលែងតែ ខ្លួនគាត់ហ្នឹងជ្រើសរើសដើម្បីចូលរួមកិច្ចដំណើរការសវនាការដោយប្រយោលពីបន្ទប់ឃុំខ្លួនខាងក្រោម។

[០៩:១០:៣៧]

ប៉ុន្តែនៅព្រឹកមិញនេះ គឺមុនពេលដំណើរការសវនាការលោកវេជ្ជបណ្ឌិត ឈា គន្ធារី ដែលជាគ្រូពេទ្យប្រចាំការទទួលពិនិត្យថែទាំសុខភាពជនជាប់ចោទនៅមន្ទីរឃុំឃាំង អ.វ.ត.ក បានពិនិត្យ និងកត់សម្គាល់ឃើញនូវសុខភាពរបស់លោក អៀង សារី មិនល្អ ដូចជាមានការហត់ខ្លាំងនៅពេលធ្វើចលនាបន្តិចបន្តួច ចុកទ្រូង សម្រាន្តមិនលក់ ហូបមិនបាន ហើយក្អួត។ ហើយគាត់បានផ្តល់អនុសាសន៍ថាគាត់មិនអាចស្តាប់នៅក្នុងបន្ទប់សវនាការខាងលើបានឡើយ ហើយសូមឲ្យប្រធានអង្គជំនុំជម្រះអនុញ្ញាតឲ្យគាត់ស្តាប់សវនាការនៅបន្ទប់រង់ចាំខាងក្រោម ងាយស្រួលពេទ្យតាមដាន។ ដោយមូលហេតុនេះ អង្គជំនុំជម្រះសម្រេចថាដោយសារមានបញ្ហាសំណើសុំពិតមែន ប៉ុន្តែនៅពេលដែលអនុវត្តសិទ្ធិនេះវាមិនស៊ីសង្វាក់គ្នាទៅនឹងវិធាន និងការចាំបាច់ ដើម្បីធានាអំពីសុខមាលភាពផ្នែករូបរាងកាយរបស់ជនជាប់ចោទ ឬដើម្បីធានានូវការប្រព្រឹត្តទៅដោយរលូននៃកិច្ចដំណើរការជំនុំជម្រះ អង្គជំនុំជម្រះគឺសម្រេចថា បង្គាប់ឲ្យជនជាប់ចោទនោះចូលរួមកិច្ចដំណើរការនីតិវិធី ក្នុងដំណើរការសវនាការថ្ងៃនេះពីបន្ទប់ឃុំខ្លួនខាងក្រោមតាមរយៈឧបករណ៍សោតទស្សន៍។

សូមអញ្ជើញ!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម សូមជម្រាបសួរប្រិយមិត្តទាំងអស់គ្នា។ ជាដំបូង ខ្ញុំគិតថាមានការបកប្រែខុស ដូច្នេះខ្ញុំគិតថាការបកប្រែជាភាសាអង់គ្លេសមានបញ្ហា។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ទៅលើគោលជំហររបស់យើង កាលពីម្សិលមិញលោក អៀង សារី បានដាក់នូវឯកសារដកនូវការលះបង់សិទ្ធិរបស់គាត់ ហើយគាត់ទទូចថាគាត់មានវត្តមាននៅក្នុងសវនាការតែម្តង។ គឺគាត់មិនចង់ចូលរួមដោយប្រយោលនៅក្នុងបន្ទប់ខាងក្រោមនោះទេ។

[០៩:១២:៥៩]

ដូច្នេះ ខ្ញុំគិតថាប្រហែលជាមានការបកប្រែខុស ហើយខ្ញុំចង់ឲ្យមានបញ្ជាក់ច្បាស់ទៅលើជំហរ

របស់យើង។ ហើយជាមួយនឹងការដកនូវការលះបង់សិទ្ធិនេះ យើងក៏បានដាក់នូវឯកសារមួយដែលយើងបញ្ជាក់ថា -- ទៅលើបញ្ហានេះថា "ថ្ងៃនេះយើងបានជួបជាមួយលោក អៀង សារី ហើយបាននិយាយជាមួយវេជ្ជបណ្ឌិត ហើយយើងសួរ សុំឱ្យលោកវេជ្ជបណ្ឌិតមកផ្តល់នូវភស្តុតាង"។ ហើយលោកវេជ្ជបណ្ឌិតគាត់នឹងបញ្ជាក់ថា តើលោក អៀង សារី អាចមានលទ្ធភាពតាមដានសវនាការពេញ ១ថ្ងៃ ឬមួយក៏អត់។ ដូចដែលបានបញ្ជាក់ដោយលោកវេជ្ជបណ្ឌិត លោកបណ្ឌិត ខាំប៊ែល ដែលបានបញ្ជាក់កាលពីពេលលើកមុន។ ខ្ញុំទុកឱ្យមានការបកប្រែ ដោយមានការបកស្រាយ ថាតើវាមានអ្វី?

[០៩:១៣:៤៦]

តាមវិធាន៨១(៥) បានចែងថា "ដោយសារតែហេតុផលសុខភាព ឬក៏ការព្រួយបារម្ភដទៃទៀត នៅពេលដែលជនជាប់ចោទមិនអាចចូលរួមដោយផ្ទាល់នៅក្នុងសវនាការ ប៉ុន្តែគាត់មានសម្បទាគ្រប់គ្រាន់ទាំងផ្លូវកាយ និងផ្លូវចិត្ត អាចចូលរួម"។ នេះគឺជាចំណុចដែលមានបញ្ហា ដែលយើងចង់លើកឡើងយកមកជជែក នេះគឺជាបញ្ហាមួយ។ នៅពេលដែលយើងនិយាយថា មានសម្បទាទាំងផ្លូវកាយ និងផ្លូវចិត្ត។ ប៉ុន្តែយើងចង់បញ្ជាក់ថា គាត់មិនមានសម្បទាគ្រប់គ្រាន់ ដើម្បីចូលរួមតាមផ្នែកផ្លូវចិត្តនោះឡើយ។ ប្រសិនបើអង្គជំនុំជម្រះទាមទារថាឱ្យគាត់អង្គុយនៅខាងក្រោម នៅបន្ទប់ខាងក្រោមដើម្បីចូលរួមនោះគឺថា យើងសូមឱ្យមានការរៀបចំការតាមដានជាអេក្រង់ ដើម្បីបញ្ជាក់ច្បាស់ដើម្បីឱ្យសាធារណជនបានមើលឃើញថា គាត់មានស្ថានភាពខុសភាពបែបណា។ គឺថានៅពេលដែលកូនក្តីរបស់យើងនៅបន្ទប់ឃុំខ្លួនខាងក្រោម ប្រសិនបើគាត់គេងលក់ ឬក៏គាត់មិនបានតាមដានដឹង ឬក៏គាត់មានយ៉ាងម៉េច គឺយើងចង់ឱ្យមានការបញ្ជាក់ច្បាស់ដើម្បីឱ្យគាត់អាចការពារខ្លួនក្តី ដោយខ្លួនគាត់ផ្ទាល់។ ដូច្នេះហើយ គឺយើងមិនចង់ឱ្យមានការធ្វើនៅក្នុងរបៀបបែបនេះទេ។

[០៩:១៥:០៨]

ជម្រើសមួយទៀត គឺយើងនាំគាត់ចូលមកបន្ទប់សវនាការតែម្តង។ នេះគឺជាអ្វីដែលលោក អៀង សារី ចង់បាន។ ខ្ញុំអាចយល់ថា អង្គជំនុំជម្រះមិនចង់ឱ្យសាធារណជនគាត់មើលឃើញលោក អៀង សារី ឬក៏ឱ្យមានការបង្ហាញលោក អៀង សារី នៅក្នុងស្ថានភាពបែបនេះទេ។ យើងមានជម្រើសមួយទៀត គឺឱ្យមានសមាជិកមេធាវីការពារក្តីមួយរូបនៅខាងក្រោមជាមួយគាត់ ដើម្បីធ្វើការថតវីដេអូទៅលើគាត់ផ្ទាល់។ យើងមានជម្រើសច្រើន នៅពេលនោះ គឺក្រុមការពារក្តី និងធ្វើការថតវីដេអូ។ នេះគឺជាអ្វីដែលយើងចង់បាន ហើយយើងបានស្នើសុំ។ យើងបានស្នើទៅអង្គជំនុំជម្រះសាលាដំបូង ដើម្បីឱ្យ

ចេញនូវដីកាបង្គាប់មួយទៅដល់មន្ទីរឃុំឃាំង ដើម្បីឲ្យយើងអាចតាមដានថាតើគាត់មានលក្ខណៈបែបណា? ប៉ុន្តែនៅពេលដែលជួបហ្នឹង គឺមានការប្រជុំសម្ងាត់មុនមួយ ជាមួយខាងមេធាវីការពារក្តី ប៉ុន្តែមានខាងព្រះរាជអាជ្ញាចូលរួមផងដែរ។

[០៩:១៦:១៣]

គឺថា យើងនៅពេលដែលមានការប្រជុំជាមួយនឹងខាងរដ្ឋបាល ជាមួយនឹងខាងព្រះរាជអាជ្ញា និងខាងភាគីនានា គឺខាងមេធាវីការពារក្តីមិនត្រូវបានអនុញ្ញាតឲ្យចូលរួម ហើយក៏មិនបានអនុញ្ញាតឲ្យធ្វើការថតសំឡេង ឬក៏ថតនូវវីដេអូនៃអ្វីដែលគាត់បានឃើញ បានធ្វើ បានដឹងនោះឡើយ។ ដូច្នេះហើយនេះគឺជាអ្វីដែលយើងស្នើ។ យើងគិតថា នៅពេលដែលខ្ញុំប្រើពាក្យ "ការប្រជុំសម្ងាត់"នេះ គឺព្រោះដោយសារតែការប្រជុំហ្នឹងមិនមានមេធាវីការពារក្តីបានចូលរួមនោះឡើយ។ ដូច្នេះ ខ្ញុំគិតថាមុនពេលដែលយើងបន្តទៅមុខទៀត យើងគួរស្តាប់វេជ្ជបណ្ឌិត ហើយខ្ញុំនឹងមានចេតនាចោទសួរវេជ្ជបណ្ឌិត ដើម្បីធ្វើការកត់ត្រាចូលប្រតិចារឹក។ យើងចង់ឲ្យមានការកត់ត្រាប្រតិចារឹក។ យើងយល់អំពីទ្វេគ្រោះ ឬក៏ការប្រឈមដែលអង្គជំនុំជម្រះសាលាដំបូងបានជួបប្រទះ។ យើងដឹងថា លោក អៀង សារី នៅមានជីវិតនៅឡើយ។ ប៉ុន្តែតួនាទីរបស់ខ្ញុំជាមេធាវីការពារក្តី គឺខ្ញុំចង់ឲ្យមានការជំនុំជម្រះប្រកបដោយយុត្តិធម៌។ ប៉ុន្តែខ្ញុំមិនអាចធ្វើទៅបានទេ ប្រសិនបើយើងទុកឲ្យលោក អៀង សារី នៅខាងក្រោមដែលឲ្យគាត់គេងលក់ ឬក៏គាត់មិនអាចតាមដាន ឬក៏គាត់មិនអាចផ្តល់អារម្មណ៍បាន។ នេះ គឺជាបញ្ហាមួយ។

[០៩:១៧:៣៣]

ដូច្នេះ សំណើរបស់ខ្ញុំគឺសូមឲ្យអញ្ជើញ ឲ្យកោះហៅវេជ្ជបណ្ឌិតមក ហើយយើងនឹងពិភាក្សាបញ្ហាហ្នឹង ជាមួយលោក អៀង សារី ហើយយើង -- ប្រសិនបើមានការចាំបាច់យើងនឹងដើរចេញពីអង្គជំនុំជម្រះនេះតែម្តង។ ដើម្បីឲ្យយើងអាចដោះស្រាយទៅលើបញ្ហានេះបានដោយយុត្តិធម៌។ លុះត្រាតែសិទ្ធិរបស់ខាងការពារក្តីត្រូវបានការពារឲ្យបានគ្រប់គ្រាន់ និងយុត្តិធម៌ យើងនឹងបន្តកិច្ចដំណើរការនីតិវិធីនេះ ជាមួយអង្គជំនុំជម្រះសាលាដំបូងបន្តទៅមុខទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាមុន ព្រោះដើម្បីមានការពាក់ព័ន្ធជាមួយនឹងអ្វីដែលលើកឡើងដោយក្រុមមេធាវីការពារក្តីលោក អៀង សារី។ សូមអញ្ជើញ!

[០៩:១៨:២០]

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

លោកប្រធាន--

**ប្រធានអង្គជំនុំ៖**

យើងអនុញ្ញាតឲ្យលោកតំណាងសហព្រះរាជអាជ្ញាធ្វើមុន ដើម្បីឲ្យចប់បញ្ហាមួយពាក់ព័ន្ធជាមួយនឹងការលើកឡើងរបស់មេធាវីការពារ--

អង្គុយចុះទៅបានហើយ!

**លោក អេនគ្រូ អ៊ីនូហ្ស៊ី៖**

*(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**ប្រធានអង្គជំនុំ៖**

យើងនឹងទុកឱកាសជូនលោក ដោះស្រាយបញ្ហាមុនដំណើរការសួរដេញដោលដើមបណ្ដឹងរដ្ឋប្បវេណី ដោយបញ្ហាផ្សេងគ្នា។ យើងបានឃើញលោកងើបតាំងពីដំបូងមកម្ល៉េះ ប៉ុន្តែដោយសារបញ្ហាយើងបានលើកចាត់ចែងចំពោះលោក អៀង សារី ជាមុន។ មេធាវីលោក អៀង សារី គាត់បានងើបឡើង។ ឥឡូវនេះ គាត់បានចប់ហើយ នៅមានមតិយោបល់របស់ភាគីម្ខាងទៀត ធ្វើការសង្កេត ឬកត់សម្គាល់លើមតិយោបល់ដែលលើកឡើងដោយមេធាវី អៀង សារី។ ឲ្យចប់បញ្ហានីមួយៗ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[០៩:១៩:៤៣]

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរដល់អស់លោក លោកស្រី មេធាវីទាំងអស់។ ជាដំបូងពាក់ព័ន្ធទៅនឹងសំណើរបស់មេធាវីការពារក្ដី ដែលទាក់ទងទៅនឹងការនាំជនជាប់ចោទមកអង្គសវនាការនេះ ដូចដែលលោកចៅក្រមបានកត់សម្គាល់ឃើញច្បាស់ហើយនៅក្នុងសេចក្ដីសម្រេចថ្ងៃ២៦ ខែធ្នូ (ស៊ីក) គឺថាខាងលោកវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ច្បាស់ថា ថ្ងៃទី២៦ ខែវិច្ឆិកា លោកវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ថា "ការរក្សាទុកគាត់នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម គឺសមស្រប ដោយសារមានគ្រែ។ វាមិនមែន មានត្រឹមតែកៅអីដូចនៅខាងលើនេះទេ។ ហើយគាត់អាចចូលបន្ទប់ទឹកដោយងាយស្រួល ហើយការថែរក្សាចំពោះជនជាប់ចោទ គឺវាប្រសើរជាងនៅខាងលើ។ ដោយសារតែមានវត្តមានរបស់វេជ្ជបណ្ឌិតនៅជាប់ជាមួយលោក អៀង សារី"។ ខ្ញុំគិតថា នេះមិនមែនជាសំណើរបស់មេធាវី

ការពារក្តីទេ ដែលស្នើសុំឲ្យនាំលោក អៀង សារី មកបន្ទប់សវនាការនេះ។ ប្រសិនបើស្ថានភាពរក្សាទុកគាត់នៅខាងក្រោម វាប្រសើរជាង។ ដូច្នេះ ខ្ញុំគិតថា ការនាំគាត់មកបន្ទប់សវនាការ វាធ្វើឲ្យស្ថានភាពរបស់គាត់វាកាន់តែលំបាកទៅវិញទេ។ ព្រោះយើងផ្អែកទៅលើអនុសាសន៍របស់លោកវេជ្ជបណ្ឌិត ខាំប៊ែល គឺបានថាគួរតែដាក់នៅខាងក្រោម ជាទីកន្លែងល្អរបស់គាត់។ ដូច្នេះ វាមិនមែនជាការត្រឹមត្រូវនោះឡើយ ប្រសិនបើយើងនាំគាត់មកខាងលើ។

[០៩:២១:២០]

បញ្ហាមូលដ្ឋានដែលមេធាវីការពារក្តីបានលើកឡើង គឺ វាត្រឹមត្រូវក្នុងលក្ខណៈមួយ ដែលថា លោក អៀង សារី អាចនឹងមិនមានលទ្ធភាពការតាមដានដោយប្រសិទ្ធភាពខ្លាំងក្លានោះ។ ប៉ុន្តែបញ្ហាថាតើគាត់តាមដាននៅក្នុងបន្ទប់សវនាការ ឬក៏នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម? វាគឺជាបញ្ហាមួយ។ ដូច្នេះ វាជាបញ្ហាសំខាន់ ថាតើគាត់អាចតាមដានតាមមធ្យោបាយសោតទស្សន៍ ឬក៏អត់ ផ្អែកតាមវិធាន៨១(៥)។ នេះគឺជាបញ្ហាសំខាន់។

លោកប្រធានបានស្តាប់ឮអំពីមតិរបស់អ្នកជំនាញទាក់ទងទៅនឹងបញ្ហានេះរួចអស់ទៅហើយ ហើយផ្អែកទៅតាមសេចក្តីសម្រេច ដោយផ្អែកទៅលើអ្នកជំនាញចំនួនបីរូប ដែលបានធ្វើការពិនិត្យទៅលោក អៀង សារី គឺថាអ្នកជំនាញទាំងបីរូប គឺលោក អៀង សារី មានសម្បទាគ្រប់គ្រាន់ទាំងផ្លូវកាយ និងផ្លូវចិត្ត អាចចូលរួមនៅក្នុងការជំនុំជម្រះនេះ ទាំងការចូលរួមនៅក្នុងបន្ទប់សវនាការផ្ទាល់ ឬក៏បន្ទប់ឃុំខ្លួនខាងក្រោម។ ហើយពួកគាត់បានផ្តល់អនុសាសន៍ថា "ជាការប្រសើរ ដើម្បីរក្សាគាត់ទុកនៅបន្ទប់ឃុំខ្លួនខាងក្រោម"។ វាជាការពិត ដែលថាមនុស្សដែលមានវ័យបែបនេះ គួរតែត្រូវទទួលបាននូវការថែរក្សាបន្ថែមទៀត ប៉ុន្តែអ្វីដែលច្បាស់ចំពោះយើង គឺថាសេចក្តីសម្រេចរបស់អង្គជំនុំជម្រះបានធ្វើ ដោយផ្អែកទៅលើមូលដ្ឋាន ដែលថាគាត់អាចចូលរួមដោយពេញលេញ និងប្រកបដោយអត្ថន័យនៅក្នុងការជំនុំជម្រះ។

[០៩:២២:៥៨]

អ្វីដែលកើតឡើងជាញឹកញាប់នៅទីនេះ គឺទាក់ទងទៅនឹងបញ្ហាមេធាវីការពារក្តី ហើយនៅក្នុងការសំណើរបស់គេ គឺមានបញ្ហាមួយផ្សេងទៀត។ ហើយយើងមានភស្តុតាងដែលយើងស្តាប់ឮ គឺវាមានបញ្ហា គឺនៅម្ខាង ចំណែកអ្វីដែលមេធាវីការពារក្តីលើកឡើង វាផ្ទុយទៅវិញ គឺវានៅម្ខាងទៀត។ ដូច្នេះ គឺគួរតែផ្អែកទៅលើភស្តុតាងដែលយើងបានស្តាប់ឮនៅក្នុងសវនាការ។ ហើយយើងគួរតែចេញសេចក្តី

សម្រេចផ្អែកទៅលើភស្តុតាងដែលបានស្តាប់ មិនមែនធ្វើសេចក្តីសម្រេចផ្អែកទៅលើសំណើរបស់ភាគីនោះទេ។ នៅពេលដែលយើងមើលទៅលើសំណើ ដែលភាគីទាំងអស់បានទទួលកាលពីម្សិលមិញ ខ្ញុំសំណើសុំទៅអង្គជំនុំជម្រះពិចារណាទៅលើសេចក្តីសម្រេច។ ខ្ញុំសូមដកស្រង់កថាខណ្ឌ៣២ ដែលមេធាវីការពារក្តី អៀង សារី បានបញ្ជាក់ថា "មិនដែលមានការចោទប្រកាន់ណាមួយដែលថា លោក អៀង សារី គាត់មានបញ្ហាវិបល្លាសស្មារតីនោះឡើយ"។ គឺថាគឺមានការបញ្ជាក់ថា គាត់អាចតាមដានកិច្ចដំណើរការនីតិវិធីតាមផ្លូវសតិបញ្ញាបាន។

[០៩:២៤:០៩]

នៅក្នុងកថាខណ្ឌណាមួយទៀត ដែលបញ្ជាក់ថា ដែលបានបញ្ជាក់ថា "លោក អៀង សារី មិនអាចចូល មានលក្ខណៈ -- គាត់មិនអាចចូលរួមដោយសកម្ម ប៉ុន្តែគាត់អាចចូលរួមបាន"។ ដូច្នេះអានេះ គឺជាអ្វីដែលមេធាវីការពារក្តី អៀង សារី បានលើកឡើងទាក់ទងទៅនឹងការវាយតម្លៃរបស់វេជ្ជបណ្ឌិត។ ប្រសិនបើលោក អៀង សារី គាត់គេងស្ងៀមនៅមួយកន្លែង មិនអាចប្រែខ្លួន ឬក៏មិនអាចធ្វើអីបាន គឺថាខ្ញុំគិតថា ស្ថានភាពដែលល្អបំផុត គួរតែទុកនៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម ហើយឲ្យគាត់បន្តតាមដាន១ម៉ោងកន្លះ ហើយបន្ទាប់មកយើងសម្រាក ហើយបន្ទាប់មកយើងបន្តសវនាការតទៅទៀត។ នេះគឺជាអ្វីដែលលោកវេជ្ជបណ្ឌិត ខាំប៊ែល បាននិយាយ។ គឺថានៅពេលដែលគាត់សម្ភាសលោក អៀង សារី នៅក្នុងខែវិច្ឆិកា រយៈពេល១ម៉ោងកន្លះ គឺគាត់អាចធ្វើបាន។ ហើយនៅពេលដែលគាត់ត្រឡប់មកសម្ភាស មកជួបលោក អៀង សារី នៅពេលរសៀល គឺលោក អៀង សារី អាចបន្តការសន្ទនាបានបន្តទៅមុខ ដោយមិនមានបញ្ហា។

នេះគឺជាអ្វីដែលលោក ដែលៗមេធាវី អៀង សារី បានលើកឡើងកាលពីម្សិលមិញ ប្រសិនបើលោក អៀង សារី គាត់គេងស្ងៀមមួយកន្លែង គាត់នៅតែអាចបន្តតាមដានសវនាការ។ ដូច្នេះប្រសិនបើយើងយកមកគាត់មកលើបន្ទប់សវនាការទាំងនេះ គាត់មិនអាចគេងបាន ហើយវាជាបញ្ហាមួយលំបាក។ ដូច្នេះ យើងគួរតែគោរពទៅតាមអ្វីដែលវេជ្ជបណ្ឌិតបាននិយាយ ក៏ដូចជាលោកបណ្ឌិត ខាំប៊ែល បានបញ្ជាក់ផងដែរ។

[០៩:២៥:៣១]

មេធាវីការពារ អៀង សារី បាននិយាយជាមួយនឹងវេជ្ជបណ្ឌិត ប៉ុន្តែយើងមិនច្បាស់ថាតើការជួបនិយាយនោះ និយាយពីអ្វី ឬក៏វាមានន័យអ្វីនោះទេ។ ដូច្នេះ ខ្ញុំគិតថាអង្គជំនុំជម្រះគួរតែទទួលព័ត៌មានឲ្យ

បានលម្អិត ហើយសាកសួរវេជ្ជបណ្ឌិត ដើម្បីធ្វើការសន្និដ្ឋានថា លោក អៀង សារី អាចបន្តតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោម។ ខ្ញុំគិតថា នេះគឺជាបញ្ហាមូលដ្ឋានទាក់ទងនឹងវិធាន៨១(៥)។

ដូច្នេះ ខ្ញុំចង់ឲ្យមានការពិចារណាថាលោក អៀង សារី គាត់អាចតាមដានកិច្ចដំណើរការនីតិវិធីទាំងនៅក្នុងបន្ទប់សវនាការ ឬក៏នៅបន្ទប់ឃុំខ្លួនខាងក្រោម។ យើងក្នុងនាមជាព្រះរាជអាជ្ញា យើងនឹងព្យាយាមបំពេញទៅតាមអ្វីដែលអង្គជំនុំជម្រះបានបញ្ជាក់ ក៏ដូចជាអ្វីដែលលោកវេជ្ជបណ្ឌិតបានបញ្ជាក់ គឺយើងជឿជាក់ទៅលើវេជ្ជបណ្ឌិត ហើយយើងសូមសន្និដ្ឋានថា លោក អៀង សារី អាចមានលទ្ធភាពបន្តកិច្ចដំណើរការនីតិវិធីក្នុងថ្ងៃនេះបាន។ ហេតុដូច្នេះហើយ ការសវនាការនៅថ្ងៃនេះ គួរតែបន្តទៅមុខ។

[០៩:២៦:៤៧]

យើងសូមស្នើថា ផ្អែកទៅលើភស្តុតាងដែលយើងបានទទួលក្នុងរយៈពេលកន្លងមក ពេលវេជ្ជបណ្ឌិតនានា គឺថាសវនាការថ្ងៃនេះ គឺមានលទ្ធភាពបន្តទៅមុខដោយគ្មានបញ្ហា។

យើងទទួលស្គាល់ថា បញ្ហាសុខភាពលោក អៀង សារី គឺមានភាពទន់ខ្សោយមែន ប៉ុន្តែលោកវេជ្ជបណ្ឌិតបញ្ជាក់ថា មិនអីទេ។ ដូច្នេះយើងគួរតែមើលទៅតាមប្រចាំថ្ងៃ។ យើងមើលទៅតាមស្ថានភាពជារៀងរាល់ថ្ងៃ ១ថ្ងៃម្តងៗ។

ប្រសិន -- ដូច្នេះ ខ្ញុំគិតថា យើងគួរតែផ្អែកទៅលើព័ត៌មានប្រចាំថ្ងៃ ដើម្បីឲ្យយើងសម្រេចថា លោក អៀង សារី អាចមានលទ្ធភាពតាមដានកិច្ចដំណើរការនីតិវិធីជារៀងរាល់ថ្ងៃ គឺថាយើងវាយតម្លៃ ១ថ្ងៃម្តងៗ តាមករណីជាក់ស្តែង ដើម្បីធ្វើការសម្រេច។ ហើយអ្វីដែលខ្ញុំចង់បញ្ជាក់គឺថា ការចូលរួមនៅបន្ទប់ឃុំខ្លួនខាងក្រោមនោះ គឺវាមានលក្ខណៈដូចគ្នា ឬក៏ថាសឹងតែថាដូចគ្នានឹងការចូលរួមនៅក្នុងបន្ទប់សវនាការនេះផ្ទាល់តែម្តង។ ហេតុនេះក៏វាស្របទៅតាមបទដ្ឋានអន្តរជាតិក៏ដូចជាមានចែងនៅក្នុងវិធាន ៨១(៥) ផងដែរ។

[០៩:២៧:៥៤]

ខ្ញុំគិតថា លោកវេជ្ជបណ្ឌិត គាត់បានផ្តល់នូវអនុសាសន៍គ្រប់គ្រាន់រួចទៅហើយទាក់ទងទៅនឹងលទ្ធភាពរបស់ អៀង សារី ក្នុងការតាមដានសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោម។ ដូច្នេះយើងអាចបន្តសវនាការទៅមុខទៀតបាន។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អរគុណ! សូមអញ្ជើញ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំមានការកត់សម្គាល់ខ្លីទេ ដោយបន្ថែមទៅលើអ្វីដែលបានលើកឡើងដោយសហព្រះរាជអាជ្ញា។

ការកត់សម្គាល់ដំបូងរបស់ខ្ញុំហ្នឹង គឺពាក់ព័ន្ធទៅនឹងការកែប្រែជំហររបស់ អៀង សារី កាលពីម្សិលមិញ ពីព្រោះថាពីដំបូងនោះ អ៎! គឺគាត់ថាសម្រេចថាគាត់លែងលះបង់សិទ្ធិវត្តមានទៀតហើយ។ សាក្សីនៅដដែល ដើមបណ្តឹងរដ្ឋប្បវេណីក៏នៅតែដដែល ក៏ប៉ុន្តែ អៀង សារី គឺគាត់កែប្រែគោលជំហរ គឺគាត់ចង់មកមានវត្តមាននៅក្នុងសវនាការវិញ។ ដូច្នេះយើងអាចសួរអំពីមូលហេតុ ហេតុអ្វីបានជាគាត់កែប្រែគោលជំហររបស់គាត់នៅក្នុងការជំនុំជម្រះក្តីយើងនេះ?

[០៩:២៩:១១]

ការកត់សម្គាល់ទី២របស់ខ្ញុំនោះ ដូចដែលសហព្រះរាជអាជ្ញាបានលើកឡើងហើយថា ដើមបណ្តឹងរដ្ឋប្បវេណីក៏យល់ផងដែរ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា នោះ អង្គជំនុំជម្រះបានចេញនូវសេចក្តីសម្រេចដោយគិតទៅលើតុល្យភាពនៃសិទ្ធិរបស់ភាគីទាំងអស់ ហើយនិងគិតទៅលើសិទ្ធិរបស់ អៀង សារី។ អង្គជំនុំជម្រះបានគ្រោងនូវការរៀបចំពិសេស ហើយខ្ញុំគិតថាការសម្រេចនេះ គឺថាស្របទៅនឹងយុត្តិ-សាស្ត្រអន្តរជាតិពាក់ព័ន្ធទៅនឹងបញ្ហានេះ។

ដូច្នេះខ្ញុំគិតថាវាជារឿងធម្មតាទេ ដែលអង្គជំនុំជម្រះចេញសេចក្តីសម្រេចបែបនេះ បន្ទាប់ពីបានស្តាប់នូវយោបល់របស់អ្នកជំនាញដែលបានបង្ហាញ ដែលបានពន្យល់ប្រាប់អំពីស្ថានភាពនោះ។ ដូច្នេះច្បាស់ណាស់ អៀង សារី គាត់មានសម្បទា ហើយមិនដែលបានបញ្ជាក់ថាគាត់មិនមានសម្បទា ឬក៏មានខ្លះ អត់ខ្លះនោះទេ។ ដូច្នេះ ស្ថានភាពគឺថាបញ្ជាក់ច្បាស់ណាស់ ហើយអង្គជំនុំជម្រះក៏បានចេញសេចក្តី សម្រេចច្បាស់ហើយ យើងបានស្តាប់យោបល់របស់គ្រូពេទ្យរួចហើយ ដូច្នេះមិនចាំបាច់ហៅគ្រូពេទ្យមកសួរគាត់នោះទេ។ ដូច្នេះ យើងអាចបន្តសវនាការយើងទៀតបាន ដើម្បីផលប្រយោជន៍ដើមបណ្តឹងរដ្ឋប្បវេណីផងដែរ គឺថា យើងអាចធ្វើបាន ដូចដែលបានធ្វើកន្លងមកហើយ ហើយរហូតដល់បញ្ចប់។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក អៀង សារី!

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន សូមលើកយកចំណុចមួយចំនួនដែលខ្ញុំចង់លើកឡើង។ ជាដំបូងលោក ស្មឹត បានបញ្ជាក់ខុស ហើយនាំមានការនិយាយខុសទាក់ទងនឹងគោលជំហររបស់យើង។ យើងមិនដែលបញ្ជាក់បែបនេះទេ។ យើងមិនដែលបញ្ជាក់ថាលោក អៀង សារី មានបញ្ហាខាងសតិបញ្ញា ឬក៏ថាគាត់មានជំងឺវង្វេងវង្វាន់ស្មារតីនោះឡើយ។ អ្វីដែលយើងបានអះអាង គឺថាដោយសារតែស្ថានភាពជំងឺផ្លូវកាយរបស់គាត់ ទើបគាត់មិនអាចមានលទ្ធភាពតាមដានកិច្ចដំណើរការនីតិវិធី។ នេះគឺជាគោលជំហររបស់យើងវាបានបន្តតាំងពីដើមរហូតមកដល់ឥឡូវនេះ ហើយយើងមិនដឹងថាហេតុអ្វីបានជាព្រះរាជអាជ្ញាព្យាយាមធ្វើឲ្យអង្គជំនុំជម្រះយល់ខុសពីគោលជំហររបស់យើងនោះឡើយ។ គឺថាយើងនិយាយអំពីស្ថានភាពពីមួយថ្ងៃទៅមួយថ្ងៃ ហើយយើងសូមគាំទ្រ ខ្ញុំចង់និយាយបន្តទៀតថា អាចនឹងពិនិត្យមើលដល់កម្រិត១ម៉ោងម្តងៗទៀតឯណោះ។ ដូចដែលវេជ្ជបណ្ឌិត ខាំប៊ែល បានបញ្ជាក់ថា គឺរបាយការណ៍ហ្នឹងធ្វើឡើងតាំពីប៉ុន្មានខែមុនម្ល៉េះ ប៉ុន្តែអ្វីដែលគាត់មានស្ថានភាពនៅថ្ងៃនេះ គឺថាយើង មិនដឹងច្បាស់ឡើយ។

នៅពេលដែលយើងសួរវេជ្ជបណ្ឌិត គឺថា យើងអាចស្តាប់វេជ្ជបណ្ឌិតបានប្រសិនបើយើងចង់ដឹងនេះគឺជាអ្វីដែលសំខាន់ គួរតែយើងស្តាប់វេជ្ជបណ្ឌិតប្រចាំថ្ងៃ។ អ្វីដែលសំខាន់គឺថា យើងត្រូវធ្វើការតាមដាន ហើយមេធាវីការពារក្តីត្រូវធ្វើការតាមដាន ហើយមេធាវីការពារក្តីមានតួនាទីការពារផលប្រយោជន៍របស់កូនក្តី។ ខ្ញុំគិតថា នេះគឺជាតួនាទី និងជាការទទួលខុសត្រូវរបស់មេធាវីការពារក្តីដើម្បីការពារសិទ្ធិរបស់កូនក្តីរបស់យើង។ ថាតើយើងធ្វើការតាមដានកូនក្តីរបស់យើងដោយរបៀបណាក្នុងការតាមដានសវនាការពីមួយថ្ងៃទៅមួយថ្ងៃ ពីមួយពេលទៅមួយពេល ក្នុងការដានតាមកិច្ចដំណើរការនីតិវិធីនោះ។

[០៩:៣២:០០]

យើងមិនអាចនិយាយបានទេថា ប្រសិនបើគាត់នៅខាងក្រោម ហើយមានទូរទស្សន៍មានអីមើលហ្នឹង វាអាចបញ្ជាក់ថាគាត់អាចមានវត្តមាន ហើយអាចតាមដានកិច្ចដំណើរការនីតិវិធីនេះ នោះវាមិនគ្រប់គ្រាន់នោះទេ។ អាចថា ខ្ញុំ ខ្ញុំលើកឧទាហរណ៍មួយ ខ្ញុំអាចនឹងមើលទូរទស្សន៍ ប៉ុន្តែមិនមែនខ្ញុំបានន័យថា ខ្ញុំមើលទូរទស្សន៍ឃើញទេ ខ្ញុំគេងលក់ ខ្ញុំទុកឲ្យទូរទស្សន៍ចោលតែឯងនោះទៅ។ នេះគឺជាអ្វីដែលយើងចង់បញ្ជាក់ថា គឺថាដោយសារតែគាត់មានបញ្ហាសុខភាពផ្លូវកាយទើបធ្វើឲ្យគាត់មិនអាចបន្តការតាមដានកិច្ចដំណើរការនីតិវិធីបាន។

[០៩:៣៣:០២]

យើងបានជួបជាមួយគាត់ហើយ ហើយមានតែយើងហើយនិងគាត់នោះ វេជ្ជបណ្ឌិតទេ ដែលបានជួបជាមួយគាត់ដើម្បីពិភាក្សាអំពីស្ថានភាពគាត់ដោយផ្ទាល់។ ថាតើលោក អៀង សារី គាត់អាចមានការប្រសើរវិញ ឬក៏អត់នោះ យើងមិនច្បាស់នោះទេ។ ដូច្នេះ ការដែល -- រដ្ឋធម្មនុញ្ញបានចែងថា "យើងត្រូវរក្សាសិទ្ធិរបស់កូនក្តីរបស់យើង ហើយយើងត្រូវការពារសិទ្ធិកូនក្តីរបស់យើងក្នុងការការពារក្តីរបស់គាត់ ហើយយើងធានាថាយើងការពារគាត់ក្នុងរយៈពេល ២៤ម៉ោង ក្នុង១ថ្ងៃ និង ៧ថ្ងៃក្នុង១សប្តាហ៍ យើងត្រូវធ្វើការតាមដានស្ថានភាពជារៀងរាល់ថ្ងៃ"។ ប្រសិនបើយកគាត់មកបន្ទប់សវនាការ ប្រសិនបើយើងឃើញគាត់គេងលក់ អាហ្នឹងយើងដឹងច្បាស់ថា គាត់មិនបានតាមដានកិច្ចដំណើរការនីតិវិធី។ ដូច្នេះនៅពេលដែលមានស្ថានភាពបែបហ្នឹង គឺយើងអាចដាក់សំណើសុំដោយផ្អែកលើវិធាន ៨១(៥) តែម្តង។ នេះគឺជាអ្វីដែលយើងចង់បាន។

[០៩:៣៤:០៥]

ប្រសិនបើទាក់ទងទៅនឹងអ្វីដែលព្រះរាជអាជ្ញាបានលើកឡើង គាត់នៅអគារមួយផ្សេង ទោះបីថាគាត់ចូលរួម ឬមិនចូលរួមក៏ដោយ ហើយយើងព្យាយាមបញ្ចប់រឿងក្តីនេះ ហើយធ្វើឲ្យមានការចេញសាលក្រម សាលដីកា គឺជាការចាប់។ អានេះជាបញ្ហារបស់ខាងព្រះរាជអាជ្ញា ប៉ុន្តែយើងជាមេធាវីការពារក្តីចាំបាច់ត្រូវតែការពារសិទ្ធិរបស់គាត់។ យើងត្រូវតែឲ្យគាត់ចូលរួមដោយមានប្រសិទ្ធភាព ហើយដើម្បីឲ្យគេអាចឃើញ ដើម្បីឲ្យសាធារណជនអាចឃើញថាលោក អៀង សារី អាចចូលរួមដោយផ្ទាល់ គឺចង់ឲ្យមានការថតជាវីដេអូ ឬក៏មានការបង្ហាញជាវីដេអូដើម្បីឲ្យសាធារណជនបានឃើញ។ នេះគឺជាអ្វីដែលយើងស្នើសុំឲ្យធ្វើ។ ប្រសិនបើយើងមិនធ្វើបែបនេះទេ វាហាក់ដូចជាការជំនុំជម្រះដោយកំបាំងមុខ។ គ្រាន់តែចូលរួមដោយរូបរាងកាយមិនប្រាកដថាគ្រប់គ្រាន់នោះទេ។ ដូច្នេះ យើងស្នើសុំក្នុងចំណុចនេះ ឲ្យអញ្ជើញវេជ្ជបណ្ឌិតមកសាកសួរដោយផ្ទាល់តែម្តង។ ហើយខ្ញុំចង់បញ្ជាក់មួយសាទៀតថា មេ -- សហព្រះរាជអាជ្ញាគាត់បានបញ្ជាក់ដោយខុស គឺថា ថាវេជ្ជបណ្ឌិតគាត់មិនដែលធ្វើការបញ្ជាក់ ឬក៏ធ្វើជាអនុសាសន៍ណាមួយដែលថា កូនក្តីរបស់ខ្ញុំមានសម្បទាគ្រប់គ្រាន់ ក្នុងការចូលរួមសវនាការនោះឡើយ។ គាត់គ្រាន់តែបញ្ជាក់ថា កូនក្តីខ្ញុំមានសម្បទា -- អូ! មានៗសុខភាពល្អធម្មតានៅខាងក្រោម។ ប៉ុន្តែមិនមែនបានន័យថា សុខភាពមានសុខភាពហ្នឹង អាចថាគាត់អាចចូលរួមដោយសវនាការដោយផ្ទាល់នោះឡើយ។

វេជ្ជបណ្ឌិតគាត់មិនមានលទ្ធភាព ឬក៏ ប្រហែលជាគាត់មិនបានបញ្ជាក់ឲ្យបានច្បាស់ អំពីសម្បទាក្នុងការចូលរួមសវនាការក្នុងពេលនោះឡើយ។ ដូច្នេះ គឺយើងគួរតែឲ្យមានការបញ្ជាក់ច្បាស់ថាតើលោក អៀង សារី មានលទ្ធភាពចូលរួមសវនាការពេញមួយថ្ងៃ ឬក៏អត់។ សូមអរគុណលោកប្រធាន។

[០៩:៣៦:០០]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៧:៤០]

**ប្រធានអង្គជំនុំ៖**

ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដែលបានលើកដៃមានបំណងចង់លើកឡើងបញ្ហាអ្វី សូមអញ្ជើញ!

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។

ជាដំបូងខ្ញុំសូមបញ្ជាក់ថា អ្វីដែលខ្ញុំចង់និយាយគឺ--

[០៩:៣៨:០៤]

*(ចៅក្រមពិភាក្សាគ្នា)*

[០៩:៣៨:៣៧]

**ប្រធានអង្គជំនុំ៖**

ប្រសិនបើលោកមេធាវីមានបំណងលើកឡើងពាក់ព័ន្ធជាមួយនឹងបញ្ហាសុខភាពរបស់លោក អៀង សារី ក្នុងការចូលរួមសវនាការ នោះគឺលោកអាចលើកឡើងបាននៅក្នុងវិសាលភាពនៃអង្គច្បាប់ដែលពាក់ព័ន្ធទៅនឹងវិធាន៨១(៥) តែប៉ុណ្ណោះ។

**លោក អេនគ្រូ អ៊ីន្ទូហ្ស៊ី៖**

សូមអរគុណលោកប្រធាន។ ជាថ្មីម្តងទៀត ខ្ញុំសូមជម្រាបសួរអស់លោក លោកស្រីទាំងអស់។ ខ្ញុំមិនមានអ្វីចង់និយាយអំពីបញ្ហាលោកអៀង សារី នោះទេ។ ព្រោះថាលោក អៀង សារី មិនមែនជាកូនក្តីរបស់ខ្ញុំនោះឡើយ។ ខ្ញុំគ្រាន់តែចង់គាំទ្រទៅលើសំណើដែលធ្វើឡើងដោយមេធាវីការពារក្តីលោក កាណាវាស ទាក់ទងទៅនឹងបញ្ហាផ្លូវច្បាប់ នៃការចូលរួមដោយប្រសិទ្ធភាព ដោយសកម្ម។ ព្រោះថា

បញ្ហានេះវាពាក់ព័ន្ធទៅនឹងជនជាប់ចោទទាំងអស់។ ដូច្នេះ ខ្ញុំខ្លួនឯងផ្ទាល់ ខ្ញុំគិតថាអង្គជំនុំជម្រះមិនមានតួនាទីអ្វីនៅក្នុងការរក្សាវត្តមាន ឬក៏តម្រូវឲ្យមានការចូលរួមពីជនជាប់ចោទនោះឡើយ។ ដូចដែលលោកមេធាវីការពារក្ដី កាណាវាស បាននិយាយថា "បុគ្គលនីមួយៗមានសិទ្ធិទទួលបានការការពារ និងការការពារក្ដី"។ តើអង្គជំនុំជម្រះនឹងធ្វើការសម្រេចទៅលើបញ្ហានេះក្នុងពេលឥឡូវនេះ ឬមួយក៏យ៉ាងម៉េចដែរ? ព្រោះថាខ្ញុំមានមតិបន្ថែមដទៃផ្សេងទៀតទាក់ទងទៅនឹងបញ្ហាផ្សេងទៀត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណណាស់ យើងត្រូវដោះស្រាយបញ្ហានេះឲ្យបានដាច់ស្រេចជាមុនសិន មុននឹងបន្តទៅនឹងបញ្ហាផ្សេងទៀត។ ឥឡូវនេះដោយសារមានបញ្ហាចំពោះមុខដែលអង្គជំនុំជម្រះត្រូវពិភាក្សាសម្រេច ដូច្នេះអង្គជំនុំជម្រះសាលាដំបូងសម្រេចប្រកាសសម្រាករយៈពេល៣០នាទី ដើម្បីថយទៅពិចារណាសម្រេចទៅលើបញ្ហាដែលលើកឡើងដោយមេធាវីការពារក្ដីលោក អៀង សារី ចំពោះបញ្ហាសុខភាពរបស់លោក អៀង សារី នេះ។

សម្រាកចុះ! ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងដប់ ដប់នាទីសូមអញ្ជើញចូលវិញដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ០៩:៤១ នាទី ដល់ម៉ោង ១០:២៧ នាទី)*

[១០:២៧:១៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ។ ហើយអង្គជំនុំជម្រះក៏សូមប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីសម្រេចលើសំណើសុំរបស់មេធាវីការពារក្ដីលោក អៀង សារី ដែលបានស្នើសុំកាលពីព្រឹកមិញ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។ អង្គជំនុំជម្រះសាលាដំបូងបានពិភាក្សា និងសម្រេចដូចខាងក្រោមនេះ៖

ពាក់ព័ន្ធទៅនឹងសំណើសុំផ្សេងៗទាក់ទងទៅនឹងសម្បទារបស់លោក អៀង សារី ដើម្បីចូលរួមនៅក្នុងសវនាការដែលបានលើកឡើងដោយមេធាវីអន្តរជាតិរបស់គាត់នោះ គឺអង្គជំនុំជម្រះសាលាដំបូងបានលើកឡើងពាក់ព័ន្ធទៅនឹងសម្បទារបស់លោក អៀង សារី ដើម្បីចូលរួមនៅក្នុងសវនាការ។ សេចក្តីសម្រេចនេះផ្តោតទៅលើ សំអាងទៅលើសក្ខីកម្មរបស់អ្នកជំនាញ និងភស្តុតាងនានា ហើយផ្តល់ឱកាសឲ្យភាគីទាំងអស់ដាក់នូវសំណើសុំផ្សេងៗ។

[១០:២៩:០០]

នេះគឺជាចំណុចចាប់ផ្តើមនៃសេចក្តីសម្រេចនេះ ក៏ប៉ុន្តែអ្នកជំនាញបានបញ្ជាក់ថា លក្ខខណ្ឌស្ថានភាពរាងកាយរបស់លោក អៀង សារី អាចនឹងមានការប្រែប្រួលពីពេលមួយទៅពេលមួយ ហើយអង្គជំនុំជម្រះបានពិចារណាទៅលើចំណុចនេះ ហើយសម្រេចទៅលើស្ថានភាពសុខភាពរបស់គាត់ដូចនៅក្នុងកាលៈទេសៈ ដូចខាងក្រោម៖

ដោយយល់ឃើញថា វេជ្ជបណ្ឌិតព្យាបាលលោក អៀង សារី បានចេញនូវរបាយការណ៍វេជ្ជសាស្ត្រមួយជូនអង្គជំនុំជម្រះនៅព្រឹកនេះ ដោយផ្តោតទៅលើការពិនិត្យសុខភាពជនជាប់ចោទនៅថ្ងៃនេះ ហើយជាភាសាអង់គ្លេស សេចក្តីសង្ខេបនៃរបាយការណ៍គឺថា លោក អៀង សារី មិនអាចតាមដានដំណើរការនីតិវិធីនៅក្នុងបន្ទប់សវនាការបានទេ។ ហើយវេជ្ជបណ្ឌិតបានស្នើសុំថា អង្គជំនុំជម្រះត្រូវអនុញ្ញាតឲ្យលោក អៀង សារី ចូលទៅតាមដាននៅបន្ទប់ខាងក្រោម ដើម្បីអាចនឹងឲ្យវេជ្ជបណ្ឌិតត្រៀមខ្លួនរួចជាស្រេច តាមដានពិនិត្យសុខភាពរបស់លោក អៀង សារី។ ដោយពិចារណាទៅលើសំណើសុំដោយមេធាវីការពារក្តីអន្តរជាតិរបស់គាត់ លោក អៀង សារី បានលើកឡើងនូវចំណុចបឋមថា “វាជាការចាំបាច់ណាស់ ដែលសម្បទារបស់លោក អៀង សារី គឺអាចសំអាងតែទៅលើមតិយោបល់ផ្នែកពេទ្យ”។ ហើយអង្គជំនុំជម្រះបានសម្រេចថា យោងទៅតាមវិធាន៨១(៥) ការលំបាកដែលបណ្តាលឲ្យលោក អៀង សារី មិនអាចចូលមកក្នុងបន្ទប់សវនាការបាននោះ ឬក៏លំបាកដែលនឹងអនុញ្ញាតឲ្យគាត់ចូលមកបាននោះ គឺថាអាចនឹងធ្វើឲ្យសវនាការនេះ មានការពន្យារយ៉ាងវែង។ ហេតុដូច្នេះ អង្គជំនុំជម្រះបង្គាប់ឲ្យលោក អៀង សារី តាមដានដំណើរការនីតិវិធីពីបន្ទប់ឃុំឃាំងខាងក្រោម។ ហើយអង្គជំនុំជម្រះក៏ពិចារណាផងដែរថា ការគាំទ្រផ្នែកបច្ចេកទេសទាំងអស់ ដើម្បីគាំទ្រទៅដល់ការចូលរួមតាមដានដំណើរការនីតិវិធីនៅបន្ទប់ឃុំខ្លួនខាងក្រោម។ ក្នុងនោះមានការភ្ជាប់ខ្សែទូរស័ព្ទដើម្បីទាក់ទងជាមួយនឹងមេធាវីរបស់គាត់។

[១០:៣១:៤៨]

ហើយអង្គជំនុំជម្រះក៏បានគិតថា ការតាមដាននីតិវិធីពីបន្ទប់ខាងក្រោមដែលបានស្នើសុំដោយអ្នកជំនាញដោយសារហេតុផលនេះឯង ជាពិសេស គឺថាត្រូវតែបំពាក់ប្រព័ន្ធបច្ចេកទេស ដើម្បីឱ្យគាត់អាចតាមដានបាន ហើយសម្ភារៈដែលបានស្នើសុំដោយអ្នកជំនាញ ត្រូវតែបំពាក់ឱ្យបានសមស្រប ដើម្បីឱ្យលោក អៀង សារី តាមដាននៅក្នុងកាលៈទេសៈនេះ ឱ្យបានសមស្របជាងនៅក្នុងបន្ទប់សវនាការនេះទៅទៀត។

ទាក់ទងទៅនឹងកាតព្វកិច្ចដែលត្រូវតាមដានសុខភាពសម្បទារបស់លោក អៀង សារី ជាបន្តទៅទៀតនេះ អង្គជំនុំជម្រះសង្ឃឹមទៅលើគ្រូពេទ្យព្យាបាលដែលអាចនឹងជម្រាបមកអង្គជំនុំជម្រះនូវការកែប្រែណាមួយជាបន្ទាន់នៃស្ថានភាពសុខភាពរបស់លោក អៀង សារី។ ហើយអង្គជំនុំជម្រះក៏សូមបញ្ជាក់ផងដែរថា ការតាមដានផ្នែកសុខភាពនេះ គឺថាដោយសារមិនមានមេធាវី ឬក៏ចៅក្រម មិនបានតាមដានដោយផ្ទាល់ ឬក៏ដោយសារសាធារណជននោះទេ ត្រូវតែតាមដានដោយគ្រូពេទ្យ។ ដោយហេតុផលនេះឯង អង្គជំនុំជម្រះបដិសេធ ថាមិនឱ្យថតជាវីដេអូបញ្ជាំងចូលមកក្នុងបន្ទប់សវនាការ គឺយើងសង្ឃឹមទៅលើគ្រូពេទ្យព្យាបាល ដែលគាត់តាមដានស្ថានភាពសុខភាពរបស់លោក អៀង សារី និងយកចិត្តទុកដាក់ថែទាំសុខភាពរបស់គាត់។

[១០:៣៣:២៥]

សំណើសុំមួយទៀត ដែលបានស្នើសុំដោយមេធាវីអន្តរជាតិរបស់លោក អៀង សារី គឺថាត្រូវតែអញ្ជើញឱ្យគ្រូពេទ្យព្យាបាលមកឆ្លើយនៅចំពោះមុខអង្គជំនុំជម្រះ។ របាយការណ៍វេជ្ជសាស្ត្រ គឺច្បាស់ហើយសម្រាប់អង្គជំនុំជម្រះ និងឱ្យអង្គជំនុំជម្រះសម្រេចបានដោយមិនចាំបាច់អញ្ជើញគ្រូពេទ្យព្យាបាលគាត់ ដើម្បីឱ្យគាត់មកបកស្រាយទៅលើរបាយការណ៍របស់គាត់ក្នុងមធ្យោបាយណាមួយនោះទេ។

លោកប្រធាន ខ្ញុំគិតឃើញថា នេះគឺសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះច្បាស់ហើយ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល កាណាវ៉ាស៖**

សូមអរគុណលោកប្រធាន លោក លោកស្រីចៅក្រម។ ខ្ញុំសូមឱ្យបញ្ជាក់ចំណុចមួយ មុននឹង

ឈានទៅដល់ការធ្វើសេចក្តីសម្រេចនោះ។ តាមដែលយើងខ្ញុំយល់ គឺអង្គជំនុំជម្រះមិនចង់ឲ្យមានការធ្វើការតាមដានដោយអ្នកណាម្នាក់ក្រៅពីគ្រូពេទ្យព្យាបាលនោះទេ។

[១០:៣៤:៣៧]

ឧបមាថា លោក អៀង សារី គាត់សម្រាន្តលក់ ហើយគ្រូពេទ្យគ្រាន់តែតាមដាន ប៉ុន្តែយើងមិនមានប្រតិចារឹកអីនោះទេ។ នេះគឺជាសេចក្តីព្រួយបារម្ភរបស់មេធាវីការពារក្តី។ ដូច្នេះ យើងខ្ញុំសូមស្នើសុំឲ្យអង្គជំនុំជម្រះសម្រេចភ្លាមៗ ដើម្បីជៀសវាងនូវស្ថានភាពណាមួយ គឺថាយើងខ្ញុំចង់ឲ្យមានការកត់ត្រា មានប្រតិចារឹក ថាហេតុអ្វីបានជាលោក អៀង សារី ត្រូវតែបំបែកចេញពីដំណើរការនីតិវិធីនេះ? ឬក៏ហេតុអ្វីបានជាថា បញ្ហាលោក អៀង សារី នេះគឺថាធ្វើឲ្យពន្យារទៅដល់សវនាការនោះ?

តើខ្ញុំយល់ត្រឹមត្រូវដែរឬទេ ដែលថាអង្គជំនុំជម្រះ គឺដែលរារាំងមិនឲ្យមានការថតជាវីដេអូនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម នៅពេលដែលនីតិវិធីកំពុងតែដំណើរការនោះ។ គឺថាយើងខ្ញុំមិនចង់ឲ្យគ្រូពេទ្យ គ្រាន់តែសរសេររបាយការណ៍របស់គាត់នោះទេ យើងខ្ញុំចង់ឲ្យថតជាវីដេអូ និងបញ្ចាំងមក ក្នុងបន្ទប់សវនាការនេះតែម្តង។ នេះគឺជាអ្វីដែលយើងខ្ញុំស្នើសុំដើម្បីឲ្យសាធារណជនអាចមើលឃើញដោយផ្ទាល់ផង។

[១០:៣៥:៤៦]

យើងខ្ញុំមិនចង់គ្រាន់តែប្រើប្រាស់ឧបករណ៍ដែលបំពាក់ទេ គឺថាគាត់មិនអាចលូក ទៅលើកទូរស័ព្ទមកនិយាយបាន។ ដូច្នេះចំណុចនេះគឺថាមិនមានអ្វីជាការប្រសើរនោះទេ។ ដូច្នេះយើងខ្ញុំមានសំណើដ៏សាមញ្ញមួយ តើយើងខ្ញុំអាចអនុញ្ញាតឲ្យមានតំណាងពីក្រុមមេធាវីការពាររបស់លោក អៀង សារី ណាមួយទៅថតវីដេអូគាត់នៅពេលដំណើរការនីតិវិធីកំពុងបន្ត? ដូច្នេះ យើងនឹងមានប្រតិចារឹកពាក់ព័ន្ធទៅនឹងស្ថានភាពរបស់គាត់។ បើបដិសេធ បើសិនជាបដិសេធ គឺថា ប៉ុន្តែបើថាមិនធ្វើដូច្នេះបាន ខ្ញុំមិនអាចនឹងចូលរួមក្នុងដំណើរការនីតិវិធីនេះបានទេ បើសិនណាជាប្រតិចារឹកទាំងមូល គឺថាមិនអាចៗ នឹងមានប្រតិចារឹកទាំងមូលនោះបានទេ។ គឺត្រូវតែតាមដានស្ថានភាពសុខភាពរបស់គាត់។ ទាំងស្ថានភាពសុខភាព ទាំងថាតើគាត់តាមដាននីតិវិធីដំណើរការនីតិវិធីបានដែរ ឬក៏អត់?

[១០:៣៦:៤៣]

ខ្ញុំយល់ឃើញថាសំណើសុំនេះ ជាសំណើសុំមួយប្រកបទៅដោយសេចក្តីស្មោះត្រង់ វា ហើយវាក៏នឹងមិនពន្យារទៅលើដល់ដំណើរការនីតិវិធីនោះទេ។ ហើយខ្ញុំមិនមានឃើញថាមានហេតុផលអីដែល

ថា មិនអនុញ្ញាតឲ្យថតវីដេអូនោះទេ។ ដើម្បីការពារ កាលណាគាត់មិនអាចតាមដានដំណើរការនីតិវិធីបានគឺថាយើងអាចនឹងដឹងអំពីបញ្ហានេះ ហើយយើងអាចនឹងមានប្រតិចារឹកសម្រាប់ការប្ដឹងសាទុក្ខទៅតុលាការកំពូល។ សូមអរគុណ។

[១០:៣៧:១៥]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៤០:២១]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វីល្លៀម ស្មីត៖**

សូមអរគុណលោកប្រធាន។ ជាការពិតហើយដែលថា អយ្យការមិនទាស់ទៅនឹងអ្វីលើកឡើងដោយលោកសាស្ត្រាចារ្យនោះទេ។ ដូច លោក លោកស្រីចៅក្រមបានជ្រាបហើយគឺថា នៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម គឺថាមានសៀវភៅកត់ត្រាសុខភាពរបស់គាត់។

ជំហររបស់សហព្រះរាជអាជ្ញាគឺថា សុខភាពរបស់ អៀង សារី គួរតែត្រូវបានតាមដាន ទោះបីជាតាមរយៈវីដេអូក្ដី ឬក៏តាមដានដោយគ្រូពេទ្យព្យាបាលគាត់ក្ដី។ បើពាក់ព័ន្ធទៅនឹងការទ្រុឌទ្រោម ឬចុះខ្សោយសុខភាពរបស់គាត់នោះ ព័ត៌មានបែបនេះគឺថាត្រូវតែកត់ត្រាទុក ហើយបើទុកណាជាការប្រើប្រាស់ឧបករណ៍ទាំងអស់នេះ ឧទាហរណ៍ជនជាប់ចោទគាត់សម្រាន្តលក់ នោះវាមានបញ្ហានឹងចោទឡើង។

[១០:៤១:២៧]

សូមចងចាំថា លោកសាស្ត្រាចារ្យ គ្រូពេទ្យ ដែលថាគាត់មិនបានលើកឡើងអំពីថាលោក អៀង សារី នឹងអាចសម្រាន្តលក់ពេញមួយថ្ងៃនោះទេ ដោយសារតែថា ការវិលមុខ ជំងឺវិលមុខរបស់គាត់នោះទេ។ ដូចដែលអង្គជំនុំជម្រះបានស្ដាប់ឮហើយ គឺលោកសាស្ត្រាចារ្យថា ទោះជាជនជាប់ចោទជ្រើសរើសចូលរួមនៅក្នុងដំណើរការនីតិវិធី ឬក៏យ៉ាងណានោះ វាជាបញ្ហារបស់គាត់។

អ្វីដែលលោកសាស្ត្រាចារ្យបានលើកឡើងគឺថា គាត់អាចតាមដានដំណើរការនីតិវិធីពេញ១ថ្ងៃ។ តែបើសិនណាជាជនជាប់ចោទ សម្រាន្តលក់១ម៉ោង ឬក៏២ម៉ោង មិនបានតាមដានដំណើរការនីតិវិធីនោះនេះវាចោទជាបញ្ហាហើយ។ ដូច្នេះ អង្គជំនុំជម្រះគួរពិចារណាអំពីការថតវីដេអូពាក់ព័ន្ធនៅពេលដែល

ជនជាប់ចោទអាចនឹងសម្រាន្តលក់ទៅ ដោយផ្ដោតទៅលើភស្តុតាងរបស់អ្នកជំនាញ គឺថា បានលើកឡើងថា គាត់អាចតាមដានបាន។ ប៉ុន្តែបើគាត់អាចនឹងសម្រាន្តលក់ នោះវាជារឿងរបស់គាត់ ជាការបោះបង់សិទ្ធិរបស់គាត់ក្នុងការតាមដានដំណើរការនីតិវិធី។

[១០:៤២:៤៦]

ការតាមដានដំណើរការនីតិ -- សុខភាពរបស់គាត់គឺថា ជាការត្រឹមត្រូវហើយ។ ខ្ញុំយល់ឃើញថា សម្ភារៈឧបករណ៍ទាំងអស់ រួមទាំងសៀវភៅកត់ត្រាសុខភាពរបស់គាត់ គឺថាគ្រប់គ្រាន់ហើយ។ ប៉ុន្តែបើសិនណាជាគាត់សម្រាន្តលក់យ៉ាងណា គឺត្រូវតែកត់ត្រា។ ប៉ុន្តែថាតើត្រូវថតវីដេអូ ឬក៏មិនថតនោះ នោះគឺជាឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះដែលត្រូវពិចារណា ដែលត្រូវថតវីដេអូពីនរណាម្នាក់ ដែលដើម្បីរកឲ្យឃើញថា តើអាចនឹងមានការសម្រាន្តលក់ ឬក៏យ៉ាងណានោះ។

លោក លោកស្រីចៅក្រម ចំណុចចុងក្រោយ តំណាងសហព្រះរាជអាជ្ញាមិនបានមានឱកាសឆ្លើយតបទៅនឹង -- តបទៅនឹងចម្លើយតបរបស់មេធាវីការពារក្ដីនោះទេ។ តំណាងសហព្រះរាជអាជ្ញាគឺថា មិនមាន -- មានការព្រួយបារម្ភថាតើ -- ដែលលើកឡើងថា សហព្រះរាជអាជ្ញាមិនព្រួយបារម្ភចំពោះការតាមដានដំណើរការនីតិវិធីរបស់គាត់ទេ។ តែព្រួយបារម្ភថា ខ្លាចមិនបានផ្ដន្ទាទោសគាត់ទៅវិញនោះ។ នោះមិនមែនជាបញ្ហាត្រឹមត្រូវទេ។

[១០:៤៣:៥៣]

តំណាងអយ្យការគឺៗថា ចង់មានការបង្ហាញនូវភស្តុតាង ដើម្បីធ្វើយ៉ាងម៉េចឲ្យដំណើរការជំនុំជម្រះប្រព្រឹត្តទៅដោយយុត្តិធម៌។ ហើយចំណុចពាក់ព័ន្ធគឺថា វាខុសគ្នាទៅនឹងការបំបែក អៀង ធីរិទ្ធចេញពីសំណុំរឿងនេះ។ ហើយសាធារណជនគឺថា -- គឺថាការដែលនិយាយពាក់ព័ន្ធដោយមិនពីរោះពិសា ដោយមាក់ងាយនោះ គឺថា សាធារណជនអាចពិចារណាទៅលើចំណុចនេះ។

យើងខ្ញុំសូមស្នើដល់អង្គជំនុំជម្រះឲ្យ -- កុំឲ្យលើកឡើងនូវពាក្យសម្ដីបែបនេះនៅពេលអនាគត។ ហើយតួនាទីរបស់យើងគឺថា យើងមិនត្រូវបំពារបំពាន ទៅនឹងវិជ្ជាជីវៈរបស់យើងនោះទេ។ ការជំនុំជម្រះគឺថាអាស្រ័យទៅលើសាក្សី និងភស្តុតាង។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោក មែខល កាណាវាស!

[១០:៤៥:០០]

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។

ខ្ញុំសូមឆ្លើយតបទៅនឹងតំណាងសហព្រះរាជអាជ្ញាដែលគាត់លើកឡើងបែបខឹងសម្បានេះ។ គឺថា ម្យ៉ាង គឺយើងអាចតាមដានសុខភាពរបស់គាត់ ប៉ុន្តែយើងមិនអាចតាមដានឱ្យដឹងថា តើគាត់អាចតាមដានដំណើរការនីតិវិធីបានឬក៏អត់។ បើសិន -- គាត់អាយុ៨៦ឆ្នាំហើយ បើសិនណាជាគាត់មិនអាចតាមដានបានដោយសម្រាន្តលក់ ដូច្នេះយើងខ្ញុំមិនចង់មានការកត់ត្រាណាមួយដែលនាំឱ្យមានការរំខានទៅដល់ការវិភាគចុងក្រោយ ថាគាត់ទទួលនូវការជំនុំជម្រះដោយយុត្តិធម៌នោះ។ ហេតុដូច្នេះឯង បានជាយើងខ្ញុំធ្វើការញែកឱ្យដាច់ពីគ្នា។

[១០:៤៥:៤៨]

ខ្ញុំយល់ឃើញថា សហព្រះរាជអាជ្ញាមិនមានចំណាប់អារម្មណ៍អីទៅនឹងសិទ្ធិរបស់កូនក្តីយើងខ្ញុំទេ។ បើគាត់ចាប់អារម្មណ៍ គឺថាគាត់ត្រូវតែគាំទ្រទៅដល់យើងខ្ញុំ ដែលថាត្រូវបំពាក់វីដេអូដើម្បីថត ចង់ឱ្យដឹងថា តើគាត់ -- គឺគាត់មិនអាចតាមដានដំណើរការនីតិវិធី ដូចថាតែបញ្ហាជំងឺបេះដូងរបស់គាត់ ដោយសារតែការអស់កម្លាំង រហិតរហៃដៃជើងទើបគាត់សម្រាន្តលក់ ឬក៏សម្រាន្តលក់ដោយចេតនា។ ហេតុអ្វីបានជាតំណាងសហព្រះរាជអាជ្ញា គាត់ខ្លាចបែបនេះ? ម៉េចក៏យើងមិន -- ធ្វើម៉េចឱ្យវាភ្លឺទាំងអស់គ្នា ឃើញទាំងអស់គ្នាទៅ?

ដូច្នេះខ្ញុំ ថាខ្ញុំត្រូវតែធ្វើអន្តរាគមន៍។ បើលោក អៀង សារី នៅក្នុងបន្ទប់ឃុំខ្លួនខាងក្រោម ហើយគាត់សម្រាន្តលក់ទៅ។ អ៊ីចឹងហើយបានជាខ្ញុំស្នើសុំថា ឱ្យសមាជិកនៃក្រុមការពារក្តីរបស់យើងខ្ញុំម្នាក់ទៅតាមដាន។

[១០:៤៦:៤២]

**ប្រធានអង្គជំនុំ៖**

លោកៗ លោកមេធាវី លោកអាចមិនធ្វើឡើងវិញទេ។ លោកអំមិញ គឺមានការឆ្លើយតបរបស់លោកតំណាងសហព្រះរាជអាជ្ញា។ កម្រិតលោកអាចលើកឡើង គឺលើកកម្រិតឆ្លើយទៅនឹងអ្វីដែលលោកកត់សម្គាល់ឃើញបានហើយ។ លោកមិនវិលត្រឡប់ទៅវិញទេ។

**លោក ម៉ៃខល កាណាវាស៖**

សូមអរគុណលោកប្រធាន។ បាទ ជាថ្មីម្តងទៀត គឺយើងខ្ញុំចង់បង្ហាញជំហររបស់ខ្ញុំថា ការតាម

ដាននៃសុខភាពរបស់គាត់ គឺវាខុសពីការតាមដានឲ្យដឹងថាតើគាត់អាចតាមដាននីតិវិធីបាន ឬក៏អត់នោះ។ ហេតុដូច្នេះឯងបានជាយើងខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថា ត្រូវតែមានការកត់ត្រាឲ្យបានត្រឹមត្រូវ។ បើមិនអនុញ្ញាតយើង ក្រុមយើងខ្ញុំតាមដានស្ថានភាពសុខភាពលើការតាមដាននីតិវិធីដោយសមាជិកនៃក្រុមការពារក្ដីរបស់យើងខ្ញុំទេ ដោយសារតែខ្ញុំយល់ថា នេះគឺគាត់សម្រាន្តលក់ គឺថាវាជាការសវនាការកំបាំងមុខហើយ។ សូមអរគុណ។

[១០:៤៧:៥២]

**លោក វីវៀ្ញម ស្មីត៖**

យើងខ្ញុំសូមឆ្លើយតបដោយសង្ខេប។ តំណាងសហព្រះរាជអាជ្ញាមិនបានលើកឡើងថា យើងខ្ញុំជំទាស់ទៅនឹងការថតវីដេអូលោក អៀង សារី នោះទេ។ តំណាងសហព្រះរាជអាជ្ញា គឺថាបានលើកឡើងថា "ទុកសេចក្ដីសម្រេចនេះទៅលើឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ"។ ហើយសំណើ -- នេះជាសំណើទី១។ ទី២ តំណាងសហព្រះរាជអាជ្ញាមិនបានលើកឡើងថា មិនត្រូវតាមដានជនជាប់ចោទនោះទេ គឺត្រូវតែតាមដានដោយគ្រូពេទ្យ ឬក៏អ្នកថែទាំសេវាសុខភាពណាម្នាក់។ ហើយនោះ យើងមានសៀវភៅកត់ត្រានៅទីនោះស្រាប់ហើយ។

ដូច្នេះ មេធាវីការពារក្ដីហាក់បីដូចជាភ្លេចនូវចំណុចទាំងអស់នេះ ដែលជាភស្តុតាងនេះ។ ហើយមេធាវីគាត់ស្ដាប់ លើកឡើងតែសំណើរបស់គាត់ ហើយសំណើនេះគឺថាអាស្រ័យទៅលើអង្គជំនុំជម្រះជាអ្នកសម្រេច។ សូមអរគុណ។

[១០:៤៨:៥០]

*(ចៅក្រមពិភាក្សាគ្នា)*

[១០:៥១:៥៩]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមផ្ដល់ ប្រគល់ភារៈជូនទៅលោកស្រីចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍ ដើម្បីបន្តនូវសេចក្ដីសម្រេចរបស់អង្គជំនុំជម្រះ បញ្ចប់នូវបញ្ហាដែលលើកឡើងដោយមេធាវីការពារក្ដីលោក អៀង សារី ចំពោះបញ្ហាសុខភាពនៃការចូលរួមនៅក្នុងកិច្ចដំណើរការថ្ងៃនេះ។ សូមអញ្ជើញលោកស្រីចៅក្រម!

**ចៅក្រម ស៊ីលវៀ ខាតវ៉ាយថ៍៖**

សូមអរគុណលោកប្រធាន។

អង្គជំនុំជម្រះសាលាដំបូងបានសម្រេចរួចមកហើយថា អង្គជំនុំជម្រះនឹងមិនឲ្យថតវីដេអូជនជាប់ចោទនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោមនោះទេ។ ហើយអាចនឹងធ្វើវិសោធន៍កម្ម -- ហើយអង្គជំនុំជម្រះមិនធ្វើការកែប្រែទៅលើសេចក្ដីសម្រេចនេះទេ។ ហើយមេធាវីការពារក្ដីបានលើកឡើងចំណុចដដែលៗដែលអង្គជំនុំជម្រះបានសម្រេចរួចមកហើយ។

[១០:៥៣:០៥]

បញ្ហាចម្បងបំផុតសម្រាប់អង្គជំនុំជម្រះ គឺបញ្ហានៃការវាយតម្លៃទៅលើស្ថានភាពសុខភាពនៃសម្បទារបស់លោក អៀង សារី ក្នុងការចូលរួមក្នុងសវនាការ។ ហេតុដូច្នេះឯង ការតាមដានសុខភាពដោយគ្រូពេទ្យព្យាបាលគាត់នេះ គឺជារឿងសំខាន់ណាស់។ វាជាមធ្យោបាយមួយដែលជួយបង្កលក្ខណៈជម្រាបដល់អង្គជំនុំជម្រះ ក៏ដូចភាគីទាំងអស់អំពីស្ថានភាពសុខភាពរបស់លោក អៀង សារី បើមានការកែប្រែណាមួយ។ នេះគឺជាហេតុផលមួយដែលសមស្របសម្រាប់បង្កលក្ខណៈឲ្យគាត់ស្ថិតនៅក្នុងបន្ទប់ឃុំឃាំងខាងក្រោម ដែលគ្រូពេទ្យគឺថា អាចនឹងពិនិត្យ តាមដានសុខភាពរបស់គាត់។

ក្រុមមេធាវីការពារក្ដីរបស់ អៀង សារី អាចនឹងឲ្យបុគ្គលិកណាម្នាក់ពីក្រុមរបស់ខ្លួនចូលទៅបន្ទប់ឃុំឃាំងខាងក្រោម ដែលបើសិនណាជាក្រុមមេធាវីការពារក្ដីយល់ឃើញថា សមាជិកនៃក្រុមការពារក្ដីនោះអាចនឹងធ្វើសេចក្ដីសន្និដ្ឋានទៅលើស្ថានភាពសុខភាពរបស់លោក អៀង សារី ចេញពីការកត់សម្គាល់របស់គ្រូពេទ្យព្យាបាល។

ខ្ញុំយល់ឃើញថា នេះគឺជាសេចក្ដីសម្រេចដែលអង្គជំនុំជម្រះបានសម្រេច គឺលើកឡើងប៉ុណ្ណោះគឺគ្រប់គ្រាន់ហើយលោកប្រធាន។ សូមអរគុណ។

[១០:៥៤:២៧]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកស្រីចៅក្រម។

ជាបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដែលមានបំណងលើកឡើងនូវបញ្ហាផ្សេងៗ នៅពេលព្រឹកមិញនេះ។ សូមអញ្ជើញ!

**លោក អេនត្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រី។ ខ្ញុំគិតថា មានបញ្ហាដែលយើងមិនទាន់បានបញ្ចប់ទាក់ទងទៅនឹងការលេច -- ការទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណី TCCP

អោ រី កាលពី -- ដូច្នេះ យើងមិនទាន់បានធ្វើការសម្រេចឲ្យច្បាស់លាស់ ទាក់ទងទៅនឹងដើមបណ្ដឹងរដ្ឋប្បវេណីនេះទេ ថាតើយើងអនុញ្ញាតឲ្យមានការបើកវេទិកាបន្តទៀត ដើម្បីជាការឆ្លើយតបទៅនឹងព្យសនកម្មរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬក៏អត់។ ខ្ញុំបានលើកតាំងពីព្រឹក ដើម្បីឲ្យមានការធ្វើបែបនេះ ប៉ុន្តែមិនមានការអនុញ្ញាត។ ហើយខ្ញុំបានឮសួរខាងចៅក្រម ខាតវ៉ាយថ៍ បានបង្គាប់ឲ្យលោកប្រធានថា "ឲ្យដកខ្ញុំចេញពីសាលសវនាការ ឬមួយក៏ឲ្យបញ្ឈប់ខ្ញុំពីសាលសវនាការនេះ"។

ដូច្នេះ ខ្ញុំគិតថា យើងគួរតែឲ្យមានការលើកឡើង ឬក៏បើកវេទិកា ដើម្បីឲ្យឆ្លើយតបទៅនឹងព្យសនកម្ម អោ រី កាលពីសប្ដាហ៍មុន ថ្លែងទុក្ខសោករបស់ដើមបណ្ដឹងរដ្ឋប្បវេណី។ យើងគិតថា យើងមិនមានការលើកលែងណាមួយចំពោះការស្នើសុំ ដែលមេធាវីការពារក្ដីស្នើសុំដល់អង្គជំនុំជម្រះដើម្បីឲ្យធ្វើការចោទសួរសំណួរ ដូចដែលបានចោទសួរទៅនឹងជនជាប់ចោទផងដែរ។ ព្រោះថា ដើមបណ្ដឹងរដ្ឋប្បវេណីគាត់អាចធ្វើសំណើទៅអង្គជំនុំជម្រះដើម្បីសួរដល់ជនជាប់ចោទ ដូច្នេះ ជនជាប់ចោទក៏គួរតែមានឱកាសដើម្បីធ្វើសំណើទៅអង្គជំនុំជម្រះដើម្បីសួរទៅដល់ដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។

[១០:៥៦:៣២]

ជាថ្មីម្ដងទៀត ក្នុងសិទ្ធិជាដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់ នៅពេលដែលដើមបណ្ដឹងរដ្ឋប្បវេណីបានសំណើ។ ព្រោះថា នៅពេលដែលដើម -- ជនជាប់ចោទគាត់បញ្ជាក់ថាគាត់មិនចង់ឆ្លើយតបសំណួរ គឺសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីបានបញ្ចប់។ មិនគួរមានការបន្តសិទ្ធិរបស់ដើមបណ្ដឹងរដ្ឋប្បវេណីនេះទៀតឡើយ ហើយខ្ញុំសូមបន្តទៅនឹងចំណុចមួយទៀត ដែលខ្ញុំចង់និយាយ គឺខ្ញុំចង់និយាយអំពីថ្ងៃសុក្រ ទី២៣ ខែវិច្ឆិកា គឺនៅពេលដែលយើងបានបញ្ចប់សវនាការ។

លោក អោ រី បានលើកសំណួរទៅលោកប្រធាន បានស្នើសុំដល់លោកប្រធាន ដើម្បីឲ្យគាត់អាចសួរសំណួរទៅលោក ខៀវ សំផន។ លោកប្រធានបានបញ្ជាក់ថា "សំណួរអាចដាក់ដោយផ្ទាល់មកលោកប្រធាន ហើយលោកប្រធានអ្នកសួរបន្ត"។ នៅចំណុចនោះ សហការីរបស់យើង គឺលោកស្រី អង់តា ហ្គីសសេ បានងើបឈរដើម្បីជម្រាបដល់អង្គជំនុំជម្រះអំពីគោលជំហររបស់លោក ខៀវ សំផន។ លោកប្រធាននៅពេលនោះ តាមការយល់ឃើញរបស់ខ្ញុំគឺបានបង្គាប់បញ្ជាដោយមិនត្រឹមត្រូវដល់លោកស្រី អង់តា ហ្គីសសេ មិនឲ្យនិយាយ ហើយឲ្យតែលោក ខៀវ សំផន អ្នកនិយាយ។ ហើយបញ្ហានេះវាបានបន្តទៅមុខ ហើយតាមការលើកឡើងរបស់ខ្ញុំ លោកប្រធានបានប្រាប់ដោយគ្មានមូលហេតុដល់លោកស្រី អង់តា ហ្គីសសេ ឲ្យអង្គុយ ដោយមិនឲ្យនិយាយ។

[១០:៥៨:១២]

ហើយនៅពេលនោះ លោក ខៀវ សំផន បានងើបឡើងឈរ ដើម្បីប្រាប់ថាគាត់មិនចង់និយាយ។ ហើយអានេះគឺជាអ្វីដែលលោកស្រី អង់តា ហ្គិសសេ ចង់ងើបឡើងនិយាយប្រាប់លោកប្រធាននោះឯង។ ដូច្នេះ អ្វីដែលខ្ញុំចង់និយាយ ថាតើក្នុងករណីដែលខ្ញុំ ឬក៏ អង់តា ហ្គិសសេ ឬក៏លោក ម៉ៃខល កាណាវាស ងើបឈរឡើង ដើម្បីឆ្លើយជំនួសកូនក្ដីរបស់យើង ដើម្បីបញ្ជាក់អំពីគោលជំហររបស់កូនក្ដីរបស់យើង យើងងើបឈរឡើងដើម្បីបញ្ជាក់អំពីជំហររបស់កូនក្ដីរបស់យើង។ ដូច្នេះ វាគ្មានហេតុផលណាមួយ ខ្ញុំគិតថា គ្មានករណីលើកលែងណាមួយដែលថា លោកប្រធានអាចធ្វើឱ្យ អន្តរាគមន៍យើង ហាមឃាត់យើងក្នុងនាមជាភាគីនោះឡើយ។ ព្រោះថាយើងបានប្រើប្រាស់សិទ្ធិរបស់យើង ហើយយើងមកទីនេះ ដើម្បីការពារក្ដីរបស់យើង។ ដូច្នេះ ខ្ញុំគិតថា វាជាលើកលែងពិសេសបំផុត ដែលលោកប្រធានបានធ្វើបែបនេះ ចំពោះមេធាវី អង់តា ហ្គិសសេ។ ហើយខ្ញុំសូមស្នើថា លោកប្រធានគួរតែពិនិត្យមើលទៅលើក្រមសីលធម៌តុលាការ ហើយនិងក្រមសីលធម៌នានា ដែលមាននៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ខ្ញុំគិតថា អ្វីដែលលោកប្រធានបានធ្វើចំពោះមេធាវី អង់តា ហ្គិសសេ កាលពីលើកមុននោះ គឺមិនត្រឹមត្រូវទាល់តែសោះតែម្ដង។ ដោយសារតែលោក ខៀវ សំផន មិនមែនជាកូនក្ដីរបស់ខ្ញុំ ខ្ញុំសូមបញ្ជាក់ថា តួនាទីរបស់យើងនៅទីនេះ គឺក្នុងនាមជាមេធាវីការពារក្ដី ដើម្បីតំណាងឱ្យក្ដីរបស់យើង ហើយយើងគោរពតួនាទីរបស់យើង។

[១០:៥៩:៥២]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនណាស់ អរគុណច្រើនមេធាវី ប៉ុណ្ណឹងបានហើយ។ យើងស្ដាប់សមល្មមនឹងស្ដាប់បានហើយ ប៉ុន្តែលោកមេធាវីបានមើលឯកសាររួចហើយ លោកមេធាវី ដូចជាមានភ័ន្តច្រឡំ សូម្បីតែមើលឯកសាររួច ហើយលោកលើកមកនិយាយ ទំនងជាមិនមែនជា អោ រី ទេ អោ រី យើងបានកំណត់ច្បាស់លាស់ ទំនងជា ចៅ នី ទេ។ សូម្បីតែគ្រាន់តែឈ្មោះមនុស្សដែលៗមានបញ្ហាហ្នឹងលោកលើកមិនត្រូវផង មិនដឹង អោ រី មិនដឹង ចៅ នី ផង។ បានហើយ ប៉ុណ្ណឹងបានហើយ យើងអរគុណច្រើន។

**លោក អេនឌ្រូ អ៊ីនូហ្ស៊ី៖**

ខ្ញុំសូមបញ្ជាក់ថា ខ្ញុំសូមបញ្ជាក់ឱ្យបានច្បាស់ថា នេះមិនមែនជាខាងរបស់យើងទេ ដែលបញ្ជាក់ថា អោ នី (ស៊ីក) អោ រី នោះ។

[១១:០១:០០]

**ប្រធានអង្គជំនុំ៖**

យើងឲ្យលោកមានបញ្ហាអីទៀត លោកអាចនិយាយបានទៀត។ ឥឡូវនេះយើងបានអរគុណលោករួចហើយ។ ការកត់សម្គាល់របស់លោក ជាមេរៀនសម្រាប់យើង ជាប្រធានអង្គសវនាការ ដើម្បីប្រឹងប្រែងធ្វើឲ្យល្អប្រសើរ ពីព្រោះសវនាការហ្នឹង ៣, ៤ ឆ្នាំ យ៉ាងវែងដូច្នេះ។ គ្រាន់តែយើងកត់សម្គាល់លោកវិញថា គ្រាន់តែលោកអានទូវភាពដែលពាក់ព័ន្ធនៃបញ្ហាដែលលើកឡើង ឈ្មោះមនុស្សហ្នឹងលោកអានមិនត្រូវផង។ លោកកំណត់ឈ្មោះមិនត្រូវផង តែប៉ុណ្ណឹងទេ។

មានបញ្ហាអ្វីផ្សេងទៀតសូមអញ្ជើញលើកបន្តទៀត?

**លោក អេនឌ្រូ អ៊ីនូហ្វ៊ី៖**

សូមអរគុណលោកប្រធានដែលបានជម្រាប។ ចំណុចមួយទៀតចុងក្រោយ គឺពាក់ព័ន្ធទៅនឹងអ្វីដែលខ្ញុំចង់និយាយនៅពេលព្រឹកនេះ ហើយខ្ញុំគិតថានេះជាចំណុចក្រោយរបស់ខ្ញុំ។

នៅពេលដែលបញ្ចប់ការចោទសួររវាងចៅក្រម ឡាវែន៍ ហើយនិងមេធាវី អង់តា ហ្គីសសេ ខ្ញុំចង់ដឹងថាតើ -- ឥឡូវនេះជាឧទាហរណ៍មួយ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណីថ្លែងទុក្ខសោក ហើយការថ្លែងទុក្ខសោកហ្នឹងបានលើកឡើងនូវបញ្ហាថ្មីមួយ ហើយបញ្ហាដែលលើកឡើងហ្នឹង វាអាចជាការឆ្លើយដាក់ទៅដល់ជនជាប់ចោទក្នុងលក្ខណៈណាមួយ។

[១១:០២:៣៣]

លោកស្រី អត់តា ហ្គីសសេ ចង់ដឹងថាតើវាជាការត្រឹមត្រូវដែរទេ ដែលអាចអនុញ្ញាតឲ្យគាត់កោះហៅសាក្សី ឬក៏ឲ្យអង្គជំនុំជម្រះកោះហៅសាក្សីមកឡើងវិញ ដើម្បីធ្វើការសួរដេញដោល? ខ្ញុំគិតថាវាមានការផ្លាស់ប្តូរយោបល់រវាងចៅក្រម ឡាវេន៍ ហើយនិង អង់តា ហ្គីសសេ។ ហើយបើតាមដែលខ្ញុំចាំគឺថានៅក្នុងការពិភាក្សាគ្នានោះ គឺវាហាក់ដូចជាគួរឲ្យចាប់អារម្មណ៍ ខ្ញុំមិនប្រាកដថាតើយើងមានគោលជំហរបែបណានោះទេ នៅពេលដែលមានការពិភាក្សាគ្នា នៅពេលដែលគាត់ប្រើ អ៎! ពេលដែលគាត់ងើបឈរ លោកស្រីចៅក្រម ខាតវ៉ាយថ៍ បានប្រាប់លោកប្រធានថា "កុំៗ លោកប្រធានឲ្យអង្គុយចុះទៅ"។ ហើយឲ្យបញ្ចប់ទៅ។ នៅពេលនោះ លោកប្រធានគាត់ថាសំណើសុំហ្នឹងត្រូវបានបដិសេធ។ ដូច្នេះហើយអ្វីដែលយើងចង់និយាយថា គឺថាយើងបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះ យើងចូលមកចូលរួមនៅក្នុងសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ឬក៏មកយើងមកចូលតែនៅចំពោះមុខ

លោកប្រធាន និល ណុន និងលោកស្រីចៅក្រម ខាត់រ៉ាយថ៍ នោះទេ។ ខ្ញុំគិតថា ហើយខ្ញុំសង្ឃឹមថា អង្គជំនុំជម្រះសាលាដំបូង មិនមែនចៅក្រមជាបុគ្គលនោះទេ គឺថាអង្គជំនុំជម្រះទាំងមូលធ្វើការចេញនូវសេចក្តីសម្រេច មិនមែនតែចៅក្រមមួយរូប ពីររូបនោះទេ។

[១១:០៣:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណច្រើនណាស់។ យើងធ្វើការងារកន្លងមក គឺចែកចេញជាពីរផ្នែកខុសគ្នារវាងឆន្ទានុសិទ្ធិក្នុងនាមប្រធានអង្គជំនុំសវនាការ និងអង្គជំនុំជម្រះ។ ក្នុងការអនុវត្តច្បាប់ជាតិដូចគ្នា។

បញ្ហាប្រកាសបើកសវនាការ បញ្ហាសម្រាក មិនមែនចាំពិភាក្សាគ្នាទាំងប្រាំរូប ហើយសម្រេចថាសម្រាក ឬក៏អត់សម្រាក ប្រកាសបើកសវនាការ ឬក៏អត់បើកនោះទេ។ វាមានរឿងឆន្ទានុសិទ្ធិរបស់ប្រធាននៅក្នុងការសម្រេច និងរឿងបញ្ហាដែលត្រូវសម្រេចដោយសមូហភាពនៃអង្គជំនុំជម្រះ។ យើងគិតថាយើងធ្វើ ប្រព្រឹត្តឱ្យបានត្រឹមត្រូវជាអតិបរមានូវនីតិវិធី ដែលអនុវត្តនៅយើង -- នៅក្នុងប្រទេសយើង តាំងពីដើមមក យើងមានវិជ្ជាជីវៈជាចៅក្រមនេះ គឺយើងប្រិតប្រៀង និងប្រឹងប្រែងធ្វើឱ្យបានត្រឹមត្រូវណាស់។

ជាការពិតណាស់ យើងទទួលស្គាល់ថា អាចមានការភ័ន្តច្រឡំរវាងការកំហិតនៃប្រើសិទ្ធិក្នុងនាមប្រធាន ឆន្ទានុសិទ្ធិប្រធាន ហើយនិងបញ្ហាដែលបែងចែករវាងថា បញ្ហាណាខ្លះដែលត្រូវសម្រេចជាសមូហភាព។ ដោយសារបញ្ហាវាយូរអង្វែង វាវែង។ តែទោះបីយ៉ាងណា យើងអរគុណលោកជាអនេកដែលលោកបានធ្វើការសង្កេតប៉ុណ្ណេះ។ ហើយយើងក៏បានសង្កេតលោកវិញរួចហើយអំពីបញ្ហានេះ។

ឥឡូវនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកដើម្បីពិសាអាហារថ្ងៃត្រង់ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយសាម--

សូមអញ្ជើញមានបញ្ហាអី?

[១១:០៦:០២]

**លោក អេនគ្រូ អ៊ីនូហ្សី៖**

លោកប្រធាន ខ្ញុំសូមថ្លែងអំណរគុណចំពោះចម្លើយដ៏ល្អរបស់លោកប្រធាន។ ហើយខ្ញុំសូមបញ្ជាក់ថា ដើម្បីជាកំណត់ត្រា ប្រសិនបើយើងប្រើប្រាស់នូវការរៀបចំកាលវិភាគថ្មី ប្រហែលជាតុលាការហ្នឹងត្រូវដំណើរការក្នុងលក្ខណៈមួយថ្មីផ្សេងទៀតមើលទៅ។

**ប្រធានអង្គជំនុំ៖**

អរគុណ។ មានការភ័ន្តច្រឡំ អំមិញមិនមែនម៉ោងដប់ពីរទេ។ ម៉ោងទើបតែម៉ោងដប់មួយទេ។ អ៊ីចឹងយើងបន្តស្តាប់សក្ខីកម្មដើមបណ្តឹងរដ្ឋប្បវេណី ដែលបានគ្រោងទុក។

មន្ត្រីរដ្ឋបាលតុលាការ កោះអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-188 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ!

[១១:០៦:៥០]

*(ដើមបណ្តឹងរដ្ឋប្បវេណីចូលក្នុងបន្ទប់សវនាការ)*

[១១:០៨:៤៧]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីដើមបណ្តឹងរដ្ឋប្បវេណី! តើលោកស្រីឈ្មោះអី?

**លោកស្រី ទឹង សុខា៖**

**ឆ៖** នាង ខ្ញុំឈ្មោះ ទឹង សុខា។

**ស៖** អរគុណលោកស្រី ទឹង សុខា។ តើលោកស្រីកើតនៅថ្ងៃខែឆ្នាំណា? លោកស្រីចាំថ្ងៃខែឆ្នាំកំណើតរបស់លោកស្រីដែរទេ?

**ឆ៖** ចាស ខ្ញុំចាំលោកប្រធាន គឺថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៤៧។

**ស៖** បាទ អរគុណ។ ហើយតើលោកស្រីអាចប្រាប់អំពីទីកន្លែងកំណើតរបស់លោកស្រីដល់អង្គសវនាការបានដែរឬទេ? តើលោកស្រីកើតនៅទីកន្លែងណា?

**ឆ៖** ចាស លោកប្រធាន ខ្ញុំកើតនៅភូមិស្វាយតានាន់ ឃុំព្រែករំដេង ស្រុកស្រីសន្ធរ ខេត្តកំពង់ចាម។

**ស៖** បាទ អរគុណ។ ហើយចុះលំនៅដ្ឋានរបស់លោកស្រីវិញ តើសព្វថ្ងៃនេះលោកស្រីរស់នៅទីកន្លែងណា? -- ចាំៗ រង់ចាំក្បាលមីក្រូហ្វូនប្រតិបត្តិការ!

[១១:១០:១០]

**ឆ៖** ខ្ញុំរស់នៅភូមិ៣ សង្កាត់ជ្រោយចង្វា ផ្លូវទន្លេមេគង្គ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ។

**ស៖** បាទ អរគុណ។ ចុះលោកស្រីប្រកបមុខរបរអ្វីដែលសព្វថ្ងៃនេះ?

**ផ៖** ចាស ខ្ញុំសព្វថ្ងៃ ខ្ញុំជាមន្ត្រីចូលនិវត្តរួចហើយ។

**ស៖** បាទ អរគុណ។ ហើយចុះឪពុកបង្កើតរបស់លោកស្រីឈ្មោះអី?

**ផ៖** ចាស លោកឪពុកឈ្មោះ ទឹង គុយ។

**ស៖** បាទ អរគុណ។ ចុះម្តាយបង្កើតរបស់លោកស្រីឈ្មោះអី?

**ផ៖** ចាស ម្តាយបង្កើតឈ្មោះ លី ប៉ាច។

**ស៖** បាទ អរគុណ។ ចុះលោកស្រីមានប្តីដែលឬទេ? ឬក៏នៅលីវ អ៎!នៅលីវសព្វថ្ងៃនេះ?

**ផ៖** ចាស គ្រួសារខ្ញុំ ស្វាមីខ្ញុំបានស្លាប់ គាត់ចូលមរណកាលហើយ ខ្ញុំនៅមេម៉ាយចាស។

**ស៖** លោកស្រីមានកូនប៉ុន្មាននាក់?

**ផ៖** ពេលឥឡូវខ្ញុំមានកូនពីរនាក់។ ម្នាក់បានស្លាប់នៅសម័យខ្មែរក្រហមហើយ ទាំងអស់បីចាស។

[១១:១១:៥៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ លោកស្រី ទឹង សុខា ក្នុងនាមលោកស្រីជាដើមបណ្តឹងរដ្ឋប្បវេណី លោកស្រីអាចថ្លែងរៀបរាប់ប្រាប់ដល់អង្គសវនាការអំពីស្ថានភាពព្យសនកម្ម ឬស្ថានភាពទុក្ខសោកវេទនា ដែលកើតមានចំពោះលោកស្រីដែលមានជាអាទិ៍ ការខូចខាតខាងផ្លូវចិត្ត ខាងរូបកាយ ឬក៏ខាងសម្ភារៈ ជាព្យសនកម្មផ្ទាល់ខ្លួនដែលជាបច្ច័យដោយផ្ទាល់ពីបទឧក្រិដ្ឋ និងបានកើតមានពិតប្រាកដរហូតមកដល់បច្ចុប្បន្ននេះ ដែលនាំឲ្យលោកស្រីសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលពាក់ព័ន្ធទៅនឹងបទឧក្រិដ្ឋដែលត្រូវបានចោទប្រកាន់ទៅលើជនជាប់ចោទ ដែលប៉ះពាល់ចំពោះលោកស្រីក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ។ នេះគឺជាសិទ្ធិរបស់លោកស្រី ដែលលោកស្រីអាចធ្វើដូច្នេះនាពេលចុងក្រោយបំផុតនៃការផ្តល់សក្ខីកម្មរបស់លោកស្រី។ អង្គជំនុំជម្រះជម្រាបនេះ គ្រាន់តែលោកស្រីដឹងអំពីសិទ្ធិ ហើយលោកស្រីអាចត្រៀមក្នុងលក្ខណៈសម្បត្តិក្នុងការអនុវត្តសិទ្ធិក្នុងការថ្លែងរៀបរាប់ បង្ហាញអំពីទុក្ខសោកវេទនា និងព្យសនកម្មនេះនៅពេលចុងក្រោយនៃដំណើរការផ្តល់សក្ខីកម្មរបស់លោកស្រីតែប៉ុណ្ណោះ។

ហើយអង្គជំនុំជម្រះសូមជម្រាបជូនដល់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីថា ដើម្បីអនុវត្តតាមបទប្បញ្ញត្តិតាមវិធាន៩១ ស្ទួន នៃវិធានផ្ទៃក្នុង អង្គជំនុំជម្រះសាលាដំបូងផ្តល់វេទិកាជូនទៅតំណាងសហ -- ទៅសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី សួរដេញដោលដើមបណ្តឹងរដ្ឋប្បវេណីរូបនេះមុនភាគីឯទៀតនៃរឿងក្តី ហើយក៏សូមបញ្ជាក់ផងដែលថា រយៈពេលនៃការ

តាំងសំណួរដេញដោល រួមទាំងសហព្រះរាជអាជ្ញាផង គឺកន្លះថ្ងៃ សម្រាប់ភាគីនីមួយៗ។

សូមអញ្ជើញ!

[១១:១៣:៥៧]

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន មេធាវីនាំមុខសូមផ្ទេរសិទ្ធិជូន សំ សុគង់ ហើយនិងលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត ដើម្បីសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញ!

**លោក សំ សុគង់៖**

ជាបឋម ខ្ញុំបាទសូមគោរពលោកប្រធានក្រុមប្រឹក្សា ហើយនិងសូមគោរពក្រុមប្រឹក្សា ហើយសូមគោរពអង្គសវនាការទាំងមូល។

ហើយសូមជម្រាបសួរលោកស្រី ទឹង សុខា ហើយខ្ញុំបាទជាមេធាវី សំ សុគង់ ជាមេធាវីដើមបណ្តឹងរដ្ឋប្បវេណី សូមតាំងសំណួរទៅលោកស្រី។ នៅក្នុងសំណួរនោះគឺចែកចេញជាបីផ្នែក។ ផ្នែកទី១ ខ្ញុំចង់សួរលោកស្រីទាក់ទងនឹងមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ ហើយនិងដំណាក់កាលទី២ ផ្នែកទី២ គឺទាក់ទងនឹងការជម្លៀសក្នុងដំណាក់កាលទី២។ ហើយផ្នែកទី៣ ខ្ញុំនឹងសួរលោកស្រីទាក់ទងនឹងការជម្លៀសក្នុងដំណាក់កាលទី២។

[១១:១៥:០៧]

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក សំ សុគង់៖**

**ស៖** សួរទី១ ដែលខ្ញុំត្រូវសួរលោកស្រី ខ្ញុំចង់សួរថា នៅមុនឆ្នាំ -- នៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកស្រីរស់នៅទីណាដែរ?

**លោកស្រី ទឹង សុខា៖**

**ឆ៖** សូមជម្រាបលោកប្រធាន ថ្ងៃ មុនថ្ងៃ១៧ មេសា ខ្ញុំរស់នៅក្នុងផ្ទះ ខ្ញុំភ្លេចលេខផ្ទះ ប៉ុន្តែផ្ទះនៅមុខ តាមផ្លូវលេខ១០៥ គឺជាផ្ទះឈើមួយខ្នង។ ខាងក្រោមមានរៀបបេតុង ខាងលើជាផ្ទះឈើ ហើយ

ប្រក់ក្បឿង នៅតាមផ្លូវលេខ១០៥ ខាងមុខវត្តទួលទំពូង ហៅថា ផ្លូវលូទឹកស្អុយ ត្រង់ម៉ុំហ្នឹង។

[១១:១៦:០៦]

**សះ** តើនៅមុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥ តើលោកស្រីបានឃើញមានព្រឹត្តិការណ៍អ្វីខ្លះដែលកើតឡើងនៅក្នុងទីក្រុងភ្នំពេញ ក៏ដូចជាប្រទេសកម្ពុជាទាំងមូល?

**ឆះ** សូមជម្រាបលោក នៅថ្ងៃ១៦ មេសា ទៅខាងមុខវិញគឺមានជាការជាសង្គ្រាមប្រយុទ្ធគ្នា។ ថ្ងៃ១៦ ហ្នឹង គឺជាការប្រយុទ្ធបាញ់ផ្លោង កប៉ាល់ យន្តហោះអី ហោះពីលើដំបូលផ្ទះយើងហ្នឹងប្រយុទ្ធគ្នាឮឆ្ងាយ ឮជិត ទម្លាក់គ្រាប់បែកឆ្ងាយ ទម្លាក់គ្រាប់បែកជិត ផ្លោងចុះផ្លោងឡើងចាស។ ពួកយើងនៅថ្ងៃនុ៎ងបងប្អូនរត់ពីនេះពីនោះ ពីទួលគោក ពីណាពី -- មុន ១៧ហ្នឹង គឺមកពីខាងទួលគោកក៏មានមក ពីខាងទឹកល្អក់ក៏មានមកផ្ទះខ្ញុំ។ ហើយមានបងប្អូនមួយចំនួនមកពីខេត្តកំពង់ស្ពឺហ្នឹងមកពីមុនហ្នឹង។ ហ្នឹងគឺគាត់រត់មកគ្រួសារគាត់ច្រើនណាស់ ដោយសារសង្គ្រាមនៅឆ្ងាយក៏មាន នៅជិតក៏មាន ចាស។ ហើយមនុស្សជាច្រើនមក ហើយមានប្អូនមួយមកទៀត មកពីទួលគោកហ្នឹង គឺមានទាំងកូនមកទៀត តែខ្ញុំដល់ភ័យពេកហ្នឹងមិនអាចដឹងថា អ្នកណានៅលើ អ្នកណានៅផ្ទះ អ្នកណានៅក្រោមផ្ទះ។ យើងនាំគ្នាចុះមកនៅក្នុងត្រង់សេខាងក្រោម ក្នុងថ្ងៃ១៦ហ្នឹង។

[១១:១៧:៤៥]

តែមានពេលខ្លះ ស្រាកពីគ្រាប់ខ្លះ អ្នកម្ដាយខ្ញុំគាត់បានអញ្ជើញទៅវត្តថ្ងៃ១៦ ហ្នឹង ពីព្រោះបុណ្យចូលឆ្នាំ គាត់ទៅវត្តយកចំណីចំណុកទៅវត្តទៀត។ ដល់អ៊ីចឹងរហូតមកដល់យប់១៦ ហ្នឹង គឺយើងនៅក្នុងត្រង់សេហើយចាស។

**សះ** នៅថ្ងៃទី១៦ ខែមេសា ឆ្នាំ១៩៧៥ លោកស្រីថា ក្រុមគ្រួសារលោកស្រី គឺនៅក្នុងត្រង់សេ តើនៅថ្ងៃទីប៉ុន្មានក្រុមគ្រួសារលោកស្រីត្រូវបានគេជម្លៀសចេញពីទីក្រុងភ្នំពេញ?

**ឆះ** ចាស គឺនៅថ្ងៃទី១៧ មេសា ដែលគេជម្លៀសចេញក្រុងភ្នំពេញ ប៉ុន្តែព្រឹកមិនទាន់មានអ្នកណាមកប្រាប់ឲ្យជម្លៀសទេ នៅមួយពេលព្រឹកហ្នឹង។ នៅមានផ្លោងមួយពីរៗទៀត។ ពួកអ្នកក្នុងផ្ទះហ្នឹងគឺបំបែកគ្នា ភ័យពេក បងប្អូនហ្នឹងចេញមក ម្ដាយខ្ញុំហ្នឹង ម្ដាយក្មេករត់ទៅនៅផ្ទះបងប្អូនគាត់នៅបឹងកេងកង មានកូនពីរទៅជាមួយហើយ។ បងស្រីមួយទៀតប្រមូលអីវ៉ាន់ដែលរត់មកពីត្រាំខ្នារហ្នឹងគាត់ភ័យពេកទៅ គាត់ប្រមូលអីវ៉ាន់ប្ដីគាត់បង្ខំឲ្យរត់ទៅគីឡូលេខ៤ វិញ។ គីឡូលេខ៤ ទឹកល្អក់នោះ។

[១១:១៩:២០]

ដល់អ៊ីចឹងពួកខ្ញុំហ្នឹងវាភ័យខ្លាំងដែរ មិនដឹងជាឃាត់អ្នកណា ទុកអ្នកណាយ៉ាងម៉េច ម្ដាយក្មេកខ្ញុំហ្នឹងក៏ជូនឲ្យឪពុកក្មេកហ្នឹងនាំទៅនៅបឹងកេងកងជាមួយបងប្អូនគាត់ពីរបីនាក់ទៀត។ ចំណែកបងប្រុសមួយទៀត នាំកូនប្រុសគាត់ មានម្ដាយគាត់ មានកូនប្រុសបីនាក់ និងកូនស្រីម្នាក់ ព្រមទាំងប្រពន្ធគាត់ឲ្យរត់ទៅនៅខាងទឹកល្អក់វិញ។ ដល់អ៊ីចឹងប្ដីនុំងភ័យពេក ខ្ញុំឃាត់ក៏មិនឈ្នះ ក៏គាត់ត្រូវតែរៀបចំចេញទៅពីផ្ទះហ្នឹងទៅវិញ ចេញពីត្រង់សេហ្នឹង ទៅរៀបចំទូលអីវ៉ាន់អីវ៉ែចេញទៅ។ ហើយប្ដីឌុបអីវ៉ាន់ទៅមុន ប្រពន្ធទូលអីវ៉ាន់ទៅក្រោយ។ គាត់ភ័យស្លន់ មុខស្លក់គាត់អស់ហើយ កូនគាត់ឈឺទៀត។ ដូច្នេះ គាត់ដើរទៅ ដើរបាត់ទៅពីក្នុងគ្រួសារខ្ញុំហ្នឹងទៅ។

ហើយប្អូនមួយគ្រួសារទៀត ដែលប្ដីជាដុកទ័រហ្នឹង ខ្ញុំអត់បាននិយាយក្នុងឯកសារជម្រាប ប៉ុន្តែការពិតគឺបានរត់មកពីទួលគោក មកនៅផ្ទះខ្ញុំហ្នឹង មានពោះទម្ងន់មួយផង។ ពរកូនមួយផង ពីរនាក់ប្ដីប្រពន្ធ។ ឈ្មោះ ចាន់ នារី ហើយប្ដីឈ្មោះ អោម លឹមដេត។ ហើយព្រឹកហ្នឹង ខ្ញុំក៏អត់បានទៅអើតមើលថា តើប្អូនហ្នឹងទៅឯណា អីណីទេ? ពីល្ងាច ខ្ញុំយកសម្លៀកបំពាក់ឲ្យនាងអស់ហ្នឹង ពីព្រោះអត់មានយកអីមក ឲ្យមុង ហើយព្រឹកឡើង ក៏ខ្ញុំបាត់មួយគ្រួសារនោះទៅ ក៏ខ្ញុំអត់បានទឹកឃើញដល់ៗ ថាដឹងគេទៅណាដែរ។ ហ្នឹង សូមជម្រាបដល់លោកប្រធាន។ ហើយនៅពេលហ្នឹង រតាត់រតាយគ្នាច្រើនណាស់ចេញៗ អ្នកខាងក្រោមផ្ទះហ្នឹង ក៏ខ្ញុំអត់ដឹងជាអ្នកណាទៅណាទៀតទេ ដល់ប៉ុណ្ណឹង ចាស។

[១១:២១:១៩]

**ស៖** បាទ សំណួរជាបន្ត ខ្ញុំ -- ប៉ុន្តែមុននឹងសួរសំណួរ សូមជម្រាបជូនលោកស្រីថា កុំ -- សូមឲ្យឆ្លើយនឹងសំណួរ ឲ្យវាមានលក្ខណៈមួយខ្លី កុំឲ្យវែងពេក ព្រោះខ្ញុំមានសំណួរជាច្រើនទៀត ដែលត្រូវសួរលោកស្រី។ លោកស្រីថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលព្រលឹមឡើងហ្នឹង លោកស្រីមិនទាន់ត្រូវបានគេជម្លៀសពីទីក្រុងភ្នំពេញទេ ដោយសារគ្រួសាររបស់លោកស្រីត្រូវបានជម្លៀស ប៉ុន្តែជម្លៀសដែរ ប៉ុន្តែនៅក្នុងទីក្រុងភ្នំពេញឡើយ។ តើនៅពេលណាដែលក្រុមគ្រួសារលោកស្រី ត្រូវបានគេទាហានខ្មែរក្រហមជម្លៀសចេញពីក្រុងភ្នំពេញ?

**ឆ៖** ចាស នៅប្រហែលជាម៉ោងរសៀល ខ្ញុំឃើញមនុស្សដើរជាច្រើនកាត់មកតាមមុខផ្ទះហ្នឹង ហើយមានខ្មែរក្រហម ដូចជាអត់មានលីកាំភ្លើងទេ តែខ្ញុំមើលទៅ គេជាមនុស្សអ្នកគ្រាន់បើហើយមើលទៅ ដើរមក មកមានអ្នកជិតខាងចេញមក ខ្ញុំក៏ចេញមកស្ដាប់គេ។ គេ -- ហើយគាត់ថា "ញោមចេញទៅ ២, ៣ថ្ងៃទៀត អត់អីទេ អត់ខ្លាំង កុំឲ្យភ័យ ឲ្យទុកអីវ៉ាន់ហ្នឹង ក៏បាត់ដែរ និយាយអ៊ីចឹងទៀត"។

ដល់អ៊ីចឹងអ្នកទាំងអស់គ្នា ក៏ចូលមកៗ គិតគ្នាម្តងទៀត ថាត្រូវទៅណា។ ដល់ម៉ោងប្រាំ គ្រួសារខ្ញុំរត់ទៅរកមិត្តភក្តិគាត់ទៀត រកមិនឃើញ ក៏មក ថាត្រូវសម្រេចចេញហើយ ព្រោះខ្លាចគេធ្វើអ្វីៗ ព្រោះដេញថាឲ្យចេញហើយ ឲ្យចេញប្រហែលម៉ោងប្រាំ ពួកខ្ញុំចេញ។ ខ្ញុំចេញ រើអីវ៉ាន់ដាក់តាមតិចច្រើនអ៊ីចឹងទៅ មិនឲ្យធូន់អីច្រើនទេ យកល្មមទេ ព្រោះគេថា ៣ថ្ងៃហ្នឹង រៀបចំអីវ៉ាន់ហ្នឹងចេញ ដោយឥតទាន់បានទៅរកឪពុកម្តាយអីទេ គឺចេញតែខ្ញុំ ឪពុកក្មេកខ្ញុំ ប្អូនថ្លៃខ្ញុំ ហើយនិងស្វាមីខ្ញុំ និងកូនខ្ញុំពីរនាក់ និងបងប្អូនដែលរត់ចេញទៅ គាត់រត់មកវិញ ជួបគ្នាហ្នឹង ចេញទាំងអស់គ្នាមក ចាស។ ទាំងអស់ ១៤នាក់។ ពេលចេញម៉ោងប្រាំហើយ ម៉ោងល្ងាចហើយ។

[១១:២៣:៣៨]

**ស៖** នៅពេលដែលលោកស្រី -- នៅពេលដែលកងទ័ព ឬក៏ទាហានខ្មែរក្រហមគាត់មកដល់ផ្ទះលោកស្រី តើនៅពេលនោះ ទាហានខ្មែរក្រហមបានរៀបរាប់ប្រាប់លោកស្រីយ៉ាងដូចម្តេចខ្លះ ដើម្បីឲ្យលោកស្រីចាកចេញពីទីលំនៅដ្ឋាន ឬពីផ្ទះនោះ?

**ឆ៖** គាត់រៀបរាប់ មិនប្រាប់តែខ្ញុំទេ ប្រាប់អ្នកដែលនៅទល់គ្នាហ្នឹង គ្រួសារដែលនៅផ្ទះៗទល់គ្នាតាមផ្លូវហ្នឹង គេចេញមក "ថាបងចេញទៅណា? ថា ហ៊ឺ! ឲ្យចេញទៅ៣ថ្ងៃទៀត អស់ខ្លាំងហើយមកវិញ"។ ហើយយើងស្តាប់ គេអត់និយាយជាមួយយើងទេ ខ្ញុំនៅស្តាប់ហ្នឹង ស្តាប់ឈរជ្រុងអ៊ីចឹង ចាំស្តាប់ដំណឹងគេហ្នឹង ស្មានថា វាបានសុខស្រួល ប៉ុន្តែអាមនុស្សធ្វើដំណើរក៏មានខ្លះហើយ។ មនុស្សធ្វើដំណើរតាមផ្លូវហ្នឹង មានច្រើនហើយ មិនមែនតិចទេ។ បងជីដូនមួយអី ដើរមកដើងទទេ យួរអីៗ កាត់តាមមុខផ្ទះខ្ញុំ ខ្ញុំអត់បានទាំងសួរទៀតផង។ ខ្ញុំចេញផុត ថ្ងៃល្ងាចចេញពីផ្ទះហ្នឹង ចាស។

[១១:២៤:៥២]

**ស៖** នៅពេលដែលលោកស្រីចាកចេញពីលំនៅដ្ឋាន ឬក៏ត្រូវបានជម្លៀសចេញពីផ្ទះ តើលោកស្រីទៅទិសខាងណាដែរ?

**ឆ៖** ចាស ខ្ញុំបានដើរទៅត្បូង។ ទៅខាងត្បូង ចេញតាមផ្លូវ បត់ទៅផ្លូវមុនីវង្សវិញ។ ចេញត្បូងបន្តិច ព្រោះផ្ទះខ្ញុំនៅជិតកាច់ជ្រុង ចេញទៅត្បូងបន្តិច បត់ទៅផ្លូវមុនីវង្ស ហើយកាត់តាមមុខសាលាច្បាប់។ ដល់ទៅខាងផ្លូវមុនីវង្សហ្នឹង មនុស្សកាត់តែណែនច្រើនឡើងៗ ធ្វើដំណើរពិបាកហើយ ម៉ោងប្រាំៗ ម៉ោងប្រាំមួយហ្នឹងពិបាកណាស់។

**ស៖** លោកស្រីថា ចាកចេញពីលំនៅដ្ឋាន ឬក៏ពីផ្ទះហ្នឹងទៅទិសខាងត្បូង។ តើការចាកចេញ

របស់លោកស្រីត្រូវទៅតាមគោលបំណងដែលលោកស្រីចង់ទៅដែរឬទេ នៅពេលនោះ?

[១១:២៦:០១]

**ឆ៖** ចាស ខ្ញុំមិនៗដឹងជាទៅឯណា គេគ្រាន់តែថាចេញអ៊ីចឹង ដំបូងអត់មានគោលបំណងថាទៅណា ប៉ុន្តែផ្ទះយើងវានៅប៉ែកខាងត្បូងភ្នំពេញ ហើយមនុស្សដើរពីជើងមកត្បូង។ ដល់អ៊ីចឹងយើងត្រូវចេញទៅតាមទិសដែលគេដើរពីជើងទៅត្បូងហ្នឹង ទៅតាមគេហ្នឹង ទៅតាមហ្វូងមនុស្សទាំងអស់ហ្នឹង។ អត់ទាន់ដឹងទិសច្បាស់លាស់ទេ ៣ថ្ងៃហ្នឹងមិនដឹងជាទៅខាងណាទៅខាងណើ។ ចេះតែទៅៗតែតាមក្រុមដើរហ្នឹង។

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរពី ចាកចេញពីទីលំនៅ ឬក៏ផ្ទះហ្នឹងក៏ដូចជាប្រជាពលរដ្ឋទីក្រុងភ្នំពេញផ្សេងៗទៀត។ តើលោកស្រីមានបានឃើញកងទ័ពខ្មែរក្រហម ឬក៏ទាហានខ្មែរក្រហមដើរអមជាមួយនឹងប្រជាពលរដ្ឋដែរឬទេ?

**ឆ៖** ចាស មានឃើញខ្មែរក្រហមមកដល់មុខសាលាច្បាប់ ឃើញខ្មែរក្រហមច្រើនណាស់ ក្មេងៗលីកាំភ្លើង ប៉ុន្តែវាមិនមែន អ៎! គេមិនមែនមកដើរអមយើងជាច្រើននាក់ទេ មួយលិច មួយកើត ដើរបង្កប់ខាងនោះខ្លះ ខាងនេះខ្លះអីអ៊ីចឹង ចាស។ ហើយមកដល់សាលាច្បាប់ហ្នឹង ឃើញយើងបានឈប់ហើយ យប់ហើយ ដើរមិនចង់រួចទេ ម្ល៉ោះហើយវាយប់ វាឃឹតនៅកន្លែងហ្នឹង ឯណាដឹកឥវ៉ាន់សំពីងសំពោង គេក៏សំពីងសំពោង យើងក៏សំពីងសំពោង វាទទើសទទែង ណាកូនផង ណាអ្នកឈឺត្រូវដឹកផង ម្ល៉ោះហើយវាមានការលំបាកខ្លាំងណាស់។ ដល់អ៊ីចឹងបានតែត្រឹមមុខប្រហែលសាលាច្បាប់ សាលាបឹងត្របែកហ្នឹង ក៏ពួកយើងត្រូវទៅយប់ហើយ។ យើងសម្រាកនៅហ្នឹង យប់ហ្នឹង យប់ថ្ងៃ១៧ហ្នឹង។

[១១:២៧:៥៨]

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរ ក៏ដូចជាប្រជាជនពលរដ្ឋផ្សេងៗទៀតធ្វើដំណើរហ្នឹង តើមាន លោកស្រីមានបានឃើញ មានការសម្លាប់ជនជាតិ -- សូមទោស មានការសម្លាប់ទាហាន លន់នល់ នៅពេលធ្វើដំណើរដែរឬទេ?

**ឆ៖** ចាស ក្នុងមួយដំណាក់កាលមុនដំបូងហ្នឹង យប់ទី១ហ្នឹង ខ្ញុំអត់បានឃើញការសម្លាប់ទេ គ្រាន់តែឮគ្រាប់ឆ្ងាយអីផ្ទុងអ៊ីចឹងទៅ។ ជិតអីក៏មានដែរ ហើយអ្នកល្អបហ្នឹង ក្មេងទ័ពខ្មែរក្រហមហ្នឹងអ្នកខ្លះអង្គុយ អង្គុយក្បែរៗយើងគេងហ្នឹង យប់ទី១។ អង្គុយខ្លះ ដើរខ្លះហ្នឹងចាស។ អត់បានឃើញការសម្លាប់នៅឡើយទេ។

[១១:២៨:៥៩]

**សៈ** នៅពេលណាដែលលោកស្រីបានឃើញការសម្លាប់ទាហាន លន់ នល់?

**ធៈ** *(មីក្រូហ្វូនមិនទាន់ដំណើរការ)*

**សៈ** សូមម្តងទៀត ដោយសារអត់មានមីក្រូហ្វូន។

**ធៈ** ចាស សូមទោស ខ្ញុំ -- ក្នុងពេលព្រឹកឡើង យើងធ្វើដំណើរទៅទៀតហើយ ទៅទិសខាងត្បូងដដែល តែដល់ក្បាលថ្នល់ គឺគេឱ្យទិសចេញទៅកើត។ អត់មានអ្នកណាចេញមកលិចបាន អត់មានអ្នកណាចេញទៅត្បូង ឃើញទៅកើតទាំងអស់គ្នា ប៉ុន្តែក្នុងចង្អៀត ដល់យើងមកដេកនៅ យើងមកគេងសម្រាកនៅគល់ស្ពានមុនីវង្សហ្នឹងនៅខាងកើត១យប់ យប់ទី១៨ហ្នឹង ខ្ញុំគេងនៅហ្នឹង។ ព្រោះនៅអែអង់រកគ្នា គ្នីគ្នាដែលបែកបាត់ហ្នឹងរកមិនឃើញទៀត ដល់រកមិនឃើញទៅ នៅអស់១ថ្ងៃ។ នៅម៉ោ ១៨ហ្នឹងរហូតដល់យប់នៅគេងហ្នឹង នៅគល់ស្ពានហ្នឹង ហើយឃើញមនុស្សស្លាប់មាន។ មានអ្នកខ្លះស្លាប់លុតជង្គង់នៅកន្លែងមាត់ទឹកហ្នឹង ហើយមានបៀរដែលគេលេងហ្នឹង ក៏វារាត់រាយពេញហ្នឹង។ ពីព្រោះពេលព្រលប់ យប់ថ្ងៃហ្នឹងក៏នៅមានការផ្តោងពី១៧ ពីហ្នឹងមកវានៅសល់កាកសំណល់ហ្នឹង។ ខ្ញុំនៅគេងហ្នឹង១យប់។

[១១:៣០:៣៨]

**សៈ** នៅពេលដែលលោកស្រីធ្វើដំណើរ ក្រៅពីលោកស្រីឃើញមានការសម្លាប់អ្នករាជការ ឬទាហានលន់លន់។ តើលោកស្រីមានបានឃើញចាស់ជរា ឬក៏ដូចជាកុមារ នៅពេលធ្វើដំណើរហ្នឹងមានការលំបាកអ្វីខ្លះដែរ លោកស្រី?

**ធៈ** ចាស លោកប្រធាន នៅពេលធ្វើដំណើរហ្នឹងមនុស្សចាស់ជរាពិបាក។ ដែលត្រឹម៧០ឡើងទៅ មានអ៊ំរបស់ខ្ញុំហ្នឹង។ អ៊ំរបស់ខាង -- អ៊ំរបស់លោកប្តីខ្ញុំ គាត់ហ៊ឹងត្រចៀក ហើយកូនចៅដើរដឹកដៃយូរអីមិនកើតទេ គាត់ស្លាប់អីអត់ឮទេ។ ហើយអ្នកដែលរបួសដែលចេញពីភ្នំពេញហ្នឹង បងជីដូនមួយគ្រួសារខ្ញុំ ពេលគេផ្តោងពីថ្ងៃ ពីថ្ងៃ១៧ហ្នឹង គាត់ដាច់ជើង មានរបួសជើងទៅ។ គេដឹកកង់ ប្តីគាត់ដឹកកង់ឡើង។ កូនមួយក្តៅមួយហ្នឹងដឹកកង់ ហើយចាស់ហ្នឹងដើរដឹកដៃទៀត។ ហើយចំណែកគ្រួសារខ្ញុំ ឪពុកខ្ញុំគាត់ជ្រែងទប់ម៉ូតូ ទប់អី ចេះតែខំដើរទៅ អាយុជាង៦០ទេ។ ដល់តែអ៊ំនោះជាង៧០ លំបាកណាស់។

[១១:៣២:០០]

ហើយមនុស្សផ្សេងទៀតក៏មកជួប ចង់ដើរជាមួយដែរ ដែលគាត់វង្វេងគ្នីគ្នាដែរ មកចង់ដើរនឹង

គ្រួសារខ្ញុំដែរ ពីព្រោះស្គាល់។ ស្គាល់អ្នកដែលមកពីបឹងកេងកង ដែលម្ដាយក្មេកខ្ញុំរត់ទៅហ្នឹង។ យាយហ្នឹងដើរមកឡើកអីចឹងទៅ មកជួបខ្ញុំទៅ បានទៅជាមួយគ្នា។ ដល់តែយូរបន្តិចទៅទៀត បាត់យាយហ្នឹងមិនដឹងគាត់វង្វេងទៅណា ថាខ្ញុំអត់អាចមើលគាត់ឃើញទេ រកគាត់មិនឃើញទេ។

**ស៖** លោកស្រីថា នៅពេលដែលធ្វើដំណើរមានមនុស្សចាស់ ក៏ដូចជាកុមារស្ត្រី ក៏ដូចជាមានអ្នកជំងឺ។ តើនៅពេលដែលពួកគេទាំងនោះត្រូវការសេវាព្យាបាល ដូចជាថ្នាំពេទ្យ ឬថ្នាំសង្កូវអីផ្សេងៗ តើខាងខ្មែរក្រហម គាត់មានបានផ្ដល់អីគ្រប់គ្រាន់ទៅឲ្យពួកគាត់ដែរឬទេ?

[១១:៣២:៥៧]

**ឆ៖** ខ្ញុំអត់មានឃើញពួកអ្នកយកចិត្តទុកដាក់ដោយឲ្យថ្នាំមកអ្នកឈឺ ឲ្យថ្នាំមកអ្នកចាស់អីទេ អត់ឃើញទេនៅតាមផ្លូវហ្នឹង។ ដល់តែខ្ញុំមកប្រហែលជាដល់កោះក្របី មិនដល់ទេ ខ្ញុំអត់ចាំច្បាស់ទេ ទឹកព្រោះដើរវាយឺតដែរ វាមិនមែនដើរលឿនទេ មកគេងមួយកន្លែងទៀត។ ដល់គេងមួយកន្លែងទៀត អាហ្នឹងបានគេងនៅជាប់នឹងខ្មោចដែលគេគ្រប តែយើងអត់ស្អុយ យើងស្មានតែគេគ្របអីវ៉ាន់ យើងគេងជាប់នៅហ្នឹង។ ដល់ព្រឹកឡើង យើងទាញអាកន្ទេលហ្នឹងមក បានឃើញខ្មោចនៅហ្នឹង បានយើងភ័យ យើងទាញកន្ទេលចង់យកទៅគេង ពីព្រោះយើងអត់យកកន្ទេលតាមខ្លួន យកតែកំណាត់ ដូចកម្រាលពួកកម្រាលអីទន់ៗហ្នឹងតាមខ្លួនពេលហ្នឹង ព្រោះថា ២, ៣ថ្ងៃអត់ៗដឹកកន្ទេលបានទេ ពួកគ្រួសារខ្ញុំហ្នឹង។ ដឹកតែអង្ករ ដឹកតែរបស់របរបន្តិចបន្តួច កន្ត្រកអីហ្នឹង។ ហើយចង់យកកន្ទេលហ្នឹងមក ឃើញខ្មោចនៅហ្នឹង។ ដូច្នេះនាំគ្នាភ័យ ដើរគេចពីត្រង់ហ្នឹងតទៅទៀតទៅ។

[១១:៣៤:០៥]

**ស៖** បើតាមការរៀបរាប់របស់លោកស្រី លោកស្រីធ្វើដំណើរចេញពីទីក្រុងភ្នំពេញ គឺលោកស្រីមានការស្នាក់នៅជាច្រើនកន្លែង។ តើនៅពេលដែលស្រីធ្វើដំណើរ លោកស្រីមានឃើញសាកសពដែលដេកស្លាប់នៅរប៉ាត់រប៉ាយតាមផ្លូវ ឬក៏ឃើញមានការសម្លាប់នៅតាមផ្លូវដែរឬទេ?

**ឆ៖** ចាស ជម្រាបលោកប្រធាន កំណាត់មនុស្សដែលគេកាត់កដាក់នៅតាមផ្លូវ ហើយមិនស្អុយគឺនៅកំណាត់ផ្លូវពីស្វាយរលំ ទៅខាងសិត្បូ។ ផ្លូវហ្នឹងពេលដែលខ្ញុំឆ្លង រកវិធីឆ្លងទូកហ្នឹងមកខាងត្រើយខាងតាខ្មៅវិញ បានខ្ញុំឃើញមនុស្ស។ ប្រហែលជាទាហានហើយ ពីព្រោះគាត់ស្លៀកខោកាគី យើងមើលឃើញពីចម្ងាយ ឃើញគាត់សម្រាន្តនៅក្បាលផ្លូវអីចឹង អត់មានក្បាល យើងស្លុតណាស់ៗ ឱបកូនរត់វាងទៅ ខ្ញុំឃើញកន្លែងហ្នឹង គឺមនុស្សម្នាក់ហ្នឹង គេកាត់ក្បាលចេញហើយចាស។

**ស៖** បើតាមការមើលឃើញរបស់អ្នកស្រី តើអ្នកដែលគេកាត់ក្បាលហ្នឹង តើគាត់ជាៗប្រជាពលរដ្ឋធម្មតា ឬក៏ជាអ្នកធ្វើការនៅក្នុងសម័យ លន់ នល់?

**ឆ៖** ចាសខ្ញុំ តាមខ្ញុំសន្និដ្ឋានគឺជាអ្នកធ្វើរាជការ ឬក៏ប៉ូលិស ឬក៏ទាហានក៏មិនដឹងដែរ ពីព្រោះខោហ្នឹង ខោកាគីជើងខ្លី ត្រឹមក្បាលជង្គង់ រាងគាត់ធាត់ៗស្លីងអីចឹង ប៉ុន្តែអត់ស្គុយទេ។ ខ្ញុំរត់រាងហ្នឹងរាងផង ធ្មេចភ្នែកទៅ ខ្ញុំអត់ស្គុយទេ។ ប្រហែលជាមនុស្សនៅថ្មីៗទេ ជាៗអ្នកធ្វើការងារហើយ។ បើប្រជាជនអត់ស្លៀកអីចឹងទេ។

[១១:៣៦:១៧]

**ស៖** លោកស្រីបានឆ្លើយពីខាងលើអម្បាញ់មិញថា នៅពេលដែលជម្លៀសចេញពីទីក្រុងភ្នំពេញគ្រួសារលោកស្រី ក៏ដូចជាលោកស្រីផ្ទាល់ ហើយក៏ដូចជាប្រជាពលរដ្ឋផ្សេងៗបាននាំយកនូវអីវ៉ាន់មួយចំនួនទៅតាមខ្លួន។ តើនៅពេលដែលលោកស្រីនាំយកអីវ៉ាន់ទៅនោះ តើខ្មែរក្រហមមានបានដកហូតយកអីវ៉ាន់លោកស្រីនៅតាមផ្លូវដែរឬទេ?

**ឆ៖** ពេលជម្លៀសចេញ ដើរកំពុងតាមផ្លូវហ្នឹង ពីព្រោះយើងក៏លាក់ដែរ មាសពេជ្រអីយើងលាក់នៅក្នុងស្បោង អ៊ូ! ក្នុងបាវយើងហើយ អត់ៗមានអ្នកណាមកយកទេ មាសពេជ្រហ្នឹង។ ប៉ុន្តែដល់ពេលយើងទៅដល់ទិសដៅ ដែលដល់ថា ដល់ខេត្តតាកែវហ្នឹង បានគេស្នើម៉ាញៀៗដែលស្តាប់សំឡេងវ៉ាដ្យូអីហ្នឹងយកចេញពីយើង។ យើងអត់ហ៊ានថា អត់ឲ្យគេទេ។ គេថាយកទៅប្រើ អង្គការត្រូវការចាស។ ហើយយើងគ្រាន់តែអស់ខោអាវ អស់លុយ អស់ពេជ្រអីហ្នឹង បន្តិចបន្តួច ដើម្បីដូរឆ្លងទូកគេនោះទេ។ អត់មានអ្នកណាមកដកហូតទេ ដើម្បីឆ្លងទឹកឲ្យវាផុតពីកន្លែងលំបាកខ្លាំង នឹកឃើញថាខាងតាខ្មៅវាស្រួលដើរជាង ក៏ឆ្លងទូកមក មិនចេះធ្វើក្បូន មិនចេះធ្វើអី ហែលកាត់ទន្លេហ្នឹងទេ។ ទន្លេហ្នឹងជ្រៅណាស់ដែរ ខ្ញុំអត់ចេះ គ្រួសារក៏អត់ចេះ ដូច្នេះរកទូកគេឆ្លង។ គេយកពេជ្រ យកមាសយើងបានដោយសារឈ្នួលឆ្លងទូក។ តែប៉ុណ្ណឹង។

**ស៖** ជាចុងក្រោយ តើលោកស្រីទៅដល់ទិសដៅចុងក្រោយ តើលោកស្រីទៅដល់ខេត្តណាដែរ?

[១១:៣៨:២០]

**ឆ៖** ចាស ទិសដៅដល់ចុងក្រោយ គឺខ្ញុំចេញទៅដល់ស្រុកបាទី ចេញទៅក្នុងដីស្រែនៅខាងបាទីគេហៅភូមិថ្នល់ដាច់។ ទៅដល់ហ្នឹងខ្ញុំត្រូវឈប់សម្រាក ពីព្រោះដល់លោកឪពុកក្មេកខ្ញុំគាត់អ្នកស្រុកខាងតាកែវហ្នឹងផង –គាត់ៗខាងស្រុកកំពង់ស្ពឺទេ ប៉ុន្តែខាងតាកែវហ្នឹងមានក្មួយគាត់– អីចឹងគាត់ក៏ឈប់

នៅក្នុងស្រុកហ្នឹង។ ពីព្រោះក្មួយហ្នឹងឃាត់ នឹកថា ឪពុកមាមកដល់ហើយ នៅហ្នឹងហើយវាស្រួល វាអីក៏នៅទីហ្នឹងសិនទៅ។ ហើយដល់មួយគ្រួសារដែលនៅខាងកំពង់ស្ពឺ ស្អែកឡើងគាត់ត្រឡប់ អ៎! គាត់ទៅកំពង់ស្ពឺឆ្លងផ្លូវជាតិលេខ៣ ទៅស្រុកគាត់មួយទៀត។ ហ្នឹងអ្នកដែលត្រូវរបួសជើងហ្នឹង គាត់ទៅនៅហ្នឹង។ គាត់ត្រឡប់ទៅស្រុកកំណើតផ្ទះគាត់ដែលគេទម្លាក់គ្រាប់បែកងាប់កូនងាប់ចៅ តែគាត់ទៅផ្ទះគាត់ហ្នឹងវិញ។ ចំណែកខ្ញុំ ឪពុកក្មេក ហើយនិងគ្រួសារខ្ញុំចូលនៅក្នុងភូមិថ្នល់ដាច់ ហៅឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ។

[១១:៣៩:៣០]

**ស៖** សំណួរមួយទៀតទាក់ទងទៅនឹងការធ្វើដំណើរផងដែរ។ នៅពេលដែលលោកស្រីធ្វើដំណើរពីភ្នំពេញរហូតដល់ខេត្តតាកែវ តើលោកស្រីបានឃើញវត្តអារាម ក៏ដូចជាកន្លែងសក្ការៈបូជាផ្សេងៗត្រូវបានវាយបំផ្លាញ ឬក៏មានលោកស្នាក់នៅក្នុងវត្តដែរឬទេ?

**ឆ៖** ពេលខ្ញុំដើរមកដល់កន្លែងមួយ ខ្ញុំមិនសូវជាស្គាល់ភូមិសាស្ត្រខាងខេត្តតាកែវទេអង្កាល់ហ្នឹង ខ្ញុំមក មកតាមឪពុកក្មេកខ្ញុំ ហើយគាត់ថា ចូលតាមវត្តស្លាវ៉ូមទៅ ប៉ុន្តែយប់ ដល់យើងដើរយប់ហ្នឹង អត់ដឹងថាមានលោក គ្មានលោកទេ។ ខ្ញុំអត់បានកាត់ចូលក្នុងវត្តហ្នឹងទេ។ តែដល់តែទៅដល់ស្រុកបាទី អ៎! នៅថ្នល់ដាច់នោះ ក៏មានវត្តប្រាសាទស្រះកែវក៏ខ្ញុំអត់បានចូលក្នុងវត្តហ្នឹងដែរ មិនដឹងជាមានលោក ឬអត់ទេ តែស្ងាត់ណាស់ អត់ដែលឃើញលោកណាដើមមក ពណ៌ក្រហមអីទេ អត់មានទេ។ អត់ឃើញលោកទ្រង់បាត្រទេ។

**ស៖** នៅពេលដែលលោកស្រីទៅដល់ខេត្តតាកែវ តើលោកស្រីត្រូវបានគេទទួលជាមនុស្សថ្មី ឬក៏ជាមនុស្សចាស់នៅទីនោះ?

[១១:៤០:៥១]

**ឆ៖** ពេលខ្ញុំមកដល់ភូមិថ្នល់ដាច់ ស្រុកបាទី ខេត្តតាកែវហ្នឹង ទីរួមខេត្តគេនៅឆ្ងាយឯណោះទេ។ យើងនៅក្នុងស្រុកបាទីនៅឡើយ ហើយខ្ញុំនៅក្នុងជួបជុំមីងអ៊ំបងជីដូនមួយអីអ៊ីចឹង ក៏រស់នៅក្នុងផ្ទះរបស់គេហ្នឹង គេអត់ទាន់មានកន្លែងអីឲ្យយើងនៅទេ។ យើងនៅជាមួយគ្រួសារដែលស្គាល់ៗហ្នឹងចាស។ មិនដឹងជាគេទុកជាចាស់ជាថ្មីទេ ប៉ុន្តែយើងមកដល់ថ្មីមានអ្នកត្រាំខ្នារត្រាំអីហ្នឹងក៏គេមកដល់ហ្នឹងដែរ។ ចេះតែរស់នៅផ្ទះជាមួយអ្នកមូលដ្ឋានចាស់ហ្នឹងទៅ។ ដល់យូរមកទៀត បានគេបំបែកចេញចាស។

**ស៖** នៅពេលដែលលោកស្រីទៅដល់ខេត្តតាកែវ ស្រុកបាទីហ្នឹង តើខ្មែរក្រហម ខាងខ្មែរ

ក្រហមមានបានធ្វើប្រវត្តិរូបលោកស្រីទេ?

**ឆ៖** ខ្ញុំដូចជាភ្លេច មិនដឹងជាគេមកកត់ ប៉ុន្តែប្រវត្តិរូបខ្ញុំច្បាស់ជាគេដឹងហើយ ពីព្រោះទៅសាច់ញាតិបងប្អូនអីចឹង ដឹងថា អានាងធ្វើគ្រូ ខ្ញុំធ្វើគ្រូអីអីចឹង ដឹងក្នុងគ្រួសារដែលយើងនៅហ្នឹង។ ក្នុងគ្រួសារដឹង ហើយមេកងមេអី ប្រហែលជាគេមកកត់ៗហើយ ព្រោះក្រោយមក ទៅធ្វើសន្និបាតអីគេហៅអ្នកថ្មីហ្នឹងទៅ។

[១១:៤២:២៧]

គេកត់ដឹងប៉ុន្មានដងទេ។ មានកត់ដែរចាស ប៉ុន្តែដូចដាក់ធ្វើគ្រូឡើយ ខ្ញុំប្រាប់ថានៅធ្វើគ្រូអីចឹងយើងមិនប៊ានលាក់ទេ។ ចាស ខ្ញុំអត់ប៊ានលាក់ទេ។

**សៈ** មួយទៀតទាក់ទងនឹងការរស់នៅរបស់លោកស្រី តើលោកស្រីនៅស្រុកបាទី ខេត្តតាកែវហ្នឹងអស់រយៈពេលប៉ុន្មានថ្ងៃ? ប៉ុន្មានឆ្នាំដែរ?

**ឆ៖** ខ្ញុំនៅយូរដែរ ប្រហែលជាៗ ៣, ៤ ខែ ឬក៏ ៥ខែ ខ្ញុំមិនច្បាស់ ខ្ញុំអត់បានរាប់ថ្ងៃទេ ពីព្រោះការងារហ្នឹងចេះតែធ្វើរហូតអត់មានទំនេរ ម្តងគេឲ្យទៅទូលដី ម្តងគេឲ្យ -- ប៉ុន្តែ ម្តងគេឲ្យដើរកាប់ស្លឹកឈើ ម្តងទូល ដូចថា ម្តងគេរៀបផ្ទះឲ្យបែកពីគ្រួសារគេ។ រៀបដោយឡែកទេ វាមិនរៀបជាក្រុមទេ។ ដូចថា ខ្ញុំហ្នឹងត្រូវបែកពីគ្រួសារបងប្អូនហ្នឹងមកនៅផ្សេង ហើយគ្រួសារចិនៗ គេទៅនៅអីណាទៀត។ អ្នកខ្លះទៅត្រាំខ្នារទៅអីបន្តទៀត មិនមែនមកដល់ភ្លាមស្តុបទុកនៅក្នុងហ្នឹងភ្លាមទេ គឺថានៅមានសិទ្ធិទៅរកផ្ទះស្រុកកំណើតខ្លួន។ អ្នកដែលមកចូលគេងជាមួយយើងផ្ទះបងប្អូនហ្នឹង មានរួចទៅព្រឹកឡើងអាប៊ាមួយហ្នឹងទៅណោះទៅ បងមួយទៅកំពង់ស្ពឺទៅ ម៉្លោះហើយពួកខ្ញុំហ្នឹងកំពុងតែរៀបរយ គេថា អ្នក! ធ្វើនេះធ្វើនោះអី តែចេះទៅធ្វើតាមគេទៅ គេឲ្យទៅមើលគេចិញ្ចឹមនាង គេបង្ហាញរបៀបបូតស្ពៃ បូតអាស្លឹកអីមកឲ្យទុកដង្កូវស៊ីហ្នឹង ហើយនិងទូលអាចម៍គោជាច្រើន។ ដែលទូលអាចម៍គោយកដីទៅចាកស្រែហ្នឹង។ ចាស ការងារហ្នឹង។ ចំណែកគ្រួសារជាស្វាមីហ្នឹងគេយកទៅនៅភ្នំតាម៉ៅអី ឬក៏ទៅភ្នំណាឮតែគេទៅក្រាំងតាចាន់ៗអីហ្នឹង ខ្ញុំក៏អត់ស្គាល់ដែរ។ អត់សួរយកចិត្តទុកដាក់ ដឹងតែគាត់ទៅផ្សេងពីខ្ញុំហើយ។

[១១:៤៤:៣៥]

**សៈ** ក្រៅពីលោកស្រីរស់នៅខេត្តតាកែវ តើលោកស្រីមានបាន ត្រូវគេជម្លៀសទៅខេត្តណាផ្សេងទៀតទេ?

**ឆ៖** ចាស ប្រាកដជាទៅ គឺជម្លៀសម្តងទៀត។ ចាំមើល៍ ទៅក្នុងភូមិហ្នឹង គ្រាន់តែផ្លាស់លំនៅវាបីដង ចេញពីអ្នកមូលដ្ឋានចាស់ហ្នឹង និងបងប្អូននឹងទៅនៅផ្ទះមួយរោងទៅ ធ្វើថ្មីឲ្យ រោងហ្នឹង អង្គការគេធ្វើឲ្យ។ ក្រោយមកទៀត គេបានប្រហែលជា១ខែ ២ខែ ហ្នឹង គេទៅឲ្យនៅ ឃើញដីមួយកន្លែងហ្នឹងនៅភូមិត្រពាំងអង្គហ្នឹង គឺនៅគេផ្តុំបញ្ញាជន ពេទ្យ ស្ត្រីដែលធ្វើការមានប្រាក់ខែហ្នឹង ឲ្យទៅនៅខាងភូមិត្រពាំងអង្គ ប៉ុន្តែមិនមែននៅក្នុងភូមិគេទេ គឺលើដីទទេតែម្តង។ ដីហ្នឹង គេសងខ្ទមៗវែងៗជាប់គ្នា ដូចជានេះអ៊ីចឹង មួយច្រកៗម្នាក់នៅ ហើយចិន ហើយអ្នកស្រែអីដែលរត់មក មិនដឹងគេ *គ្រុបប៉េ* ឲ្យទៅឯណាគ្រាន់តែថា បំបែកគ្នាហើយពេលហ្នឹង គេបំបែកគ្នា។ ចិន នៅក្រុមចិនទៅ រួចទាហានដែលមានទាហានមានប៉ូលិសដែលចេញពីភ្នំពេញ នៅក្នុងផ្ទះមូលដ្ឋាន ពេលហ្នឹង ខ្ញុំអត់ដឹងគេទៅនៅឯណាទេ។ ស្រាប់តែវាអស់ លែងមានៗនៅជាមួយអ្នកមូលដ្ឋានហើយ អ្នកអស់ហ្នុំង មិនដឹងទៅណា។

[១១:៤៦:០៥]

**ស៖** លោកស្រីថា មានការជម្លៀសលើកទី២ តើជម្លៀសលោកស្រីទៅខាងណាដែរ? ហើយនៅពេលណាដែរ?

**ឆ៖** សូមទោស មើល៍ប្រហែលជាខែ មិនទាន់ធ្លាក់ភ្លៀងទេកាលហ្នឹង ខ្ញុំទៅហ្នឹង មិនទាន់ភ្លៀងខ្លាំងទេ។ ប្រហែលជាខែៗកក្កដា មួយ ប្រហែលជាខែកក្កដា សីហា អីហ្នឹង។ ហ្នឹងគឺចេញហើយចេញពីៗភូមិត្រពាំងអង្គហ្នឹង ចេញទៅ ទៅអត់ប្រាប់ថា ទៅណាទេ ដំបូងឡើងថា ឲ្យរៀបអីវ៉ាន់ ប្តូរភូមិថ្មី។ ដល់អ៊ីចឹង ពេលប្តូរលើកទី១ ឡានមកជូនទៅៗៗ ខ្ញុំ បងប្អូនរត់នាំគេចមិនឲ្យទៅទេ គាត់ភ័យ គេយកទៅធ្វើបាបអីទៀត គាត់មិនឲ្យទៅទេ លើកទី១។ ដល់១ខែមកទៀត ដំណឹងហ្នឹងត្រូវបញ្ជូនអាអ្នកដែលនៅសល់ហ្នឹងទៅទៀត បានខ្ញុំទៅ គេចលែងរួច។ យកទៅខាង យកទៅដល់ពោធិ៍សាត់។ ចាសសូមទោស។ យកទៅ ទៅដល់ អាលើកទី២ហ្នឹង ពួកខ្ញុំហ្នឹងទៅ ឡានគេជូនទៅហ្នឹង ទៅខាងខេត្តពោធិ៍សាត់ ទៅដល់ពោធិ៍សាត់យប់ ចុះទៅ ចាស។

**ស៖** លោកស្រីថា មានការជម្លៀសលើកទី២ តើលោកស្រីមានបានដឹងថា តើប្រជាជនប្រភេទណាមួយ ដែលគេត្រូវមានការជម្លៀសពីលើកទី២នេះ ទៅខេត្តពោធិ៍សាត់ហ្នឹង?

[១១:៤៧:៥៩]

**ឆ៖** ពេលខ្ញុំទៅដល់ខេត្តពោធិ៍សាត់យប់ហើយ ហើយឃើញតែស្នាមធ្យូង ស្នាមដាំបាយអី នៅពេញមាត់ស្ទឹងហ្នឹង ហើយយើងក៏មិនដឹងជាមនុស្សមកពីណាខ្លះដែរ ព្រោះក្រុមដែលខ្ញុំទៅហ្នឹង សុទ្ធតែ

ក្រុមពីត្រពាំងអង្គហ្នឹង សុទ្ធតែមន្ត្រីធ្វើពេទ្យ ធ្វើវិស្វករអី កម្មករអី ខ្ញុំ គ្រូបង្រៀនអីហ្នឹងទៅហើយ មួយភូមិក្រៅត្រពាំងអង្គហ្នឹង ជាប់នឹងភូមិត្រពាំងអង្គហ្នឹង គឺពួកខ្ញុំ។ ពីពេលនៅក្នុងនេះ នៅក្នុងភូមិ -- ពេលចេញមុនដំណើរហ្នឹង មានមនុស្សជាច្រើន មកពីគ្រប់ទិស មកភូមិប្រាសាទហ្នឹងដែរ មិនដឹងជាមកពីក្រាំងលាវ ឬក៏មកពីណាទេ ប៉ុន្តែភូមិត្រពាំងអង្គខ្ញុំ ត្រូវចេញអស់ហើយពេលហ្នឹង។ ត្រពាំងអង្គខ្ញុំត្រូវចេញមកតាកែវ អ៎! វត្តប្រាសាទហ្នឹង ចាំជិះឡាន បានទៅពោធិ៍សាត់ហ្នឹង។ ដល់ទៅដល់ពោធិ៍សាត់ ក៏ដាំបាយនៅពោធិ៍សាត់ យើងអត់ដឹងទិសថាគេឲ្យយើងទៅណាទេ នៅត្រឹមពោធិ៍សាត់។ ចាស ដល់យប់ឡើងដាំបាយញាំអី ស្អែកឡើង បានដឹងទិសមួយទៀត។ ទិសហ្នឹង គឺជិះរថភ្លើងទៅវិញ។ វែកអីវ៉ាន់ វែកអី កូនចៅហ្នឹងទៅ ទៅខាងលិចជិះរថភ្លើងចេញទៅ ចាស។

[១១:៤៩:២៦]

**ស៖** នៅក្នុងដំណាក់កាលជម្លៀសជាលើកទី២ ចេញពីស្រុកបាទី ខេត្តតាកែវ តើលោកស្រីធ្វើដំណើរដោយមធ្យោបាយអីដែរ?

**ឆ៖** ចាស សូមជម្រាប ខ្ញុំជិះឡានកាមីញ៉ុង ៗ ហ្សេអឹមសេ ប៉ុន្តែអត់មានកៅអី អត់មានអីទេ ដូចទ័ពអ៊ីចឹង គឺថាក្តារនៅក្តារហ្នឹង ចេះតែលើកដាក់ លើកបោះៗៗ កំប៉ិកកំប៉ុកបន្តិចបន្តួចរៀងៗខ្លួនហ្នឹង ប៉ុន្តែគេហៅឲ្យយើងឡើងឡានណា បានឡើងឡានហ្នឹង គេមានឈ្មោះបញ្ជីគេហៅពីតាកែវ អ៎!ពីប្រាសាទ ពីវត្តប្រាសាទហ្នឹង ហៅឡើងៗៗទៅ ឡាននេះ។ ហៅឡើងទៅ ឡាននោះ ហើយអីវ៉ាន់ហ្នឹងដាក់ទៅតាមខ្លួនខ្លះក៏មានប៉ោតច្រើន ប៉ោត ធុង អីបន្តិចបន្តួចដែរទៅតាមខ្លួនហ្នឹង ប៉ុន្តែកាំបិតអីគេមិនឲ្យយើងយកទេ។ បើឃើញហ្នឹង គេទុកហើយ។ គេថានៅណោះមានអីវ៉ាន់ប្រើអស់ហើយ។

**ស៖** នៅលើរថយន្តដែលលោកស្រី ក៏ដូចជាក្រុមគ្រួសារលោកស្រី ឬមួយក៏ប្រជាពលរដ្ឋជិះនោះ តើលោកស្រីមានបានឃើញយោធា ឬក៏ទាហានខ្មែរក្រហមនៅលើរថយន្តនោះដែរឬទេ?

**ឆ៖** ចាស ខ្ញុំបានឃើញអ្នកបើកឡាន ហើយនិងគ្នាគេអង្គុយខាងមុខ ស្លៀកពាក់ខោអាវខ្មៅៗដែរ។ ជាអ្នកដឹកជញ្ជូនហ្នឹង ប៉ុន្តែរបៀបខ្មៅ មិនដឹងជាគេជាទ័ពឬក៏ជាអី ខ្ញុំអត់ដឹងដែរចាស។ ខ្ញុំអង្គុយមួយកំណាត់ក្រោយ អាឡានហ្នឹងមានមួយកំណាត់មុខ ក្នុងកាប៊ីនគេហ្នឹង គឺគេជិះ អ្នកបើកឡាន ហើយអ្នកយោធាហ្នឹង អ៎! អ្នកធ្វើការជាមួយគេហ្នឹង។

[១១:៥១:២៥]

**ស៖** នៅពេលដែលធ្វើដំណើរចេញពីខេត្តតាកែវទៅដល់ពោធិសាត់ តើលោកស្រីមានបានឃើញ

ព្រឹត្តិការណ៍កើតឡើងដូចជាទាក់ទងនឹងមានការសម្លាប់ ឬក៏មានការធ្វើទារុណកម្មទៅលើប្រជាពលរដ្ឋដែលត្រូវបានជម្លៀសក្នុងដំណាក់កាលទី២ ដែរឬទេ?

**ឆ៖** ចាស សូមទោស សូមមាន លោកប្រធានឱ្យសួរសំណួរសាជាថ្មី។ តើត្រង់តាមផ្លូវ ឬក៏ពេលទៅដល់កន្លែងជម្លៀសទៅដល់នោះ? សូមមេត្តាតាំងសំណួរម្តងទៀត ខ្ញុំដូចស្តាប់មិនទាន់។

**ស៖** នៅពេលដែលលោកស្រីធ្វើដំណើរពីខេត្តតាកែវ ស្រុកបាទីទៅដល់ខេត្តពោធិសាត់ នៅតាមផ្លូវនោះ តើលោកស្រីមានបានឃើញមានការសម្លាប់ប្រជាជនដែលត្រូវបានជម្លៀសនៅក្នុងដំណាក់កាលលើកទី២ ដែរឬទេ? នៅតាមផ្លូវ?

**ឆ៖** តាម -- ចាស សូមជម្រាប នៅតាមផ្លូវដែលពេលខ្ញុំជិះ កាំមីញ៉ុង ហ្នឹង គឺខ្ញុំអត់បានឃើញមានមនុស្សអីស្លាប់តាមផ្លូវទេ គ្រាន់តែផ្លូវវាអាក្រក់ វាគ្រហិកគ្រហុកសុទ្ធតែស្នាមក្រហេងក្រហូងហ្នឹងវាលំបាកតែប៉ុណ្ណឹង។ ហើយដល់ពេលមកដល់ឡើងរទេះភ្លើងមកទៀត មិនទាន់ទៅដល់អាទីតាំងនៅទេមកដល់ឡើងរទេះភ្លើង ខ្ញុំឮគេបាញ់ផ្ទូងៗនៅខាងក្រោមរថភ្លើងហ្នឹង ហើយគេប្រាប់ថាមានមនុស្សរត់។ ហ្នឹងនៅដំណាក់កាលទី២ ដែលជម្លៀសហ្នឹង គឺវាមានពីរ ជិះកាំមីញ៉ុង ហើយនិងជិះរទេះភ្លើង។ ពេលជិះ កាំមីញ៉ុង ហ្នឹងអត់មានឃើញខ្មោចអីទេ គ្រាន់តែឃើញអ្នកឈឺ អ្នករាក ៗ នៅលើឡានហ្នឹង ធុំក្លិនហើយ។

[១១:៥៣:២៨]

**ស៖** លោកស្រីថា នៅពេលដែលជម្លៀស នៅក្នុងដំណាក់កាលទី២ លោកស្រីឃើញមានអ្នកជំងឺ ក៏ដូចជាមានការរាករូស។ តើនៅពេលដែលឃើញរបៀបនេះ តើខ្មែរក្រហម ជាពិសេសទាហានខ្មែរក្រហមដែលទៅជាមួយលោកស្រីក៏ដូចជាខ្មែរក្រហមផ្សេងៗទៀត មានការយកចិត្តទុកដាក់ទៅលើអ្នកជំងឺទាំងនោះដែរឬទេនៅពេលនោះ?

**ឆ៖** ចាស គេអត់បានឡើងមកអើតមើលអាកំណាត់ក្រោយដែលយើងអ្នកថ្មីជិះហ្នឹងទេ គេនៅតែអង្គុយក្នុងកាប៊ីនគេហ្នឹង។ គេអត់មានមកមើលថាអ្នកណារាក អ្នកណាឃ្លានអីយ៉ាងម៉េច អត់អីទេ អត់មាននិយាយអីជាមួយយើងទេ។

**ស៖** អ៊ីចឹងនៅពេលដែលមិនមានៗការយកចិត្តទុកដាក់ ក៏ដូចជាមិនមានការផ្តល់ជាសេវាសុខភាពអីផ្សេងៗ តើអ្នកទាំងនោះមានស្ថានភាពបែបណាដែរ នៅពេលដែលធ្វើដំណើរហ្នឹង?

[១១:៥៤:៤៥]

**ឆ៖** នៅពេលធ្វើដំណើរនុ៎ង គឺមិនមានអ្នកណាសប្បាយទេ មុខក្រៀមក្រំ ហើយអត់ជជែកគ្នាអីឲ្យឮទៅអ្នកណាៗទេ អ្នកណាមានបាយក៏គេញុំានៅក្នុងឡានហ្នឹងទៅ ទាំងចង្អៀតហ្នឹង។ ខ្ញុំ កូនហ្នឹងខ្ញុំមានមួយដុំៗហុចឲ្យកូនទៅ។ អង្រឹងខ្ញុំចងនៅលើដំបូលឡានកាមីញ៉ុង ដើម្បីឲ្យកូនខ្ញុំគេង ព្រោះខ្ញុំបីអត់កើត វារលាក់ពេក វារលាក់កូនហ្នឹងខ្លាំងពេក។ កូនខ្ញុំក៏មិនស្រួលដែរសុខភាព។ ដល់អីចឹង យើងហុចឲ្យកូនញុំា តែយើងនេះវាអត់មានប៉ានញុំាទេ។ ញុំាលាក់ កុំឲ្យតែវាដួល កុំឲ្យថាអីតែប៉ុណ្ណឹង។ ឡានបើកលឿន គេអត់ឈប់វាយើងនៅញុំាបាយណា។

**ស៖** នៅក្នុងរថយន្តកាមីញ៉ុងខាងក្រោយ លោកស្រីបានឆ្លើយពីខាងលើថា យើងឃើញមានអ្នកបើកបរពាក់អាវឈុតខ្មៅ។ នៅខាងក្រោយតើមានយោធា ឬក៏ខ្មែរក្រហមណាមួយអង្គុយជាមួយប្រជាពលរដ្ឋនៅខាងក្រោយឡានកាមីញ៉ុង ដែរឬទេ?

**ឆ៖** ចាស អត់មានទេ សុទ្ធតែអ្នកថ្មីទាំងអស់។

[១១:៥៦:០៣]

**ស៖** បើតាមលោកស្រីរៀបរាប់ខាងលើ លោកស្រីថា លោកស្រីមានកូនបីនាក់ ហើយម្នាក់ហ្នឹងស្លាប់នៅក្នុងរបបខ្មែរក្រហម។ តើកូនលោកស្រីស្លាប់ហ្នឹង ស្លាប់នៅក្នុងដំណាក់កាលជម្លៀសលើកទី១ ឬក៏ក្នុងដំណាក់ជម្លៀសលើកទី២?

**ឆ៖** ចាស ជម្រាបត្រង់ហ្នឹងអំមិញ ខ្ញុំដូចជាឆ្លើយជាមួយលោកប្រធានថា ខ្ញុំមានកូនបី ពេលដែលខ្ញុំដែលពេលរ៉ឺត្រែតពេលសព្វថ្ងៃហ្នឹង កូនខ្ញុំទាំងអស់វាបី តែមួយហ្នឹងវាកើតក្រោយទេ។ វាកើតក្រោយ យើងរំដោះរួចទេ។ ដូច្នេះ ខ្ញុំឥឡូវវាមានស្ថានភាពពេល -- បើលោកមានប្រសាសន៍សួរថាមានកូនប៉ុន្មានក្នុងសម័យនោះ? អាហ្នឹង គឺខ្ញុំជម្រាបពីរ។ ប៉ុន្តែលោកប្រធានថា លោកស្រីមានកូនប៉ុន្មាន? ខ្ញុំថាបី ពីព្រោះវាមានមួយទៀតក្រោយនេះ។ ដូច្នេះនៅពេលកំពុងជម្លៀសហ្នឹង ខ្ញុំមានកូនតែពីរទេលោក កូនស្រីពីរ។ មួយធំ មួយតូច។ ចាស សូមទោស។

[១១:៥៧:១៥]

**ស៖** ចុះកូនលោកស្រីដែលស្លាប់ ស្លាប់នៅក្នុងសម័យខ្មែរក្រហម ឬមួយក្រោយសម័យខ្មែរក្រហមនេះហើយ?

**ឆ៖** ចាស កូនខ្ញុំស្លាប់ សម័យខ្មែរក្រហមអាកូនស្រីទីពីរហ្នឹង សម័យខ្មែរក្រហមពេលជម្លៀសលើកទី២ទៅដល់ខាងបាត់ដំបងហ្នឹង ចាស។

**ស៖** កូនស្រីរបស់លោកស្រីស្លាប់ តើមូលហេតុអីបានជាកូនស្រីរបស់លោកស្រីស្លាប់? ដោយសារហេតុអី?

**ឆ៖** កូនស្រីស្លាប់ដោយសារអត់មានអីញ៉ាំបរិបូរណ៍ ហើមបន្តិចម្តងៗ រាកបន្តិចម្តងៗ ហើមរាកៗ ហើយនិងអត់មានជីវភាពអាហារហ្នឹង គ្មានថ្នាំសង្កូវ។ ដល់ឆ្នាំ៧៦ បានកូនស្លាប់ ៧៦។

[១១:៥៨:២០]

**ស៖** បាទ សំណួរជាចុងក្រោយរបស់ខ្ញុំ ខ្ញុំចង់សួរជម្រាបសួរលោកស្រីថា តាំងពីរបបខ្មែរក្រហម លោកស្រីមានផលលំបាកអ្វីខ្លះ ហើយការលំបាករបស់លោកស្រីហ្នឹង តើវាមានអីខ្លះរហូតដល់មកទល់បច្ចុប្បន្ននេះ ចំពោះការលំបាក ក៏ដូចជាការរងទុក្ខវេទនារបស់លោកស្រីនោះ?

**ឆ៖** ចាស ជម្រាបការលំបាកហ្នឹងមានតាំងពីថ្ងៃចេញពីភ្នំពេញ។ លំបាកផ្លូវកាយ លំបាកផ្លូវចិត្ត បាត់ម៉ែ បាត់ប្អូន បាត់មិត្តភក្តិបែកខ្ញែកគ្នា រកទីពឹងអ្នកណាក៏គ្មាន ហើយមកជួបជុំនៅក្នុងភូមិថ្មល់ដាច់ហ្នឹងបានជួបញាតិសន្តានខ្លះក៏គេបំបែកទៅមួយសាទៀត។ ដូច្នេះវាលំបាកផ្លូវចិត្ត លំបាកផ្លូវកាយកាន់តែធ្ងន់ទៅៗ។ វាឆ្ងាយពីស្រុកហើយ រកនិយាយក៏មិនកើត ដល់ទៅនៅស្រុកខេត្តបាត់ដំបង គឺធ្ងន់ណាស់ធ្ងន់រហូតដល់មិនដឹងស្គាល់អ្នកណា ទៅនៅក្នុងព្រៃ ទឹកលិច គ្មានសម្ភារៈប្រើប្រាស់ គ្មានម្ហូបអាហារ គ្មានថ្នាំសង្កូវ គ្មានជម្រក។ កាប់ៗឫស្សី កាប់ឈើយកមកធ្វើគាំងគងអីហ្នឹង ធ្វើរោង ធ្វើអីហ្នឹង គឺអត់បាន អត់មានលទ្ធភាពម្តង។ ដូចនៅដៃតែម្តង គ្មានអ្វីញ៉ាំ គ្មានអ្វីស្គាល់ គ្មានស្គាល់របៀប ដូចថាគ្មានស្គាល់មនុស្សណាជាទីពឹងទាំងអស់។ សុទ្ធតែអ្នកអត់ដូចគ្នា អ៊ីចឹងវាលំបាកទៅៗ គេស្លាប់ដូចយើង យើងស្លាប់ដូចគេ យើងឈឺដូចគេ។ តែខ្ញុំអត់ទាន់ស្លាប់ទេ ពេលទៅដល់នៅក្នុងព្រៃហ្នឹង។

[១២:០០:១០]

ដល់ក្រោយមកទៀតបានកូនស្លាប់ ឪពុកស្លាប់ ប្អូនស្លាប់។ នៅពេលដំណាក់កាលទី២នេះ គឺថាធ្ងន់នៅខេត្តបាត់ដំបងហ្នឹង លំបាកផ្លូវកាយ លំបាកផ្លូវចិត្ត លំបាកនឹងការរស់ដោយអត់ឃ្លានហ្នឹង គឺមហាអត់ អត់រហូតដល់វង្វេងវង្វាន់ណ៎ះ គេហៅវង្វេងវង្វាន់ ញ៉ាំសត្វព្រៃ។ ញ៉ាំសត្វម្រើមព្រះ គេប្រាប់ថា ម្រើមព្រះហ្នឹងញ៉ាំបាន យកមកដុត ខំចាប់ ទោះបីខ្លាចយ៉ាងណាក៏ដោយ ខំចាប់ដុតឲ្យកូន។ ដល់ដុតទៅ វាមិនមែនជាសត្វដែលគេស៊ី គេញ៉ាំទេ គឺជាសំបក ដុតទៅនៅតែសំបក សាច់អត់មាន ហើយនិងបោះចោលអស់ទៅទៀតទៅ អត់ដឹងញ៉ាំអីដូចស្វាអ៊ីចឹង ដូចថារើសអានេះមកញ៉ាំមិនកើត រើសអានោះមកញ៉ាំមិនកើត។ ហើយនៅក្នុងព្រៃហ្នឹងសូម្បីតែស្លឹកថ្នឹងហ្នឹងវាបែរផ្អែមតែម្តង អត់ជូរទេទៀត។

ហើយហ៊ឹងអស់ហើយត្រចៀក មើលឃើញមនុស្សដូចមុខដូចខ្មោចអ៊ីចឹង ទាំងខ្ញុំទាំងគេ ប៉ុន្តែអត់មានកញ្ចក់មើលមុខខ្លួនឯងទេ។ អត់ថ្នាំ អត់អ្វីទាំងអស់។ ពិបាកជាងគេនៅក្នុងព្រៃនុំង ដល់មកដល់ភូមិអត់មានអ្វីហូបទៀត សេរីភាពគ្មានចាស។

[១២:០១:៣២]

**ស៖** ចុះរហូតដល់បច្ចុប្បន្ន តើលោកស្រីនៅមានការលំបាក ឬក៏មានការឈឺចាប់ ដែលជាឥទ្ធិពលនៃរបបខ្មែរក្រហមនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សំណួរនេះ យើង អង្គជំនុំជម្រះទុកឲ្យដើមបណ្ដឹងរដ្ឋប្បវេណីថ្លែងរៀបរាប់ខាងក្រោយ។ លោកអាចតាំងសំណួរពាក់ព័ន្ធនឹងអង្គហេតុ ដែលគាត់បានដឹងផ្ទាល់នៅក្នុងព្រឹត្តិការណ៍ដែលគាត់ជួបប្រទះនៅក្នុងអំឡុងជម្លៀសទី១ និងទី២។ មិនបាច់ឆ្លើយតបទេនឹងសំណួរហ្នឹង! ទុកឱកាសថ្លែងរៀបរាប់ចុងក្រោយ។ យើងបានជម្រាបជូនរួចហើយ ដោយយើងខ្លាចមានការភ័ន្តច្រឡំពីបញ្ហានេះ ទើបយើងប្រាប់អំពីសិទ្ធិរបស់គាត់ ឲ្យត្រៀមខ្លួន ដើម្បីធ្វើសេចក្ដីថ្លែងរៀបរាប់ចុងក្រោយ។

**លោក សំ សុគង់៖**

បាទ សូមអរគុណលោកប្រធាន។ ហើយខ្ញុំអស់សំណួរត្រឹមប៉ុណ្ណេះហើយ។ ហើយសហភាតាខ្ញុំនឹងគាត់មានសំណួរបន្ត។ ហើយខ្ញុំសូមអរគុណលោកស្រី ទឹង សុខា ដែលបានព្យាយាមឆ្លើយនឹងសំណួរដែលខ្ញុំបានដាក់ទៅ។ ហើយសូមឲ្យលោកស្រីសុខភាពល្អ។ សូមអរគុណ។

[១២:០២:៤៥]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ! ១០មីនុតទៀត។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ដូច្នេះ ខ្ញុំសូមចាប់ផ្ដើម ហើយនឹងបញ្ចប់នៅរសៀលនេះ។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** ជម្រាបសួរលោកស្រី ទឹង សុខា ខ្ញុំនឹងសួរសំណួរបន្ថែមមួយចំនួនទៀត គឺជាសំណួរដើម្បីបញ្ជាក់ទៅលើចំណុចមួយចំនួនដែលលោកស្រីបានលើកឡើងរួចមកហើយជាមួយសហភាតារបស់ខ្ញុំ។ បន្ទាប់មកទៀត ខ្ញុំនឹងសួរពាក់ព័ន្ធទៅនឹងព័ត៌មានថ្មីៗផ្សេងៗទៀត។ លោកស្រីបានបញ្ជាក់ថា លោកស្រី

រស់នៅទីក្រុងភ្នំពេញ ហើយរស់នៅក្នុងផ្ទះមួយ។ លោកស្រីមានកូនស្រីពីរនាក់ តើលោកស្រីអាចបញ្ជាក់អំពីអាយុរបស់កូនលោកស្រីបានទេ នៅមុនថ្ងៃទី១៧ មេសា នៅពេលដែលលោកស្រីនៅទីក្រុងភ្នំពេញ?

**លោកស្រី ទឹង សុខា៖**

**ឆ៖** សូមជម្រាបថា កូនស្រីធំរបស់ខ្ញុំអាយុ ៦ឆ្នាំ។ កូនស្រីទី២ អាយុ ៣ឆ្នាំ។

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំប្រហែលជាខ្វះព័ត៌មាន។ ដូច្នេះខ្ញុំចង់ឲ្យលោកស្រីបញ្ជាក់ឲ្យបានច្បាស់អំពីមុខរបររបស់លោកស្រី នៅពេលដែលលោកស្រីនៅទីក្រុងភ្នំពេញ ហើយនិងមុខរបររបស់ប្ដីលោកស្រី។

**ឆ៖** ចាស មុខរបររបស់គ្រួសារខ្ញុំគឺ ប្ដីខ្ញុំនៅភ្នំពេញគាត់ជាសាស្ត្រាចារ្យខាងគណិតវិទ្យា។ ចំណែកខ្ញុំជាគ្រូបង្រៀន ពីមុនមក ប៉ុន្តែដល់មកឆ្នាំ៧៣, ៧៤, ៧៥ ហ្នឹង គឺខ្ញុំជានិស្សិតសាស្ត្រាចារ្យដែរនៅសាកលវិទ្យាល័យគរុកោសល្យភ្នំពេញកំពុងតែរៀនច្បាប់ ចាស។

[១២:០៥:០៩]

**ស៖** សូមអរគុណ។ លោកស្រីបានឆ្លើយថា មានមនុស្សស្លៀកខោអាវខ្មៅមកជួបលោកស្រីនៅផ្ទះ ហើយប្រាប់ឲ្យចាកចេញពីផ្ទះ ដោយប្រាប់ថា ចេញទៅតែ៣ថ្ងៃទេ។ តើនៅពេលគេមកប្រាប់នោះលោកស្រីមានឮគេប្រើពាក្យថា“អង្គការ”ទេ? ពេលដែលអ្នកស្លៀកពាក់ខ្មៅមកប្រាប់ឲ្យចាកចេញនោះ។

**ឆ៖** ខ្ញុំអត់បានឮពាក្យ “អង្គការ” ទេ គ្រាន់តែគេថា ញាតិញោមចេញទៅ៣ថ្ងៃទៀត បានមកវិញ ពីព្រោះកុំឲ្យមានខ្មាំង កុំឲ្យអី គេត្រួតពិនិត្យខ្មាំងឲ្យអស់សិន។ អត់មានប្រាប់ថា ខ្លួនគេអង្គការទេ គ្រាន់តែឃើញថា ខ្លួនគេហ្នឹងជាអ្នកអត់មានលីកាំភ្លើងវែងទេ ប៉ុន្តែមានកាំភ្លើងខ្លី។ ហើយបង់-ក ក្រមាអីចឹង ពួកម្លូក ជាអ្នកទ្រើសហើយ គាត់ជាអ្នកគ្រាន់បើហើយចាស ពីរបីនាក់ហ្នឹងដើរមក។

[១២:០៦:៣០]

**ស៖** ហើយគេប្រាប់ថា ឲ្យចាកចេញពីទីក្រុងដើម្បីពិនិត្យមើលថា មានខ្មាំង ឬក៏អត់។ តើគេមានប្រាប់ពីមូលហេតុផ្សេងទៀតទេ ថាចេញទៅហ្នឹងដោយសារអ្វីទេ?

**ឆ៖** ចាស អត់មានពន្យល់អំពីមូលហេតុអី គឺមានតែខ្មាំងមួយមុខហ្នឹងទេ។ រួចដល់យើងឮខ្មាំងបង្កប់អីអីចឹងទៀត យើងវាមិនចង់ឲ្យច្រឡូកច្រឡំជាមួយគេមានខ្មាំង មានសត្រូវអី យើងក៏ចេះតែស្ដាប់តាមគេអីចឹងទៅ អត់ដឹង អត់បានសួរគេវិញផង មិនដឹងសួរថាម៉េច និយាយទៅវាមិនយល់សាច់ការ។ ស្រាប់តែថា ឲ្យចេញទៅកុំឲ្យមានភ័យ កុំភ័យ ញោម៣ថ្ងៃទៀតសុខហើយអីចឹង។ ហើយគេនិយាយ

ទាំងសើចទៀតណោះ យើងក៏អត់មានចាប់អារម្មណ៍អី ភ័យអីនៅឡើយដែរ។ ភ័យអីខ្លាំង ប៉ុន្តែគ្រាន់តែវាអន្ទះអន្ទែងចិត្ត ត្រង់អត់ដឹងម៉ែនៅឯណា បងនៅឯណា ប្អូននៅឯណាទេ។ ដល់ឲ្យចេញអ៊ីចឹងយើងអល់អែកអត់ចង់ចេញទេ ចង់គេងនៅយប់ហ្នឹងទៀត ប៉ុន្តែដល់ព្រលប់ម៉ោងប្រហែលប្រាំហ្នឹង ប្តីខ្ញុំមកពីរកមិត្តភក្តិវិញ ក៏អត់ឃើញ។ គាត់ផ្លៀតទៅរកមិត្តភក្តិនៅទួលទំពូង ហើយដល់គាត់មកវិញគាត់ថាគេចេញបាត់ហើយ អត់មានអ្នកណាទេ។ អ៊ីចឹងយើងត្រូវចាំបាច់រៀបអីវ៉ាន់តាមគេអ៊ីចឹងដែរ ព្រោះគេចេញមកទាំងគ្រឹកៗ អ៊ីចឹងមក។ ខ្លាចគេគប់មកយើង គេថាយើងជាមនុស្សមិនចេញតាមបញ្ជាគេ យើងត្រូវតែចេញមក។

[១២:០៨:១១]

**ស៖** ដូច្នេះ តើលោកស្រីមានគិតទេ ថាលោកស្រីថា ៣ថ្ងៃក្រោយមកនោះអាចត្រឡប់មកវិញបាននោះ ពេលគេប្រាប់អ៊ីចឹងលោកជឿគេទេ? មានគិតថា តើអាចមកបានឬមិនបានទេ?

**ឆ៖** យើងព្រោះតែយើងមិនដឹងថា ព្រោះតែយើងនៅជឿគេខ្លះហើយ បានជាយើងខំរៀបអីវ៉ាន់ចេញហើយនៅ *ព្រែកណោ* ដើរយឺតៗមិនចង់ទៅឆ្ងាយពីភ្នំពេញទេ នៅក្បែរៗភ្នំពេញហ្នឹង គេចទៅណោះគេងមួយយប់ត្រង់ណោះទៅ។ វាហត់ផង ក៏ចេះតែសម្រាកចាំដល់ថ្ងៃ គ្រប់៣ថ្ងៃយើងបានមកផ្ទះយើងវិញហើយ។ បានជាយើងអត់មានដឹងជាគិតយ៉ាងម៉េចទេ មួយភ្លែតហ្នឹង គឺថាវាដូចៗជាមិនដឹងយល់ថាម៉េច អត់យល់ គ្មានអ្នកណាពន្យល់ហេតុ ពន្យល់ផលអីទេ។

[១២:០៩:១៣]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។ ឥឡូវនេះដល់ពេលសម្រាកដែរ ពីព្រោះ ឌីវីឌី អស់ហើយមិនអាចបន្តសវនាការទៀតបានទេ។ ដូច្នេះអង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការព្រឹកនេះត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅរសៀលនេះ ចាប់ផ្តើមវេលាម៉ោងមួយនិងសាមសិបនាទី។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅក្នុងអំឡុងពេលសម្រាកពិសាអាហារថ្ងៃត្រង់នៅបន្ទប់សម្រាកសម្រាប់សាក្សីនិងអ្នកជំនាញ ដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញ នៅវេលាម៉ោងមួយសាមសិបនាទីរសៀល។

សូមអញ្ជើញលោកមេធាវី!

**លោក ហ្សាស្តើ ប៉ោះ**

សូមអរគុណលោកប្រធាន។ កូនក្តីរបស់ខ្ញុំលោក នួន ជា គាត់មានជំងឺឈឺក្បាល ឈឺខ្នងមិនអាចផ្តង់អារម្មណ៍បាន ហើយគាត់ស្នើសុំអនុញ្ញាតតាមដានកិច្ចដំណើរការនីតិវិធីពីបន្ទប់ឃុំខ្លួនខាងក្រោម។ ហើយយើងបានរៀបចំនូវលិខិតលះបង់សិទ្ធិហ្នឹងដាក់ជូនទៅអង្គជំនុំជម្រះ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបានស្តាប់សំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ ដោយមានបញ្ហាមូលហេតុសុខភាព មិនអាចអង្គុយតាមដានផ្ទាល់នូវកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះបាន។

អង្គជំនុំជម្រះយល់ឃើញថា សំណើសុំនេះ មានលក្ខណៈសមស្រប អង្គជំនុំជម្រះសម្រេចយល់និងអនុញ្ញាតឲ្យលោក នួន ជា ទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយ ស្ថិតនៅក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលធ្វើសវនាការពេញមួយរសៀលថ្ងៃនេះ។ ដោយលោក នួន ជា លះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ ក្នុងកិច្ចដំណើរការសវនាការនៅក្នុងបន្ទប់សវនាការនេះ។

[១២:១១:១៤]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តីលោក នួន ជា ប្រគល់ជូនមកអង្គជំនុំជម្រះនូវពាក្យសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃជាក់ច្បាស់របស់លោក នួន ជា។

បង្គាប់ឲ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទរូបនេះ អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមសាលសវនាការនេះ សម្រាប់រយៈនៃកិច្ចដំណើរការសវនាការនៅរសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក នួន ជា និងលោក ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យលោក នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ ដោយឡែក

លោក ខៀវ សំផន ឲ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ ឲ្យបានមុនម៉ោងមួយសាមសិបនាទី។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១២:១២ នាទី ដល់ម៉ោង ១៣:៣៩ នាទី)*

[១៣:៣៩:៤២]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារ -- នាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកស្រីកាលពីព្រឹកមិញនេះ យើងបានឈប់សម្រាកនៅពេលដែលលោកស្រីនិយាយថា នៅពេលដែលលោកស្រីចេញពីភ្នំពេញនោះ លោកស្រីគិតថាអាចត្រឡប់មកវិញបាន គឺថាលោកស្រីគិតថា លោកស្រីអាចជឿបានទៅលើសម្តីរបស់ខ្មែរក្រហម។ ដូច្នេះមានន័យថា លោកស្រីទុកចិត្តខ្មែរក្រហមបន្តិចបន្តួចដែរ តើមែនទេនៅពេលនោះ?

[១៣:៤០:៤៥]

**លោកស្រី ទឹង សុខា៖**

**ឆ៖** ចាស ខ្ញុំគិតថា ចប់សង្គ្រាមហើយ ម៉េចម៉ាក៏គេឲ្យយើងបានសេចក្តីសុខនៅដូចពីមុនវិញហើយអ៊ីចឹងណ៎ា។ ខ្ញុំយល់ថាវាសុខសន្តិភាពអស់ហើយ វាអស់សង្គ្រាម អស់ច្បាំងគ្នានៅតែមួយចំហៀងអ៊ីចឹង ខ្ញុំនឹងអាចបានវិលចូលឆាប់វិញ។ ខ្ញុំជឿអ៊ីចឹង ពីដំបូងមកចាស។ ចាស សូមជម្រាបសាជាថ្មី អំមិញ ខ្ញុំនិយាយ -- ចាស សូមទោស កាលដែលពេលគេឲ្យចេញមកដំបូងហ្នឹង ពីរបីបួនថ្ងៃហ្នឹងនៅអល់អែក។ អល់អែកព្រោះយើងជឿថាសង្គ្រាមកាលណាចប់អ៊ីចឹង គង់តែបានសុខត្រឡប់ទៅ

ផ្ទះវិញទេ ឬមួយក៏គេមើលខ្លាំងមែនយ៉ាងម៉េច យើងជឿគេ ដូចថាជឿនៅក្នុងៗតាមពាក្យគេប្រាប់ហ្នឹង ចាស។ ដល់អ៊ីចឹងចេញមកទាំងអស់គ្នាអ៊ីចឹងទៅ នៅជឿគេតើ នៅដំបូង នៅជឿអ៊ីចឹង ថានឹងចប់ហើយ គេរកខ្មាំងទេ គិតអ៊ីចឹងណាលោក ចាស។

[១៣:៤១:៥៤]

**ស៖** សូមអរគុណ។ លោកស្រីចាកចេញទៅដោយដើរ ឬក៏តាមរថយន្ត ពេលដែលលោកស្រីចាកចេញជាមួយគ្រួសារ ជាមួយនឹងបងប្អូន កូនប្ដីហ្នឹង?

**ឆ៖** ចាស អត់ -- ចាស មិនមែនមានរថយន្តទេ គឺបណ្ដើរម៉ូតូមួយម្នាក់ៗ អ្នកខ្លះឌុបកង់ ឌុបអ៊ីចឹងមក។ ក្រុមគ្រួសារខ្ញុំហ្នឹងចេញមកជិះម៉ូតូថ្មើរជើង តែមិនមានជិះបានទេ គឺដើររហូតអ៊ីចឹង រហូតទៅដល់ភូមិថ្នល់ដាច់ហ្នឹងចាស។ ភូមិថ្នល់ដាច់ ខេត្តតាកែវហ្នឹង។

**ស៖** តើការធ្វើដំណើរលើកដំបូងនៅពេលលោកទៅដល់ភូមិណាមួយ ដែលលោកស្រីនៅរយៈពេលប៉ុន្មានសប្ដាហ៍នោះ តើត្រូវការចំណាយពេលអស់ប៉ុន្មានដែរ ពេញចេញពីភ្នំពេញទៅដល់ភូមិមួយនុ៎ង?

**ឆ៖** ចាស ខ្ញុំរាប់ទៅ យើងដើរដំបូង វាយឺតៗ ហើយក្រោយមកឆ្លងទន្លេទៀត មកឈប់ខាងតាខ្មៅ រួចហួសច្រឡំផ្លូវទៅខាងព្រែកតូចនោះទៀត ព្រោះវាដឹងទិសណា ដូចថាវាទៅតាមគ្នា វាមិនច្បាស់លាស់អ៊ីចឹង ទៅដល់ព្រែកតូច ទៅដល់ព្រែកតូច គេងនៅនុ៎ង១យប់ ២យប់ទៅបានរកផ្លូវបត់ថយមកក្រោយវិញ។ ដូច្នេះ ឈប់ហ្នឹងជាច្រើនពេលដែរ មកដល់ខាងផ្លូវលេខ២វិញ មកដល់ខាង គេហៅវត្តអង្គសីង្ហហ្នឹងក៏គេងនៅហ្នឹងទៀត រកម្ហូបរកអាហារអីបន្តដំណើរទៅទៀត។ ដល់អ៊ីចឹងបានទម្រាំបានទៅដល់ភូមិថ្នល់ដាច់ ខ្ញុំគិតថាជារយៈពេល១១ថ្ងៃ ចាស ១១ថ្ងៃ ១១យប់ ទាំងដើរ ទាំងដេក ទាំងគេង ទាំងអែអង់ចាស។ ចាំស្ដាប់ដំណឹង ចាំរកបងប្អូនដែលបែកនោះ ព្រោះអ្នកស្រុកនៅហ្នឹងជាមួយគ្នាក្រែងលោគាត់ឃើញទៅនុ៎ងដែរ តែអត់ឃើញទេ។ ដល់អ៊ីចឹង អែអង់ហើយ ក្នុងដំណាក់កាលហ្នឹង គឺអែអង់ផ្លូវ មិនទាន់ចង់ទៅឲ្យផុតទេ ពីព្រោះម្ដាយក្មេង គាត់មុខជាទៅតាកែវហ្នឹងដែរ។ អ៊ីចឹងទៅម្ដាយឪពុកខ្ញុំហ្នឹង គាត់មិនធ្វើដំណើរលឿនណាស់ពេកទេ។ ហើយរកម្ហូប រកអាហារទៅ ឃើញថាជាង១០ថ្ងៃ ចាស។

[១៣:៤៤:២០]

**ស៖** នៅក្នុងពេលធ្វើដំណើរ១១ថ្ងៃ ១១យប់នេះ តើខ្មែរក្រហមមានបានផ្ដល់ទឹក ចំណីអាហារ

ការព្យាបាលថែទាំសុខភាពដល់លោកស្រី និងដល់ប្រជាជនផ្សេងទៀតដែរឬទេ?

**ឆ៖** ចាស អត់មានសោះតែម្តង។ អត់មាន ពួកខ្មែរក្រហមឲ្យអីទេ ឃើញតែគេបរឡានកាំមីញ៉ុង ពេលយប់មួយនោះ ឃើញគេបរឡានកាំមីញ៉ុងកាត់តាមមុខយើងអ៊ីចឹងដែរ តែអត់មានឲ្យស្អីទេ។

[១៣:៤៥:០១]

**ស៖** នៅពេលដែលលោកស្រីទៅដល់ភូមិដំបូងនោះ តើលោកស្រីអាចបញ្ជាក់អំពីឈ្មោះភូមិដែលនៅក្នុងស្រុកបាទីនោះបានឬទេ តើឈ្មោះអ្វីដែរភូមិហ្នឹង?

**ឆ៖** ចាស ជម្រាបប្រសាសន៍លោកប្រធាន។ ភូមិដែលទៅដល់ហ្នឹង គឺហៅថាភូមិថ្នល់ដាច់ដែលទៅដល់ឈប់នៅហ្នឹងតែម្តងហ្នឹង គឺភូមិថ្នល់ដាច់ ស្រុកក្រាំងលាវ -- មើល ភូមិថ្នល់ដាច់ ឃុំក្រាំងលាវ ស្រុកបាទី ខេត្តតាកែវ។

**ស៖** នៅទីនោះ តើលោកស្រីរស់នៅជាមួយអ្នកភូមិដែលគេរស់នៅតាំងពីយូរហើយ ឬក៏យ៉ាងម៉េច?

**ឆ៖** ចាស ន័ដំបូងហ្នឹងរស់នៅជាមួយបងប្អូនជីដូនមួយខាងស្វាមីខ្ញុំតែម្តង ផ្ទះចាស់គេ ផ្ទះគេមានផ្ទះធំ។ គាត់មានផ្ទះធំនៅក្នុងបឹងភូមិថ្នល់ដាច់ហ្នឹង ហើយយើងរស់នៅហ្នឹង ហើយមិនទាន់ដឹងថាអង្គការចាត់តាំងយើងធ្វើម៉េច គឺគ្រាន់តែជួបជុំបងប្អូនហ្នឹងអរ ត្រេកអរឲ្យនៅហ្នឹងទៅ ហើយមួយគ្រួសារទៀតដែលគាត់មានរបួសជើង បងគាត់បង្កើត បងលោកឪពុកក្មេកខ្ញុំបង្កើត គាត់ស្នែកឡើងគាត់ទៅខាងស្រុកសន្ទ្រាន កំពង់ស្ពឺ ខេត្តតាកែវ -- អ៊ូ!ខេត្តកំពង់ស្ពឺវិញ។ សន្ទ្រាន ភូមិស្រង់ហ្នឹង នៅសន្ទ្រានហ្នឹង ស្រុកគងពិសី ខេត្តកំពង់ស្ពឺហ្នឹង មួយគ្រួសារដែលទៅជាមួយគ្នាហ្នឹង។ គេបែក បែកពីត្រឹមថ្នល់ដាច់ហ្នឹងទៅ អាហ្នឹងគេទៅដល់ទីដៅគេ។ ព្រោះខ្ញុំអត់ដឹងទីដៅនៅឯណា ព្រោះផ្ទះនៅភ្នំពេញ។ អ៊ីចឹងនៅឈប់នៅថ្នល់ដាច់ហ្នឹងហើយ។ ចាំស៊ើបសួរប្រពន្ធគាត់ រកប្អូនដើម្បីជួបជុំគ្នានៅហ្នឹងចាស ខេត្តស្រុកនៅក្នុងខេត្តតាកែវ។

[១៣:៤៧:១១]

**ស៖** តើខ្មែរក្រហមមានបានដាក់ឈ្មោះជាក់លាក់ទៅដល់ប្រជាជននៅភូមិ ហើយនិងប្រជាជនដែលមកពីទីក្រុងទេ គេហៅយ៉ាងម៉េចដែរចំពោះប្រជាជនទាំងពីរហ្នឹង?

**ឆ៖** នៅហៅដូចមីអូន អាអូន បងប្អូនអ៊ីចឹង ដូចថាទៅវាជាស្រុកកំណើតដែលយើងបែកគ្នាយូរហើយ មកជួបជុំគ្នាវិញអ៊ីចឹង។ លោកពូនៅតែលោកពូអ៊ីចឹងទៅ។ អាអូននៅតែអូនអ៊ីចឹងទៅ។ ហៅគ្នាដូចគ្នាជានៅស្និទ្ធ នៅរាប់រកគ្នានៅឡើយទេ។

**ស៖** ខ្ញុំគិតថា ប្រហែលជាលោកស្រីមិនសូវយល់សំណួរខ្ញុំទេ។ ខ្ញុំចង់ដឹងថាតើខ្មែរក្រហមមានដាក់ឈ្មោះជាក់លាក់ណាមួយទៅឲ្យប្រជាជននៅភូមិ ហើយមានដាក់ឈ្មោះផ្សេងទៀតសម្រាប់ក្រុមប្រជាជនដែលចេញពីទីក្រុងមកនោះ គឺសំដៅដល់ក្រុមម្ដង។ ឧទាហរណ៍ថា ក្រុមមកពីភ្នំពេញ គេហៅប្រជាជនអី ក្រុមនៅភូមិហ្នឹងគេហៅប្រជាជនអី? ដែរមានឈ្មោះអ៊ីចឹងទេ?

**ឆ៖** ដូចជាមិនបានដាក់ឈ្មោះ ប៉ុន្តែគេដឹងថាពួក១៧ហើយអ្នកចេញមកហ្នឹង។ ព្រោះអ្នកចេញមកនៅហ្នឹង ១៧មេសា។ គេដាក់ឈ្មោះអ៊ីចឹង គេហៅយើងអ្នកថ្មី អ្នក១៧ហ្នឹង ចាស អ្នកមូលដ្ឋានហ្នឹងគេថាអ៊ីចឹង អ្នក១៧។

[១៣:៤៨:៥៣]

**ស៖** សូមអរគុណ។ តើមានការប្រព្រឹត្ត និងការរស់នៅខុសគ្នាទេ រវាងប្រជាជនមូលដ្ឋានហើយនិងប្រជាជន១៧មេសានោះ នៅក្នុងភូមិហ្នឹង ហើយនិងក្នុងភូមិបន្តបន្ទាប់ទៀតដែលលោកស្រីទៅរស់នៅនោះ?

**ឆ៖** ពេលដែលនាងខ្ញុំទៅរស់នៅហ្នឹង បងប្អូនដូចនៅចង់ -- នៅលួចឲ្យពងទាអីមួយ ពីរអីអ៊ីចឹងមក។ ជូនទៅសុំស្លរគាត់ ព្រោះអង្កាល់ហ្នឹងសម្បត្តិទ្រព្យអ្នកបងប្អូនហ្នឹង វាជាសម្បត្តិទ្រព្យផ្ទាល់ខ្លួនរបស់គាត់ មិនទាន់ដាក់រួមទេ។ ដូច្នេះ គាត់អាចរំលែក ចែករំលែកឲ្យយើង ស្រូវអីជារបស់ឯកជនរបស់គាត់ហ្នឹង គាត់មើលយើង យើងអត់អីអ៊ីចឹង យើងសុំបានទៅ យកទៅជាន់អីបន្តិចបន្តួចអ៊ីចឹងទៅ។ រួចបានក្រោយមក បានគេថាឲ្យទៅបើកអង្ករពីអង្គការអីអ៊ីចឹង បានក្រោយ១ខែ ២ខែអ៊ីចឹងទៀត បានៗគេចែកអាស្រូវអង្ករភោជន៍សំឡីហ្នឹង។ ចាស ដែលពេលគេបំបែកយើងចេញហើយ ចេញពីអ្នកមូលដ្ឋានហើយ អាហ្នឹងបានៗអង្ករគេចែក។ មុនដំបូងគឺយើងនៅញ៉ាំ មានអ្នកស្រុកជាផ្ទះផ្ទាល់ៗហ្នឹង អ្នកមូលដ្ឋានហ្នឹងគេដូចថាឧបត្ថម្ភគ្រួសារនេះប៉ុន្មានគ្រួសារ? អ្នកនេះទទួលខុសត្រូវប៉ុន្មានគ្រួសារអ៊ីចឹង? ហើយខ្ញុំហ្នឹងនៅក្នុងគ្រួសារបងប្អូនជីមួយហ្នឹងចាស។

**ស៖** សូមអរគុណលោកស្រី។ បន្ទាប់មកទៀតលោកស្រីធ្វើដំណើរទៅភូមិមួយផ្សេងទៀត។ កាលពីព្រឹកមិញនោះ លោកស្រីបានប្រាប់ថា លោកស្រីបានទៅផ្ទះពិសេសសម្រាប់បញ្ញាជននៅក្បែរភូមិ

មួយ។ តើលោកស្រីអាចបញ្ជាក់អំពីឈ្មោះភូមិដែលលោកស្រីទៅរស់នៅនុំងបានទេ?

[១៣:៥០:៤៧]

**ឆ៖** ចាស ភូមិដែលខ្ញុំទៅនៅក្រោយគេមុននឹងចេញទៅខេត្តបាត់ដំបងហ្នឹងគឺគេហៅថា "ភូមិ - - គេឲ្យឈ្មោះថា ភូមិត្រពាំងអង្គ" ប៉ុន្តែយើងមិនមែននៅហ្នឹងភូមិត្រពាំងអង្គគឺគេធ្វើនៅលើតារាងដីដោយឡែក ប្រហែលជា ៥០ម៉ែត្រពីភូមិចាស់គេហ្នឹង។ គេកសាងផ្ទះស្លឹកត្នោត អត់មានគ្រែ អត់មានអីទេ។ អ្នកណារកផាងត្នោតអី យកមកក្រាលគេងក៏បានគេងទៅ អ្នកណាអត់ហ៊ីទៅហ្នឹង មិនដឹងជាគេគេងនៅនឹងដីហ្នឹងទេ អត់មានគ្រែ អត់មានអីទេ ចាស តែមានដំបូល ហើយនិងដីហ្នឹងឲ្យយើងនៅ។ ហ្នឹងទៅនៅត្រពាំងអង្គ ភូមិបញ្ញវន្ត គេឲ្យសុទ្ធតែអ្នកចេះដឹងឲ្យទៅនៅនុំងហើយ ដែលខ្ញុំហៅថា "ភូមិអ្នកចេះដឹង" ហ្នឹង។

**ស៖** តើខ្មែរក្រហមមានបានពន្យល់មូលហេតុទេ ថាហេតុអ្វីបានជាគេបញ្ជូនលោកស្រីទៅកន្លែងហ្នឹង? គេមានប្រាប់ទេ?

**ឆ៖** ចាស គេអត់មានប្រាប់ទេ ប៉ុន្តែអង្គាល់នៅភូមិថ្នល់ដាច់ គេកត់ៗឈ្មោះអ៊ីចឹង ប៉ុន្តែយើងក៏អត់ដឹងថាគេកត់ធ្វើអីដែរ។ គេចេះតែមកកត់អ៊ីចឹង អ្នកណាធ្វើអី អ្នកណារកអី អ្នកណាមកពីណា ស្រុកខេត្តអីណាគេកត់ ដល់ក្រោយមកបានមាន *គ្រុបប៉េ* អ៊ីចឹង មានផ្តុំជាអ្នកចេះដឹងមកនៅភូមិត្រពាំងអង្គហ្នឹងតែម្តងចាស។

[១៣:៥២:២៤]

**ស៖** លោកស្រីបានឆ្លើយថា "លោកស្រីត្រូវធ្វើការ" ដូច្នេះខ្ញុំចង់ដឹងថា តើលោកស្រីធ្វើការនៅជិតកន្លែងហ្នឹងតែម្តង ឬក៏ត្រូវធ្វើដំណើរទៅឆ្ងាយដើម្បីទៅធ្វើការ?

**ឆ៖** ចាស នៅក្នុងភូមិហ្នឹងធ្វើចម្ងាយប្រហែលជា ពីរគីឡូអីហ្នឹង យ៉ាងវែងណាស់ អត់ឆ្ងាយទេ យើងនៅដើរក្នុងស្រែ ក្នុងភូមិ ដាក់ជី រកស្លឹកធ្វើជី រែកដីខ្លះបណ្តើរៗអ៊ីចឹងទៅ កូនទុកផ្សេង។ កូនមកនៅឯក្នុងខ្ទមហ្នឹងហើយ យើងចេញទៅធ្វើការតាមតែគេប្រាប់ថា ឥឡូវដើររកសន្លឹកទន្ទ្រានខែត្រឲ្យបានអ៊ីចឹងយើងចេះតែខំដើរច្បិតពីណាពីណីយកមកឲ្យគេអ៊ីចឹង ហើយអត់ដឹងធ្វើអីដើររើសតែត្នោតអីហ្នឹងយកមកផ្សែផ្សំឲ្យកូនញ៉ាំទៅ ព្រោះវាគ្មានចំណីអីទេ។ អត់មានអ្នកណាចែកចំណីចំណុក ផ្លែចេក ផ្លែអីអត់មានទេ អត់មានសោះ។ អ៊ីចឹងយើងរត់តាមហ្នឹងអ៊ីចឹងទៅចាស។

[១៣:៥៣:៣៦]

**ស៖** នៅក្នុងកន្លែងពីដំបូងដែលលោកស្រីទៅធ្វើការ ឬក៏រស់នៅនេះ តើមានការប្រជុំសម្រាប់អ្នកមកពីទីក្រុងភ្នំពេញដែរឬទេ?

**ឆ៖** ចាស នៅដំណាក់កាលទី១ហ្នឹង ខ្ញុំបានទៅមីទ្ទិងហ្នឹង ២ដង គេប្រមូលមនុស្សទាំងអស់ដែលមកពីភ្នំពេញហ្នឹងទៅ ទី១នោះទៅភូមិកុមាររាជា តែទៅហ្នឹងដើរម៉ោងប្រាំទៅដើរទៅ កុមាររាជាហ្នឹងឆ្ងាយណាស់ ដើរប្រហែលជា១ម៉ោងកន្លះអី ២ម៉ោង ដើរយប់ព្រលប់ៗហ្នឹង គេឲ្យប្រជុំនៅកុមាររាជា។ ប្រជុំហ្នឹងគេ ពីនយោបាយរបស់គេដែរ ហើយដល់ខ្ញុំចាំជាងគេ គឺទី២ ប្រជុំនៅភូមិៗថ្មល់ដាច់តែម្ដងចាស។ ទី២ហ្នឹង មីទ្ទិងធំមួយ ព្រោះគេធ្វើបុណ្យ។ ចាស សូមជម្រាប។

[១៣:៥៤:៤៩]

**ស៖** គេ -- លោកស្រីថា គេនិយាយពីនយោបាយ តើគេនិយាយពីនយោបាយអ្វីដែរនៅពេលនុ៎ង?

**ឆ៖** ចាស នៅពេលហ្នឹងគឺគេនិយាយអំពីដូចថាអបអរសាទរ នឹងជោគជ័យ និងបានអ្នកភ្នំពេញហ្នឹងមក គេដូចថា គេក៏រីករាយដែរ។ ហើយគេក៏និយាយអំពីបរាជ័យរបស់ចក្រពត្តិពួក លន់ នល់ ហ្នឹងចាញ់ បាក់ អត់ឈ្នះបដិវត្តន៍ទេ បដិវត្តន៍ខ្លាំងញ៉ាំតែខ្លួង ញ៉ាំតែក្ដាមហ្នឹងក៏ឈ្នះដែរ។ ដូច្នេះ គេមានតែនិយាយអ៊ីចឹងទេ និយាយអួតសរសើរអំពីជោគជ័យហ្នឹងណ៎ះ! ដំបូងហ្នឹងចាស។ សូមទោសបន្ថែមបន្តិចទៀត ហើយនៅក្រោយមីទ្ទិងហ្នឹង គឺគេច្រៀងរាំរបាំឲ្យយើងមើលដែរ។ របាំហ្នឹងគឺក៏ជារបាំពាក់អាវខ្មៅទាំងអស់ សុទ្ធតែពួកអ្នកបដិវត្តន៍ទេ។ គាត់ចេញមករាំសប្បាយអី ដូចថាជាបែបចិនដែរ ឬបែបរបាំគេនុ៎ងសប្បាយដែរ។ រួចខ្ញុំអត់ទេ ថ្ងៃនុ៎ងខ្ញុំចាំអត់អស់ទេ ពីព្រោះភ័យ អារម្មណ៍ភ័យ ឯណាពកូនផង ឯណាកូនធំផង កូនតូចផង យប់ហ្នឹងខ្ញុំនៅចាំមើលទៅលើនុ៎ងអត់បានទេ ព្រោះមាននារីយោធាម្នាក់មកសួរខ្ញុំអំពីឈ្មោះ ខ្ញុំហ្នឹងតែម្ដង។ រកថា ខ្ញុំមានស្គាល់គ្រូទេ ឈ្មោះ ខ្ញុំហ្នឹងតែម្ដង ដល់អ៊ីចឹងខ្ញុំភ័យខ្លាំងពេក ខ្ញុំអត់បានចាប់អារម្មណ៍គេនិយាយអីតទៅទៀតទេ នៅលើឆាកល្ខោនហ្នឹង។

[១៣:៥៦:៤៨]

**ស៖** ហេតុអ្វីបានជាលោកស្រីខ្លាចទៅវិញ ពីព្រោះថានៅក្នុងពេលមីទ្ទិងនោះ លោកស្រីនិយាយថា ខ្មែរក្រហមរីករាយទទួលអ្នកដែលមកពីភ្នំពេញ ហើយបើអ៊ីចឹងម៉េចក៏លោកស្រីខ្លាច?

**ឆ៖** ពីព្រោះ -- ចាស ជាដំបូងរីករាយ ប៉ុន្តែដល់ចុងក្រោយនិយាយអំពីបរាជ័យរបស់ខ្មាំងអីអ៊ីចឹងទៅ ហើយអាខ្មាំងត្រូវតែចាញ់អី។ ខ្មាំងបង្កប់គេៗខំដូចថា ជម្រះជម្រួតអ្នកដែលជាខ្មាំងហ្នឹងណ៎ះ

គេរកដូចថា ឲ្យបានសុខ កុំឲ្យមានខ្លាំងហ្នឹង ហើយដល់យើងអ្នកនៅភ្នំពេញដែរ។ យើង ពេលគេចេញពីភ្នំពេញមក គេថាគេរកខ្មាំងដែរ ដល់អ៊ីចឹងយើងក៏ចាប់ៗអារម្មណ៍ ចាប់ចេះបារម្ភហើយពេលហ្នឹង។ អត់ទុកចិត្ត ទទួលមាននារីខ្មែរក្រហមហ្នឹងដើរមកសួរខ្ញុំអ៊ីចឹង ខ្ញុំក៏គាំងភ័យស្លុតទៅមិនដឹងនេះ មឹងមាំង ខ្ញុំលែងបានចាប់អារម្មណ៍ទៅលើការនិយាយនៅលើឆាកគេហើយ។ ខ្ញុំភ័យរកតែវិធីដោះស្រាយអត់បាន អ៎! អត់ចង់ចេញ។ ដោះកុំឲ្យគេចាប់កំហុស។

[១៣:៥៨:០៩]

**ស៖** ឥឡូវនេះ ខ្ញុំចង់ចូលទៅនិយាយអំពីការធ្វើដំណើរលើកទី២ វិញម្តង។ លោកស្រីនិយាយថា មុនពេលរដូវមូសុង ហើយលោកស្រីក៏មិនសូវបានចាំច្បាស់ដែរ។ តើគេមានប្រាប់មូលហេតុទេថា ហេតុអ្វីបានជាគេឲ្យលោកស្រីទៅកន្លែងទី២ នុ៎ង?

**ឆ៖** ជម្លៀសជាលើកទី២ សូមទោស ក្នុងពេលជម្លៀសជាលើកទី២? ចាស ឬយ៉ាងម៉េច? ព្រោះនៅក្នុងភូមិហ្នឹងវាប្តូរពីរបីដងដែរ ក្នុងអាភូមិទី១ហ្នឹង អាជម្លៀសពីភ្នំពេញ វាដូរ -- គេដូរ២-៣ដងដែរ។ ដូច្នេះជម្លៀសទី២ ដែលលោកស្រីចង់មានប្រសាសន៍សួរហ្នឹង គឺដើម្បីសួរអំពីការចេញដំណើរទៅបាត់ដំបងនោះ ឬក៏យ៉ាងម៉េច? សូមទោស សូមបញ្ជាក់។

**ស៖** ពិតហើយលោកស្រី គឺខ្ញុំចង់និយាយអំពីការជម្លៀសលើកទី២ នុ៎ងហើយ។ តើគេមានប្រាប់មូលហេតុទេថា ហេតុអីបានជាគេឲ្យលោកស្រីធ្វើដំណើរទៅកាន់កន្លែងទី២នុ៎ង?

[១៣:៥៩:១៧]

**ឆ៖** ចាស គេប្រជុំពេលល្ងាចមួយ គេថាឥឡូវពុកម៉ែត្រូវប្តូរថ្មី ភូមិថ្មីទៀត ពីព្រោះនៅកន្លែងផ្សេងទៀត មានអង្ករច្រើននៅភូមិយើងវាអត់ដឹងជញ្ជូនមកដល់ទេ។ ដូច្នេះឲ្យយើងទៅរកកន្លែងណាដែលមានអង្ករ។ អង្គការបញ្ជូនទៅនៅភូមិផ្សេងៗដែលមានអង្ករ មានអង្ករបរិបូណ៌ញ៉ាំ ពីព្រោះទីហ្នឹងវាអត់សម្បូរថា អ៊ីចឹងណ៎ះ។ អ៊ីចឹងគេម្នាក់ៗជឿទៀតហើយ ជឿបន្តទៀតទៅ ជឿបន្តអ៊ីចឹងក៏ត្រូវតែរៀបចំអីវ៉ាន់ទៅ។ រៀបចំអីវ៉ាន់តទៅរកកន្លែងដែលមានស្រូវ មានអង្ករ ព្រោះគេពិបាកដឹកយកមកឲ្យយើង។ យើងហ្នឹងក៏ទៅជាលើកទី ក្នុងជម្លៀសទី២ ហ្នឹងមានលើកទី១ ទៅមួយៗគេហៅថា មួយវគ្គ។ ហើយខ្ញុំ -- ពួកខ្ញុំហ្នឹង បងប្អូនហ្នឹង ជួយពង្រត់ទៅពូនមិនឲ្យទៅ ព្រោះបែបគាត់អល់អែកថា ប្រហែលជាមិនរស់ដែរទេ ទៅឆ្ងាយហ្នឹង ប្រហែលហើយ តែគេអត់និយាយប្រាប់យើងត្រង់ទេ អ្នកបងប្អូនហ្នឹងគេមកលួចកញ្ចក់អីវ៉ាន់យើង យកយើងឲ្យទៅពួននៅផ្ទះគេ ក្នុងគុម្ពចេក គុម្ពអីហ្នឹងទៅ។ អាឡានជំនាន់

មួយហ្នឹង ឡានទី១ហ្នឹង វាទៅអស់ហើយ ដល់បាន ក្រោយមកគេប្រមូល គេដើរមកប្រមូលហៅពួកខ្ញុំដែលកំពុងពួនហ្នឹង ហៅទៅវិញ ហៅទៅវត្តប្រាសាទហ្នឹងវិញ។ ដល់ទៅដល់វត្តប្រាសាទវិញ គេសួរថា ហេតុអីបានជាមិត្តឯងមិនទៅតាមអង្គការ។ សួរម្នាក់ម្ដងៗ ប៉ុន្តែអត់ចេះឆ្លើយទេ ដំបូង តែអ្នកបងប្អូនហ្នឹង លួចប្រាប់ ថា ឲ្យឆ្លើយថា “ព្រោះអង្គការតែមួយ ឲ្យនៅជាមួយគ្នាហ្នឹងទៅ ទៅណា ក៏អង្គការដូចតែគ្នាទេ”។ អ៊ីចឹង ឲ្យយើងទន្ទេញអ៊ីចឹង ខ្ញុំក៏ទៅដល់កន្លែងវត្តប្រាសាទ ជួបឃោធាគេហ្នឹង ខ្ញុំសូត្រអាហ្នឹងតាមគេ ប្អូនដប់មាត់ អ៊ីចឹងដែរ។ គេឲ្យយើងចេញមក ម្នាក់ទៀតចូលទៅ គេសួរអ៊ីចឹងទៀតចេញមកវិញទៀត។ ហើយក្រោយមក គេឲ្យយើងទៅភូមិចាស់វិញ ឲ្យទៅភូមិត្រពាំងអង្គហ្នឹងវិញ។ ទៅអាជំរំនៅក្បែរត្រពាំងអង្គហ្នឹងវិញ។ យើងក៏ទៅ។

[១៤:០១:២៥]

ដល់យើងទៅៗ បានគ្នាច្រើនដែរ មិនមែនតិចទេ អ្នកដែលរត់គេចៗ មិនព្រមទៅ អាជម្លៀសទី១ អ៊ំ! អានាំបញ្ជូនតាមឡានហ្នឹងទី១ ហ្នឹង។ អត់ព្រមទៅ បានប្រហែលជា២០, ៣០ អីទៅ ខ្ញុំរាប់មិនអស់ទេ គ្រួសារហ្នឹង ក្នុងល្វែងទាំងអស់ហ្នឹង ខ្ញុំអត់មានឱកាសដើរ ដឹងទេ មានតែកងគេទេ ដែលគេដឹង។ ខ្ញុំជាអ្នក១៧ ហ្នឹង អត់ដឹងចំនួនមនុស្សប៉ុន្មានទេ ប៉ុន្តែឃើញច្រើនដែរ នៅមានច្រើន ប្អូនដប់ម្ភៃសាមសិបអីក៏គ្រួសារទៅ។ បានខ្ញុំធ្វើ រស់នៅហ្នឹងទៀត ក្រោយមកស្រាប់គេថា មិនទាន់ -- ប្រហែល១ខែ ថាឲ្យជម្លៀសម្ដងទៀត ឲ្យទៅម្ដងទៀត។ អ៊ីចឹង ខ្ញុំត្រូវទៅអាលើកទី២ ខ្ញុំទៅលើកទី២ ក្នុងក្បួនឡានហ្នឹង អាលើកទី២ហ្នឹង គេចលែងបានហើយ គឺគ្មានអ្នកណាធានាឲ្យយើងទេ បងប្អូននៅស្រុកនុ៎ង ថាលែងប៉ានហើយ ពីព្រោះគេថា “ក្បាលអ្នកណា សក់អ្នកហ្នឹង” គេកសាងគាត់ដែរ កាលណាឃោគយល់បងប្អូនអ៊ីចឹង។ អ៊ីចឹងឲ្យប្អូនទៅៗ គាត់ឱបខ្ញុំយំអីអ៊ីចឹង ខ្ញុំក៏អត់មានក្រាញននៀលដែរ ខ្លាចគាត់មានទោសយើងក៏ត្រូវទៅឯណោះទៀត ក្រែងលោទៅឯណោះមានអ្វីញ៉ាំ។ ហើយដល់ខ្ញុំចេញផុតទៅទៀតទៅហើយអ្នកត្រឡប់មក មានអ្នកនៅពួនទៀត នៅក្នុងពេលចេញទី២ហ្នឹង ព្រោះខ្ញុំត្រឡប់មក៧៩ ខ្ញុំជួបលោកគ្រូមួយ គាត់ថា “អ្នកដែលក្រាញ់នៅមិនទៅហ្នឹង គេសម្លាប់អស់”។ អ្នកគ្រូ ពេលអ្នកគ្រូឯងចេញផុតទៅ គេសម្លាប់អស់។ មានតែខ្ញុំមួយទេ ដែលខ្ញុំរត់ចេញពីភូមិហ្នឹង ទៅខាង៥៥។ បានគាត់នៅគង់វង់ជីវិត អ្នកនៅសល់ហ្នឹង គេសម្លាប់។ ហើយកាលហ្នឹង គាត់និយាយអ៊ីចឹង លោកគ្រូហ្នឹង ឈ្មោះលោកទូច គាត់នៅធ្វើការភ្នំពេញហ្នឹងដែរ។ គាត់ថា គាត់រស់ម្នាក់ឯងទេ ពីព្រោះគេសម្លាប់អស់ហើយ។ គាត់ថា អ៊ីចឹង។ អ្នកគេចៗ មិនព្រមទៅមុខ។ មិនព្រមទៅតាមគេជម្លៀសហ្នឹង។ គាត់មានប្រសាសន៍អ៊ីចឹង

ហើយខ្ញុំក៏ឮតាមហ្នឹងទៅ ពីព្រោះ៧៩ទេ អានេះ ខ្ញុំឮពីមាត់គាត់។ ពីព្រោះធ្វើការនៅភ្នំពេញ ផ្ទះល្វែងគាត់ នៅជាប់ផ្ទះល្វែងខ្ញុំ។

[១៤:០៣:២៨]

ដល់ខ្ញុំសួរទៅ បានគាត់ប្រាប់ថា "អ្អូ! ខ្ញុំនៅត្រពាំងអង្គតើ ប៉ុន្តែលើកទី២ ដែលគេទៅហ្នឹង ខ្ញុំអត់ទៅ។ ដល់ខ្ញុំអត់ទៅ គេរកចាប់ រកអីអ៊ីចឹង"។ គាត់ដឹងគាត់មានបងប្អូនជួយខ្សឹបគាត់ ឲ្យទៅ ឲ្យរត់គៀសពីហ្នឹង។ បានអ្នកនៅនុ៎ង គេសម្លាប់មិនដឹងពួកណាទេ ខ្ញុំអត់ដឹង ចាស។

**ស៖** ខ្ញុំចង់ឲ្យយល់ច្បាស់ ដូច្នេះ ខ្ញុំយល់ថា គេឲ្យលោកស្រីទៅហ្នឹង នៅជិតបាត់ដំបងហ្នឹង ដោយសារមានស្រូវអង្ករច្រើន ហើយគេទៅលើកដំបូង ដែលលោកស្រីអត់ព្រមទៅទេ ព្រោះថាអ្នកភូមិនុ៎ង ជួយលាក់បំពួនអ្នកស្រី ចង់ឲ្យលោកស្រីនៅភូមិហ្នឹង។ បន្ទាប់មក គេរកលោកស្រីឃើញ គេយកទៅដាក់នៅវត្តមួយ ហើយបង្ខំឲ្យចេញទៅ។ អ្នកខ្លះលួចពួនទៅ ហើយខ្លះនុ៎ង ប្រហែលត្រូវបានគេសម្លាប់ចោល ហើយលើកក្រោយមក លោកស្រីក៏ត្រូវគេជម្លៀសចេញទៅ។ តើអ៊ីចឹង ត្រូវទេ អ្វីដែលខ្ញុំនិយាយនេះ?

[១៤:០៤:២៩]

**ឆ៖** ចាស មិនទាន់ត្រូវទេ លោកស្រីយល់ពាក្យសម្ដីខ្ញុំមិនទាន់ អាលើកដែលកុងវ័រឡានលើកទី១ហ្នឹង ដែលបងប្អូនមកចាប់យកអីវ៉ាន់ខ្ញុំជួយពង្រត់ទៅគេច ទៅពួន។ ខ្ញុំអត់មានអារម្មណ៍ថា នៅទេ ដល់វាបាត់អាប្រដាប់ដែលខ្ញុំទូលទៅ មួយមកកញ្ចក់យកទៅបាត់ ហើយអាមួយមកកញ្ចក់អង្រែកទៅបាត់ ខ្ញុំឡេឡឺ បានមានបងមួយមកប្រាប់ថា "ទៅណោះសិន ធ្វើស៊ីញ៉ូអ៊ីចឹង ក៏យើងទៅតាមគាត់"។ អ៊ីចឹង បានពួកខ្ញុំបានរួចពីអាកុងវ័រទី១ (សូមទោស) ឡានកាំមីញ៉ុងលើកទី១ហ្នឹង ខ្ញុំរួច។ តែដល់មកដល់ថ្ងៃម៉ោងមួយដណ្ដប់ពីរដណ្ដប់ឡានចេញចេញស្ងាត់ហើយ គេដើរប្រមូលអ្នករត់ហ្នឹងយកមកសួរម្ដងទៀតថា "ហេតុអីមិនទៅតាមទិសអង្គការ?" ដល់យើងឆ្លើយតាមវិធីគេទៅ ក៏យើងរួចខ្លួនវិញ។ គេឲ្យទៅឃុំត្រពាំងអង្គហ្នឹងវិញ។ ចាស សូមជម្រាបមួយៗ សូមលោកស្រីតាមដាន។ ដល់បានប្រហែល១ខែ គេឲ្យជម្លៀសម្ដងទៀត។ គេឲ្យភូមិហ្នឹងត្រូវរៀបខ្លួនទៅម្ដងទៀត ពីព្រោះឲ្យទៅ ៗកន្លែងមានស្រូវមានអង្ករហ្នឹង ម្នាក់ៗអរណាស់ ពីព្រោះវាកាន់តែស្បើយហើយ អ្នកមូលដ្ឋានក៏អត់សូវមានស្រូវអង្ករច្រើនដែរ អ្នកមូលដ្ឋានភូមិត្រពាំងអង្គ ភូមិអីហ្នឹងអត់ទេ។ ដល់ហើយក៏យើងត្រូវទៅ ដល់ទៅហ្នឹង ខ្ញុំទៅហើយ ខ្ញុំអត់នៅទេ។ ហើយដល់មកជិត សូមទោស វាអ៊ីចឹងបានម៉ាដាមពិបាកយល់។ ដល់ពេលខ្ញុំ

ត្រឡប់មកបានរស់រានមានជីវិត៧៩នេះ បានខ្ញុំជួបលោកគ្រូម្នាក់ ដែលគាត់នៅផ្ទះល្វែងក្បែរខ្ញុំ គាត់ប្រាប់ខ្ញុំអំពីរឿងគាត់មុត ធ្លាក់ពីលើដើមត្នោត គាត់រត់ចោលស្រុកនុ៎ង ក្រោយពេលពួកខ្ញុំចេញហ្នឹង។ វាទៅចុងណ៎ា វាចង់នៅសល់មនុស្សខ្លះនៅភូមិហ្នឹង គេអត់ព្រមទៅ។ ដល់អ៊ីចឹងបងប្អូនគាត់ខ្សឹបថាឲ្យគេចផុតពីហ្នឹងទៅ ប្រហែលជាយើងមិនឲ្យយើងសុខទេ អ្នកដែលក្រាញនៅលើកទី៣នេះ។

អ្នកដែលក្រាញនៅចុងក្រោយហ្នឹងចាស។ ហើយគាត់រត់ទៅនៅ៥៥វិញទៅ បានគាត់រស់ៗ។ តែឥឡូវមិនដឹងគាត់ឈឺស្លាប់ហើយទេក៏មិនដឹង ខ្ញុំមិនដែលជួបទេ។ នៅភ្នំពេញដែលលោកហ្នឹង។ សូមទោស។

[១៤:០៧:០៩]

**ស៖** សូមអភ័យទោសលោកស្រីដែលខ្ញុំយល់មិនសូវច្បាស់អម្បាញ់មិញនេះ។ លោកស្រីចាកចេញទៅតាមឡាន ហើយលោកស្រីថានៅប្រជ្រៀតគ្នានៅក្នុងឡាននុ៎ង ហើយលោកស្រីមានទុក្ខព្រួយនៅក្នុងឡាននុ៎ងលោកស្រីធ្វើដំណើរអស់រយៈពេលប៉ុន្មានដែរ?

**ឆ៖** ដល់ -- ចាស ១ថ្ងៃដល់ព្រលប់បានៗដល់ពោធិ៍សាត់។ មិនមែនពីព្រលឹមទេ គឺទម្រាំតែជុំគ្នាហ្នឹងវាប្រហែលម៉ោងប្រាំបី ប្រាំបួនហើយហ្នឹង បានគេបើកឡានចេញទៅ។ ហើយពេលដែលចេញពីថ្នល់ដាច់ហ្នឹងយើងអត់ដឹងទិសដែលគេយកទៅណាទៀត។ ដឹងថាទៅរកកន្លែងស្រូវអង្ករ យើងយល់ថាបែបបាត់ដំបង បែបពោធិ៍សាត់អីហ្នឹង។ អ៊ីចឹងគេយកទៅដល់ពោធិ៍សាត់មែន។ ប៉ុន្តែព្រលប់ណាស់ហើយបានដល់ពោធិ៍សាត់ហ្នឹង ព្រោះផ្លូវវាអាក្រក់ពេកចាស។ ហើយនៅក្នុងឡានហ្នឹងចង្អៀតណាស់ យើងអត់អាចឈប់ គេអត់ឈប់ គេអត់មានឈប់ច្រើនកន្លែងទេ មានឈប់តែម្ដងទេ គឺមេ ខាងពួកខ្មែរក្រហមហ្នឹង គេញ៉ាំអី ឬក៏គេចូលបន្ទប់ព្រៃ ទៅកន្លែងព្រៃទៅអី។ ពួកយើងហ្នឹងអត់ហ៊ានចុះទេ ទាល់តែគេប្រាប់ឲ្យចុះ បានហ៊ានចុះ។ ទៅដល់ពោធិ៍សាត់ គេប្រាប់ឲ្យចុះ បានហ៊ានចុះ ហើយនៅលើហ្នឹងអត់ហ៊ានចុះប្រសេចប្រសាចទេ។

[១៤:០៨:៣៩]

**ស៖** លោកស្រីទៅដល់ពោធិ៍សាត់នៅពេលយប់ បន្ទាប់មកលោកស្រីឡើងជិះរថភ្លើង។ លោកស្រីជិះហ្នឹង ជិះក្នុងទូដឹកទំនិញ ឬក៏ទូសម្រាប់ដឹកអ្នកដំណើរ?

**ឆ៖** ចាស ជិះនៅក្នុងទូទំនិញ ប៉ុន្តែអត់មានឃើញទំនិញអ្វីទេ គ្រាន់តែឃើញទូទទេ មិនមែនអ្នកសម្រាប់អ្នកជិះទេ។

**ស៖** សូមអរគុណលោកស្រី។ តើរទេះភ្លើងនោះទៅឈប់នៅកន្លែងណាដែរ?

**ឆ៖** រទេះភ្លើងដែលពួកខ្ញុំជិះហ្នឹង គេទៅឈប់នៅវ៉ាមួយឈ្មោះ គោកត្រុំ។ គោកត្រុំហ្នឹងវាហួសវ៉ាមួយ កោះចា។ វ៉ាកោះចារួចបានទៅដល់វ៉ាគោកត្រុំ ៗទៅបន្ទាប់ពីគោកត្រុំទៅ អាចទៅដល់ភ្នំធិបតី។ អ៊ីចឹងវ៉ាហ្នឹង នៅចន្លោះហ្នឹង នៅក្បែរភ្នំធិបតីហ្នឹងដែរ។ វ៉ាគោកត្រុំ។

[១៤:០៩:៥៤]

**ស៖** តើនៅនុ៎ង កន្លែងនុ៎ងមានភូមិទេ នៅក្បែរៗហ្នឹង នៅពេលដែលឈប់ហ្នឹង? ហើយគេឲ្យលោកស្រីធ្វើអ្វីដែរ នៅរថភ្លើងឈប់នោះ?

**ឆ៖** ចាស វ៉ាគោកត្រុំហ្នឹង មើលទៅជុំវិញអត់ដែល -- អត់ឃើញដំបូងផ្ទះអ្នកភូមិណាសោះ។ គេតែស្នាមគេ -- អ្នកមកដល់ដំបូងហ្នឹង ដូចថាមានអ្នកខ្លះរតេករតាកដុត ស្នាមដុត ស្នាមអីនៅសល់នៅវ៉ាគោកត្រុំហ្នឹង។ អត់មានឃើញអ្នកភូមិចាស់ណាទាំងអស់ មកចាំទទួលយើង ឬក៏មកចាំប្រាប់អីយើងទេ អត់មានសោះ។ ដល់អ៊ីចឹងយើងមកដល់ហ្នឹង យើងមឹងមាំង ព្រោះខាងក្រោមសុទ្ធតែទឹក ខាងត្បូងក៏សុទ្ធតែព្រៃ ខាងជើងក៏សុទ្ធព្រៃ។ ដល់អ៊ីចឹងមិនដឹងជាទៅឯណា ទៅអីណើ ក៏នាំគ្នានៅអង្គុយក្រាញនៅលើហ្នឹងមើលមុខគ្នាម៉េងម៉ង់ៗអ៊ីចឹងទៅ។ មិនហ៊ាននិយាយឮ ពីព្រោះនៅក្នុងប៉ារុងហ្នឹងមានយោធាគេនៅតាមប៉ារុងហ្នឹងម្នាក់ដើរទៅណោះ ម្នាក់ដើរទៅណោះអ៊ីចឹង មនុស្សចាស់ មិនក្មេងពេកទេ។ អ្នកដឹកជញ្ជូនយើងទៅហ្នឹង យើងឈប់នៅគោកត្រុំហ្នឹង។

[១៤:១១:០៥]

ហើយដល់មួយសន្ទុះធំគេដើរទៅមុខបាត់ ពួកយោធាពីរបីនាក់ដែលនៅក្បែរប៉ារុងខ្ញុំហ្នឹង គាត់ឡើងទៅខាងក្បាលរទេះភ្លើងទៅ។ ស្រាប់ឮអាក្បាលហ្នឹងរត់ទៅឃិបៗ ទៅត្បូក -- ទៅលិចបាត់ទៀត។ ពួកយើងលែងមានក្បាលរទេះភ្លើងហើយ នៅតែប៉ារុងនៅហ្នឹង។ រឹតតែលែងយល់ទៀត មិនដឹងធ្វើម៉េចបើគេទម្លាក់អ៊ីចឹង។ អ៊ីចឹងក៏ដល់បានប្រហែលមួយម៉ោង ពីរម៉ោងមក ខ្ញុំមិនអាចមានម៉ោងទេ ពីព្រោះកាលណាយើងទន្ទឹងរឿងវ៉ារពេកទៅ វាវែង វាខ្លីអី ខ្ញុំមិនអាចប៉ាន់បានទេ ហើយដល់គេមកវិញ។ គេដើរមកចូលមកហ្នឹង ព្រោះរឺម៉ក ក្បាលរទេះភ្លើងហ្នឹងគេភ្ជាប់ហើយ គេដើរចូលមក គេទាញអីវ៉ាន់ចុះ អ៊ីចឹង ថាឲ្យចុះនៅហ្នឹងនៅ។ ដល់ចុះអ៊ីចឹង គេឲ្យទាញទម្លាក់ ម្នាក់ៗភ័យហើយ ស្រវេស្រវាខ្លាចលោបាត់ច្រឡំរបស់របរអី ក៏ត្រូវតែចុះ ព្រោះទឹកមុខគេលែងសប្បាយហើយ។

[១៤:១២:០១]

ដល់ចុះអ៊ីចឹងទៅបានទេទាញក្បាលហ្នឹងទៅអស់ទៅ ទៅលិច អត់មានមកកើតទេ។ អូសយកទៅលិចចាស។ ពួកយើងនៅនឹងព្រៃហ្នឹងបណ្តោយ ជិតយប់ហើយ ថ្ងៃរសៀល។

**ស៖** តើគេមានប្រាប់មូលហេតុថា ថាហេតុអីបានគេទុកលោកស្រីចោលនៅកន្លែងដែលគ្មានភូមិស្រុកអីអ៊ីចឹងទេ?

**ឆ៖** គេអត់និយាយផង គេទាញទម្លាក់ទៅ ថាកន្លែងហ្នឹងហើយ គេប្រាប់ម្តងពីមុន ពេលមកដល់គេថាឲ្យយើងចុះទៅ គឺយើងគ្មានឯណាប៊ានចុះ។ វាអត់មានភូមិ មានស្រុក វានៅតែក្នុងព្រៃអ៊ីចឹង អត់ អត់ដឹងទៅណា មកណើ។ ដូចម្នាក់ៗឡេងឡង់ ឯណាកូនឈឺ ឯណាម្តាយចាស់ ឯណាខ្លួនឯងមិនដឹងទៅឯណា អត់ស្គាល់ស្រុក ស្គាល់ភូមិអ៊ីចឹង។ ម្ល៉ោះហើយវា វាត្រូវនៅរួញរាមិនចុះដល់គេមកជាប់ម្តងទៀត បានយើងត្រូវតែដឹងថា គេខឹងហើយ។ អ៊ីចឹងយើងក៏ស្ទុះស្ទាចុះដែរ។

[១៤:១៣:២៤]

**ស៖** គេមិនប្រាប់មូលហេតុលោកស្រីទេ។ ក៏ប៉ុន្តែចំពោះលោកស្រីដែលមានបទពិសោធន៍នោះលោកស្រីតើដឹងទេ ថាហេតុអ្វីបានជាគេទុកលោកស្រីនៅកន្លែងហ្នឹង?

**ឆ៖** គឺជាទិសដៅរបស់គេ ដឹកយើងមកដាក់ត្រង់ហ្នឹងហើយ បើយើង អាហ្នឹងជាទិសដៅរបស់គេ គេឌុបមកដាក់ហ្នឹងហើយ។ ហើយឲ្យយើងស្តាប់បញ្ជាគេទៅ ទៅរៀនរស់នៅក្នុងព្រៃហ្នឹងទៅរកកន្លែងនៅ រកអីអ៊ីចឹងទៅ។ ព្រោះអត់មានអ្នកណាមកប្រាប់ បើសិនជាមានមនុស្សប្រាប់នៅប៉ារុងណាទៀត ក៏ខ្ញុំមិនដឹង ប៉ុន្តែប៉ារុងដែលខ្ញុំជិះហ្នឹង គឺអត់មានគាត់ប្រាប់ទេ ៗគេគ្រាន់តែទាញសម្តាយយើងទម្លាក់ៗអ៊ីចឹង។ បានយើងដឹងថា ត្រង់ហ្នឹងហើយដែលយើងត្រូវនៅ។

**ស៖** តើលោកស្រីអាចពន្យល់ត្រួសៗបានទេ ថាលោកស្រីធ្វើម៉េចដើម្បីទទួលបានទឹក ម្ហូបអាហារមកហូបចុកនោះ ហើយតើធ្វើម៉េចដើម្បីទទួលបានរបស់របរទាំងអស់ហ្នឹង ហើយកន្លែងរស់នៅវិញលោកស្រីត្រូវរកអីខ្លះដើម្បីមកសង់ជាជម្រកដើម្បីនៅអីជាអ៊ីចឹង ជាដើម?

[១៤:១៤:៥២]

**ឆ៖** រឿង សូមទោស -- សូមជម្រាប រឿងបញ្ហាទឹក យើងដូចអត់ខ្វល់ទេ ពីព្រោះកន្លែងណាក៏មានទឹកដែរ ឲ្យតែយើងដាំមានកូនកំសៀវមួយទៅដាក់ដាំទៅ គឺបានហើយ។ ប៉ុន្តែអត់ដឹងមានអាហារអី ពីព្រោះសុទ្ធតែបន្លែព្រៃ សុទ្ធតែដើមវាំង សុទ្ធតែដើមត្រស់ ដើមត្រែង ហើយនិងទឹក ហើយនិងដំបូកដំបូកដីទួលខ្ពស់ៗហ្នឹងនៅច្រើនណាស់កន្លែងហ្នឹង មានដំបូក។ ដល់អ៊ីចឹងយើងមិនដឹងជាយ៉ាងម៉េចទេ

ដល់ពេលពីរបីយប់មក ប៉ុន្តែភ្លៀងចាប់ធ្លាក់ច្រើន ខែហ្នឹងខែកញ្ញា ធ្លាក់រាល់ថ្ងៃទទឹកសម្លៀកបំពាក់ ទទឹកអីឲ្យយើងពិបាក ម្ល៉ោះហើយកល់អាដើមឈើហ្នឹងនៅពីក្រោមខ្លួនទៅឲ្យតែកូនគេងលើខ្លួនទៅ ខ្លួនឯងនៅអង្គុយទ្រាំៗឲ្យកូនបានគេងទៅ យើងអត់មានបានគេបានធម្មតាទេ អត់ទេ គេងអត់កើតតែម្តងលើទឹក វាហូរទៅក្បែរៗស្ពានហ្នឹងច្រើនណាស់។ ហើយដល់អ៊ីចឹងយើងពិបាក ពិបាកមែនទែន មិនដឹងជាទៅឯណា ង៉េមង៉ាមទាំងអស់គ្នា ដូច្នេះព្រលឹមឡើងអ្នកខ្លះដើរទៅរកកាប់ស្បូវកាប់អី មានអ្នកស្រុកអ្នកអី ខ្លះមានសល់កាំបិតមួយ មានអីគេកាប់គេអីទៅ យើងក៏ពឹង ខ្ចីគេបានមួយភ្លែត កាប់បាន១បង្គោល ២បង្គោលអ៊ីចឹង ទៅរកស្បូវ។ ហើយមិនដឹងជារកត្រីសាច់អីម៉េច បើវាអត់មានអាគ្រឿងធ្វើត្រីសាច់ហ្នឹង ដូច្នេះពេលហ្នឹងជាលក្ខខណ្ឌមួយលំបាកណាស់ក្នុងការរស់នៅ អត់មានអ្វីសម្រួលយើងសោះៗ អត់ៗដឹងទៅរកណាដល់ពីរបីយប់ទៀត មានម្នាក់គេមកហៅថា “ឲ្យទៅភូមិមួយនោះៗ ទៅរកស្រូវ”។ ដល់ទៅគេចាត់តាំងឲ្យកិនស្រូវអ្នកមូលដ្ឋាន នៅភូមិដ្ឋានហ្នឹងភូមិសុភី។ ប៉ុន្តែតែដើរយប់មកវិញទម្រាំតែកិនរួចបានម្នាក់មួយកាពៀកៗ ទូលយកមកភ្លៀងៗ ដំទទឹកជោក អ៊ីចឹងយកទាំងអង្ករទទឹកជោកហ្នឹងទៅចាក់ឲ្យរួមឲ្យគេ។ គេមានរួមក្បែរផ្លូវរទេះភ្លើងហ្នឹង មានមួយរួមបានគេវាល់ឲ្យយើង។

[១៤:១៦:៥០]

គេវាស់ឲ្យយើងញុំាវិញ។ មិនមែនថាទូលបានប៉ុណ្ណឹងយកមកសម្រាប់ខ្លួនយើងទេ យកមកដាក់រួម។ ដល់អ៊ីចឹងគេវាស់ឲ្យម្នាក់១កំប៉ុងៗអ៊ីចឹងដែរក្នុងពីរបីថ្ងៃមុនហ្នឹងចាស នៅក្នុងព្រៃគោកត្រុំហ្នឹង។ ដល់អ៊ីចឹងយើងទៅយកអាហ្នឹងមកបបរ យកមកអីញុំាទៅ ខ្វះទៅដើរកាត់ស្បូវទៅឃើញៗអាស្បូវហ្នឹងយកកាប់ទៅ ហើយនៅតាមស្បូវហ្នឹងសម្បូរជាងគេគឺសត្វម្រើមព្រះ។ សត្វម្រើមព្រះហ្នឹងធំៗណាស់គួរឲ្យខ្លាច ប៉ុន្តែពេលនុ៎ងមានអ្នកខ្លះប្រាប់ថា ន៎ែ អាហ្នឹងឆ្ងាញ់ណាស់ ដល់អ៊ីចឹងទាំងខ្ញុំទាំងគេ ខ្ញុំខំទោះបីខ្លាចប៉ុនណាយកមក គេថាដុតទៅសាច់វាសណាស់ដូចបង្កង ស្រាប់យកដុតឲ្យកូនវាអត់មានអីទាំងអស់សត្វហ្នឹង។ អ៊ីចឹងយើងញុំាតែប្រោះស្វា អាដើមប្រោះស្វាសម្បូរណាស់នៅក្នុងព្រៃហ្នឹង។ នៅក្នុងព្រៃហ្នឹងយកមកស្ងោរតែម្តងអត់មានម្ហូបទេចាស។ ស្ងោរដាក់អំបិលទៅ ញុំា។ អ្នកមានអំបិល បើអ្នកអត់អំបិលអត់។ រួចហើយអាម្រើមព្រះហ្នឹងបោះចោលអត់ចេះញុំា ហើយខ្លាចទៀតផងចាស។ យើងមិនដឹងជាទៅរកអីទេអត់ស្គាល់ភូមិគេ យូរៗជួបមនុស្សម្នាក់មកនាំ -- មកៗថាឲ្យទៅរកអ៊ីចឹង។ ដល់ពេលវាពិបាក៤, ៥, ៦ថ្ងៃ ខ្ញុំចៃដន្យ ខ្ញុំបានដើរទៅស្រាប់ជួបពូមួយអង្គុយនៅរ៉ាវទេះ -- លើថ្នល់រទេះភ្លើងហ្នឹងមុខស្រងូតស្រងាត់ ខ្ញុំចង់ខ្លាចថាគាត់ដូចជាខ្មោចលង ឬក៏យ៉ាងម៉េចអត់និយាយអីទាំងអស់។ ខ្ញុំសួរគាត់

ទៅ គាត់ថាគាត់មករកបងប្អូនឈ្មោះនេះៗ ដល់រាប់ទៅ ខ្ញុំដឹងថា លោកតាខ្ញុំហើយ អ៊ីចឹងខ្ញុំហៅគាត់ទៅជួបលោកប៉ាខ្ញុំវិញ។ ដល់ទៅជួបវិញគាត់ហៅថា “ឥឡូវទៅនៅខាងណោះវិញ យើងមានភូមិមួយ” អ៊ីចឹងកន្លែងហ្នឹងអត់មានភូមិ ក៏នាំគ្នាប្រមូលបងប្អូនហ្នឹងបានប្រហែលជា ៥, ៦, ៧នាក់ ទាំងអ៊ំយ៉ុនហ្នឹង ខ្ញុំជួបអ៊ំយ៉ុនហ្នឹង ខ្ញុំជួប ជាបងម្ដាយក្មេកខ្ញុំបង្កើត។ ដល់ខ្ញុំជួប គាត់ប្រាប់ខ្ញុំថា “ស៊ុន ម៉ាក់ឯងហ្នឹងគាត់ស្លាប់នៅតាកែវណោះហើយ ទាំងប្អូន២នាក់ក៏ស្លាប់ដែរ អត់មានបានមកទេ”។ យើងដើររកដើម្បីឲ្យឃើញម៉ែហ្នឹង តែគាត់ប្រាប់មកថា “ស្លាប់ហើយ”។ គាត់ក៏នាំគ្នាទៅតាមបងមួយនៅខាងជំរំថ្កូវហ្នឹង។ យើងទៅមើលគាត់ គាត់ថា “គាត់មកមុនពួកអាមុនពួកអូនឯង។ បងមកមុនពួកអូនឯងប្រហែល៦-៧ថ្ងៃហើយ”។ ដល់អ៊ីចឹងគាត់មានទីតាំងរបស់គាត់។

[១៤:១៩:២៤]

ប្រហែល១អាទិត្យក្រោយមក ដែលខ្ញុំនៅគោកត្រុំហ្នឹងទាំងលំបាកទាំងលំបិនហ្នឹង បានទៅគោកត្រុំហ្នឹង។ ដល់ទៅគោកត្រុំហ្នឹងក៏មិនខុសពីហ្នឹងដែរ ស្ថានភាពមិនមែនភូមិអ្នកស្រុកទេ គឺជាដីទួលមួយតូចល្មម ហើយគេឲ្យឈ្មោះថា “ជំរំថ្កូវ” ព្រោះអ្នកស្រុកសង់ -- អ៊ំ អ្នកជម្លៀសហ្នឹងទៅសង់ផ្ទះខ្ទមអីនៅហ្នឹង ក្បែរៗទឹកហ្នឹង សុទ្ធតែទឹកលិច ហើយអានោះដំបូក ហើយអាកន្លែងដីភូមិគេហៅ “ជំរំថ្កូវ” ហ្នឹង គឺជាៗទីលានបញ្ជាន់ស្រូវរបស់អ្នកស្រុកខេត្តបាត់ដំបងទេ ពេលគេច្រូតស្រូវរួចគេអត់ទៅភូមិគេ វាឆ្ងាយៗ គេធ្វើលានហ្នឹងបញ្ជាន់។ ដល់យូរទៅលានហ្នឹងវាអត់មានផ្លែឈើផ្លែអីញ៉ាំទេ។ អត់មានសោះ មានតែដីទួលប៉ុណ្ណឹងទេ ដែលឲ្យយើងកល់ដាក់ដើរចុះដើរឡើងអីបានបន្តិចបន្តួចហ្នឹង។ ហ្នឹងបានៗក្រោយមកទៀតវាអត់១ខែ២ខែ អត់ខ្លាំងពេកចាស អត់ខ្លាំងពេកខ្ញុំរត់ៗទៅរកភូមិចាស់។ ស្រាប់តែមានពូមួយនុំងមក ពូចម្លែកហ្នឹងខ្មៅអ៊ូញហ្នឹង លោកមកនិយាយរដឹនៗថា មកពុកម៉ែរកយកៗអាការុងមកទៅដើររកបន្លែ ដល់អ៊ីចឹងម្នាក់ៗស្ទុះស្រវរកបាន គាត់នាំទៅ។ គាត់នាំទៅដើរត្រឡប់មកវ៉ាគោកត្រុំវិញ បានដើរលើផ្លូវរទេះភ្លើងទៅកើត។ ទៅកើតទៅ ទៅយូរៗៗទៅនៅតាមកៀនផ្លូវរទេះភ្លើងខ្ញុំឃើញមនុស្សងាប់ច្រើនពេក បែបមនុស្សហ្នឹងវាអត់ គាត់មិនដឹងទៅឯណា មកអីណី ឃើញងាប់នៅលើអាកូនរានគេកាត់ៗដូចសំបុកៗចាបនៅ ដូចថា តូចៗកូនខ្ពស កូនខ្ទមតូចៗហ្នឹងប៉ុន្តែដុត ស្នាមដុតដើមឈើហ្នឹង ហើយមនុស្សហ្នឹងនៅច្រងេងច្រងាងពេញអាតាមផ្លូវរទេះភ្លើងទៅកើតហ្នឹង។

[១៤:២១:១៧]

ពេលហ្នឹងហើយដែលឪពុកក្មេកខ្ញុំគាត់ស្គុត គាត់ដើរលែងរួច គាត់ចុកឡើងចង់បញ្ឈរភ្នែក គាត់

ណាមួយហៅរពីពេលអត់មក ដល់មកដើរឃើញអ៊ីចឹងវារន្ធត់ ក៏ចាប់ខ្យល់គាត់ទៅ ឲ្យគាត់ទៅភូមិវិញទៅ។ ខ្ញុំនឹងប្រឹងទៅទៀតហើយ ដើម្បីឲ្យបានបន្លែ តែអត់មានបន្លែអីសោះ អត់ជួបទេបន្លែ យូរអើយយូរ។ យូរទៅវិលមុខខ្លួនយើងហ្នឹងទៀត។ ដល់វិលមុខខ្លួនយើងទៀត គេលែងឲ្យយើងដើរតាមគេហើយ អ្នកណាដែលគេនៅទៅរួចគេដោះខ្លួនហើយ គេចង់ទៅមុនហើយ។ បានបងប្អូនជីដូនមួយក្មួយប៉ាអីហ្នឹង មីអូនមិនទៅកើតទេ មីអូនឯងនៅហ្នឹងហើយ កុំអាល់រកកន្លែងជ្រកសិន។ បងទៅរកឲ្យបានព្រោះយប់ឥឡូវហើយ ហើយមេអ្នកដឹកនាំយើងគេទៅបាត់ហើយ។ ប៉ុន្តែដើរជាមួយគាត់នុំង គាត់ចេះតែចូលក្នុងកន្ទ្របព្រៃទាញស្លឹកថ្នឹងស្លឹកអីយកមក គាត់ញុំាហើយ ញុំាចែកយើងហ្នឹងញុំា បែបហៅរគាត់។ គាត់ក៏ហៅរ យើងក៏ហៅរ ហ៊ឹងត្រចៀក ខ្ញុំវិលមុខទៀត។ ខ្ញុំទៅលែងរួច។

[១៤:២២:១៤]

លើផ្លូវរទេះភ្លើងហ្នឹងអត់ទាន់ជួបបន្លែផង ប៉ុន្តែដល់ពេលដែលខ្ញុំ គេយកទៅផ្ញើនៅភូមិមួយនៅតាមផ្លូវរទេះភ្លើងជិតកោះចា ខាងណោះគោកត្រុំ ខាងនេះកោះចា។ នៅពេលកោះចាហ្នឹង គេងនៅនឹងខ្ទមតាហ្នឹង សូមគេផ្ញើខ្លួនទៅ។ យប់ហ្នឹងតាកោះចា ហ្នឹងគាត់ស្គម កូនគាត់ពីរបីនាក់ គាត់ដួសបាយត្រកួនហ្នឹង ត្រកួនសុទ្ធ យកមកឲ្យខ្ញុំមួយកូនចាន ព្រោះខ្ញុំអង្គុយក្បែរគាត់មើលមុខគាត់ដែរ។ តែខ្ញុំញុំាអត់កើត ព្រោះនឹកអាណិតថា គេខំធ្វើបាន គេ -- ខ្ញុំឲ្យគេញុំាវិញទៅ។ ខ្ញុំបានអង្គុយនៅទីហ្នឹងដែរ។ ហើយគេងាប់ម្នាក់ហ្នឹងយប់ហ្នឹង។ ស្អែកឡើងអ្នកយកទៅកប់សុទ្ធតែមនុស្សខ្មោចទាំងអស់។ អ្នកដែលមកសុំយកទៅកប់ហ្នឹងដូចខ្មោចហើយ គ្នាគ្មានកម្លាំងទេ។ ប៉ុន្តែបើគេឲ្យអង្ករមួយកំប៉ុងក៏គាត់យកទៅកប់ដែរ។ ខ្ញុំមើលទៅអ្នកនុំងក៏មិនរស់ដែរ រួចខ្លួនខ្ញុំក៏មិនដឹងមកខ្ញុំដល់កម្រិតណា ព្រោះវាជ្រះដុសធ្មេញក៏គ្មាន សាប៊ូក៏គ្មាន ក្រាសសិតសក់ក៏គ្មាន កញ្ចក់ក៏គ្មាន។ អត់ដែលបានមើលមុខទេ ដូចមនុស្សព្រៃអ៊ីចឹងពេលហ្នឹង។ ខ្ញុំរៀបរាប់ប៉ុណ្ណឹងបានហើយទេ លោកស្រី។

[១៤:២៣:២៨]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញបន្តទៀត ប៉ុន្តែមានការបែងចែកពេលវេលាទេ រវាងក្រុមមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី ជាមួយនិងតំណាងសហព្រះរាជអាជ្ញា។ ពេលវេលាជិតអស់ហើយនៅសល់តែ ២០នាទីទៀតទេ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំត្រូវការប្រហែលជា ១០នាទី ទៀតទេ។ ហើយសហព្រះរាជអាជ្ញាប្រហែលជាត្រូវការ ២០ទៅ៣០នាទី តែប៉ុណ្ណោះលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

យើងបានរំពឹងហើយថា ឲ្យ១កន្លះថ្ងៃ ហើយមានការខកខានបន្តិចបន្តួច យើងបានថែមម៉ោងឲ្យព្រឹកមិញ ៧នាទី។ ហើយដោយសារមានការយឺតយ៉ាវបន្តិចនៅរសៀលនេះ អ៊ីចឹងគឺមិនអនុញ្ញាតឲ្យច្រើនពេកទេ។ សូមឲ្យមានការតាំងសំណួរឲ្យបានជាក់លាក់ ហើយឲ្យចំបញ្ហា ដើម្បីពន្លឿនកិច្ចដំណើរការនីតិវិធី។

[១៤:២៤:៤៣]

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធានយើងខ្ញុំយល់ណាស់ យើងចាប់ផ្ដើមព្រឹកមិញ គឺដប់មួយដប់ប្រាំនាទី ហើយល្ងាចនេះ គឺថាម៉ោងដូចរាងជ្រេបន្តិចហើយបានយើងចាប់ផ្ដើមនោះ។ ដូច្នេះ ខ្ញុំនឹងព្យាយាមគោរពតាមការសម្រេចរបស់លោកប្រធាន។

**សួរដោយលោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

**ស៖** លោកស្រី តើភូមិចុងក្រោយបំផុតដែលលោកស្រីរស់នៅនោះជាភូមិអ្វីដែរ?

**លោកស្រី ទឹង សុខា៖**

**ឆ៖** ភូមិចុងក្រោយដែលខ្ញុំរស់នៅរហូត ដល់ឆ្នាំ៧៩វិញ ហ្នឹង គឺភូមិស្រែអូរ ចាស ស្រុក -- ភូមិស្រែអូរ មោងឫស្សី ខេត្តបាត់ដំបង។ ពេលហ្នឹង គឺខ្ញុំរត់ហើយ ដល់ពេលយ៉ាប់ហើយ ខ្លាំងហើយ ពីព្រោះខ្ញុំគិតថា ទីកន្លែងព្រៃនេះ ប្រាកដជា -- ខ្ញុំបានគិតអ៊ីចឹង ខ្ញុំថា ប្រហែលជាគេទុកឲ្យស្លាប់ទាំងអស់ហ្នឹង។ ពីព្រោះវាស្លាប់ច្រើនណាស់ហើយ ពីមុន ក្នុងរយៈ២ខែហ្នឹង ស្លាប់ៗ នឹងអត់ ស្លាប់នឹងគ្មានថ្នាំ ខ្លះពិបាកខ្លាំងពេក អត់ស៊ីធ្វើហ្នឹង ហើយមិនដឹងរកភូមិឯណាដើម្បីដោះដូរបាន។ អ៊ីចឹង ខ្ញុំរត់មកភូមិមួយទៀត គឺហើយចុងក្រោយហ្នឹង គឺស្រែអូរ ចាស។

[១៤:២៥:៥៩]

**ស៖** សូមអរគុណលោកស្រី។ លោកស្រីបានរៀបរាប់អំពីការជម្លៀសទាំងពីរលើក ដែលលោកស្រីបានទទួលរង ហើយលោកស្រីរៀបរាប់អំពីកន្លែងដែលលោកស្រីបានឆ្លងកាត់ ហើយលោក

ស្រីថា "កូនស្រីលោកស្រីនៅពេលនោះ ដែលមានអាយុ៤ឆ្នាំនោះ ស្លាប់ដោយសារតែខ្វះអាហារ ហើយនិងមិនមានការថែទាំបានល្អ ហើយដោយសារតែមានការជម្លៀសជាបន្តបន្ទាប់"។ តើលោកស្រីអាចជម្រាបបានទេ ថាតើស្វាមីរបស់លោកស្រីនោះ អាចបានទទួលរងនូវការជម្លៀសទាំងពីរលើកនេះ យ៉ាងម៉េចដែរ?

**ឆ៖** ចាស គាត់ក៏ដូចខ្ញុំដែរ ព្រោះនៅជាមួយគ្នា ប្តីប្រពន្ធ អត់បែកគ្នាបានទេ ពីតាកែវហ្នឹង ទៅរហូត ដល់អ៊ីចឹង ប៉ុន្តែគាត់ចាប់ឈឺច្រើនជាងគេ។ គាត់ឈឺដំបៅ នៅតាំងពីជំរំថ្កូវ ឈឺជើង ហើមប៉ុណ្ណឹងៗ ដើរចុះទឹក អត់បានទេ ពីព្រោះនៅលើទឹក យើងនៅលើទឹក។ ហើយកូនខ្ញុំអីហ្នឹង ដល់ពេលខ្ញុំរត់មកស្រែអូរហ្នឹង នៅឆ្នាំ៧៦ កូនស្រីក៏ស្លាប់ ឪពុកក្មេកខ្ញុំក៏ស្លាប់ ប្អូនស្រីពីរនាក់ក៏ស្លាប់។

[១៤:២៧:០២]

វាអស់រលីងពីខ្លួនហើយ អ្នកនៅក្នុងគ្រួសារតែមួយហ្នឹង ថាបានមកភូមិថ្មី ថាក្រែងបានរស់ ប៉ុន្តែដល់មកភូមិថ្មី ផ្លែឈើគេមាន តែគេដាក់រួមៗ អត់អាចអ្នកណារកបានញុាំទៀតទេ។ ដល់រួមអស់ហើយ យើងញុាំតាមរបបដែលគេឲ្យបបរ ថ្ងៃខ្លះមានបបរាវ ថ្ងៃខ្លះកន្ទក់ ហើយអត់ចានឆ្នាំង គេប្រមូលយកទៅដាក់រួមទាំងអស់។ អាពេលហ្នឹង ដែលដាច់ពោះខ្លាំងមែនទែន នៅភូមិចាស់មែន ប៉ុន្តែគ្មានសេរីភាព ដើរហើរ។ បើគេចាប់បាន ក៏គេមិនឲ្យយើងរស់ដែរ ហើយដល់អ៊ីចឹង កូនខ្ញុំបានស្លាប់នៅពេលហ្នឹងហើយ។ ស្លាប់នៅពេលហ្នឹង វាក្តៅៗ វារាក វាហើមជើងព្រុលៗ តាំងពីជំរំថ្កូវ។ ដល់មកដល់ណេះ អត់ថ្នាំអីទៀតព្យាបាលអត់បាន ពីចុង៧៥ ខ្ញុំខំរត់ទៅមោង ខ្ញុំខំយកកូនហ្នឹងទៅមោង ពីព្រោះខ្ញុំមានជំនឿ ជឿជាក់លើមន្ទីរពេទ្យ។ ដល់ទៅបានមោងហ្នឹង ជួបលោកគ្រូពេទ្យចាស់ ឈ្មោះលោក ទឹម គឹមសៀ ហ្នឹង។ គាត់ពូកែ គាត់ព្យាបាលទៅ វាស្រកបាត់រាកទៅ ខ្ញុំត្រឡប់មកវិញ។ តែដល់៧៦ ឈឺខ្លាំងទៀត អត់មានអ្នកណាមើល ខ្ញុំចេះតែដើរធ្វើការៗទៅ ហើយឪពុកជីតាអីស្លាប់អស់អ៊ីចឹងទៅ កូនខ្ញុំត្រូវស្លាប់តែម្តង ៧៦ ហ្នឹង ស្លាប់ ហើយប្អូនពីរនាក់ ក៏ស្លាប់នៅ៧៦។

[១៤:២៨:២១]

អ៊ីចឹងអស់ហើយ នៅ៧៦ នៅចុង៧៧ អំ! ដើម ៧៧ ចប់ ខ្ញុំមានរឿងមួយដែលធ្ងន់ទៀត ប៉ុន្តែពាក់ព័ន្ធនឹងគ្រួសារខ្ញុំ គឺគាត់ឈឺ ឈឺម្តងបាក់ វាបាក់កម្លាំងគាត់ខ្លាំងគាត់ពេកទៅ ដើរងងឹតភ្នែក ថ្ងៃល្ងាចម៉ោងបួន ម៉ោងប្រាំ ងងឹតរកផ្លូវមិនឃើញទេ។ បើគេឲ្យទៅប្រជុំងងឹត គេឃើញគាត់ដើរចូលព្រៃបន្លា។ អ៊ីចឹង ខ្ញុំអីត្រូវដឹកដៃ ដឹកអីគាត់អ៊ីចឹងថែមទៀត។ ពិបាកណាស់ គ្រួសារខ្ញុំ គាត់បាក់ខ្លាំង ហើយគាត់ខ្លាច

គេបំផុតទៀត។ បើខ្លាចគេ មិនប៉ានរកអីញ៉ាំផ្តេសផ្តាសទេ ខ្លាចគេចាប់ គេវៃអីអ៊ីចឹង គាត់ភ័យណាស់។ ដល់មក៧៧ គាត់សម្រេចចិត្តធ្វើសម្លាប់ខ្លួនបណ្តោយ។

**ស៖** តើលោកស្រីអាចជួយសង្គ្រោះជីវិតគាត់បានទេ នៅពេលនុ៎ង?

**ឆ៖** អ៊ំសង្គ្រោះគាត់បាន ប៉ុន្តែមិនមែន --- ពេលខ្ញុំចេញមកពីធ្វើការ ព្រោះខ្ញុំពីរបីថ្ងៃទៀត គេបញ្ជូនខ្ញុំទៅរនាម ឬក៏ទៅរលួស ដើម្បីទូលស្រូវឆ្ងាយពីគាត់ ហើយកូនស្លាប់អស់ហើយ ហើយមានកូនស្រីមួយគទៀត ទៅនៅផ្ទះគេដើម្បីរស់។ ដល់អ៊ីចឹង គាត់ឯកា ត្រូវខ្ញុំទៅមុខទៀត។ ដល់អ៊ីចឹង ខ្ញុំចេះតែភ័យរអើល។ ព្រោះខ្ញុំបានជួបពីរដង ឃើញគាត់ មានអារម្មណ៍ចង់ធ្វើស៊ីស៊ីតហ្នឹង ចង់ធ្វើស្លាប់ខ្លួនហ្នឹង។ ម្តងនោះ ខ្ញុំឃើញគាត់ចេញពីព្រៃស្វាត់មក។ ខ្ញុំសួរថា “ម៉េចក៏មកនៅព្រៃខ្មោចអ៊ីចឹងបង?” គាត់ថា “ចាំទៅដល់ផ្ទះប្រាប់”។ ទៅដល់ផ្ទះគាត់ប្រាប់ថា គាត់ខ្លាចឈ្លបគេចាប់គាត់ ពីព្រោះក្មេងៗចេះតែមកច្រៀងលេងក្បែរផ្ទះហ្នឹង គាត់ចេះតែភ័យ។ ព្រោះឃើញគេអូសមនុស្សទៅឡើងរទេះសេះ ៗយកទៅធ្វើការងារគេហ្នឹង បាត់ៗអស់ពីមុខគាត់។ ដល់អ៊ីចឹងគាត់ភ័យ គាត់ឈឺផង ធ្វើការអត់បានពេញកម្លាំង គាត់ទៅពួនដល់គាត់ពន្យល់ខ្ញុំអ៊ីចឹង ខ្ញុំស្ទាបគាត់ ខ្ញុំអាណិតគាត់ពេក ខ្ញុំមើលទៅហោប៉ៅ គាត់មានគំនិតចង់សម្លាប់ខ្លួនហ្នឹង គ្រាប់ប៉េងួក។ ខ្ញុំជម្រាបទៅដូចជារឿងកំប្លែងចុះ។ ខ្ញុំថា “ស្អីអាហ្នឹង?” គាត់ថា “អាហ្នឹង ទុកសម្រាប់សម្លាប់ខ្លួន។ ដូចថាពេលណា គេយកបងទៅ បងលេបហើយ ពីព្រោះវាងាប់លឿន”។

[១៤:៣០:៥៣]

គាត់ភ័យខ្លួនគាត់ ខ្ញុំក៏យកបោះចោលចេញអស់។ តែពីពេលហ្នឹងមក ខ្ញុំលែងទុកចិត្តគាត់។ ព្រោះពួកគាត់លែង គេក៏មនុស្សអត់ចេះនិយាយច្រើនទេ គាត់ស្ងៀម គាត់ត្រិះរិះច្រើន គាត់មិនធ្វើអីឲ្យខ្ញុំខ្វល់ច្រើនពេក គាត់មិនដែលនិយាយអីទេ។ ដល់ពេលថ្ងៃមួយ ដែលខ្ញុំត្រូវបែកទៅធ្វើការនៅស្រុករលួសខ្ញុំបាត់គាត់ៗ ខ្ញុំចូលមករកគាត់មិនឃើញ រកគាត់មិនឃើញ ខ្ញុំក៏រត់ទៅផ្ទះបាយ ក្រែងគាត់ទៅយកបាយរត់ទៅបង្គន់ក្រែងគាត់ទៅបង្គន់ អត់ឃើញ។ ដល់ចូលមកក្នុងផ្ទះខ្លួនឯងបានឃើញ។ គាត់ធ្វើអត្តឃាតរួចហើយ ប៉ុន្តែឫស្សីហ្នឹងវាបាក់ ឫស្សីដែលគាត់ចងហ្នឹង គឺវាបាក់ ហើយជើងគាត់ឈរបន្តិចនៅក្បែរចុងជើងហ្នឹងប៉ះឫស្សីបន្តិចបន្តួច។ ខ្ញុំខំស្រាយគាត់ ជួយសូវេ ជួយជាន់ ដំ បង្វិលចុះឡើង សព្វគ្រប់ខ្ញុំនឹកឃើញថាវាឫស្សីហ្នឹងវាបាក់ប្រហែលជាមិនអី ចេះតែខំៗធ្វើសព្វគ្រប់ ប្រហែល១ម៉ោង ខ្ញុំយំលែងមានទឹកភ្នែកដំបូង តែដល់ចុងក្រោយ នៅតែអង្គុយរៀបរាប់ទៅវិញ។ វាអស់សង្ឃឹមទាំងខ្ញុំ អស់សង្ឃឹមទាំងគាត់។ អ៊ីចឹងក៏ជាន់ ដល់ជាន់ខ្លាំងពេញកម្លាំងខ្ញុំ ខ្ញុំឡើងជាន់ទៅបានឃើញចេញខ្យល់មក

ចេញខ្យល់ម៉ាអើកមក។ ធ្វើទៀត ធ្វើចលនាអ៊ីចឹងទៀត បានចេញខ្យល់ម៉ាអើកទៀត តែអត់បង្រះទេ គឺនៅតែស្លកអ៊ីចឹងរហូត។ ទាល់តែខ្ញុំយកទឹកមកលាងគាត់ មុននឹងគាត់ស្លាប់ហ្នឹង អំមុននឹងថាខ្ញុំចង់កប់គាត់ហ្នឹង គឺលាងទឹក ចំអាសទឹក ខ្មែរហៅថា “ចំអាសទឹក” លាងឲ្យគាត់បានស្អាត តែដល់មុនត្រូវទឹកទៅ ស្រាប់ឃើញជីពចរឡើងវិញ។ បានគាត់បានរស់មកទៀតបានចាស។ ពេលសង្គ្រោះបានប៉ុណ្ណឹង។

[១៤:៣៣:២១]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំគិតថាសក្ខីកម្មរបស់លោកស្រីនាពេលនេះមានការលំបាកណាស់ ដូច្នេះខ្ញុំសូមបញ្ចប់ត្រឹមនេះ ហើយខ្ញុំសូមអរគុណចំពោះការបង្ហាញព័ត៌មានយ៉ាងពិស្តារ ហើយនិងបានរៀបរាប់នូវព្រឹត្តិការណ៍ដែលលោកស្រីបានឆ្លងកាត់ជូនអង្គជំនុំជម្រះ និងដើមបណ្តឹងរដ្ឋប្បវេណី។ សូមអរគុណលោកស្រីច្រើនណាស់។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតំណាងសហព្រះរាជអាជ្ញាទំនងត្រូវការពេលវេលាប៉ុន្មានទៅ?

**លោក ឌេល លីសាក់៖**

លោកប្រធាន យើងត្រូវការប្រហែលជា២០នាទី លោកប្រធាន។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសមល្មមសម្រាកដែរហើយ។

អង្គជំនុំជម្រះប្រកាសសម្រាក២០នាទី ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបីខ្វះដប់នាទីសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញដល់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ក្នុងអំឡុងពេលសម្រាក ហើយនិងឲ្យអញ្ជើញគាត់មកកាន់កន្លែងផ្តល់សក្ខីកម្មនេះវិញនៅវេលាម៉ោងបីខ្វះដប់នាទី។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៣៤នាទី ដល់ម៉ោង ១៤:៥៦ នាទី)*

[១៤:៥៦:៣៨]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្ដល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្ដឹងរដ្ឋប្បវេណីរូបនេះ។ សូមអញ្ជើញ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក ឌេល លីសាក់៖**

**ស៖** សូមជម្រាបសួរ ខ្ញុំឈ្មោះ ឌេល លីសាក់ ហើយខ្ញុំនឹងមានសំណួរមួយចំនួនដើម្បីចោទសួរទៅលើលោកស្រីតាងនាមឲ្យសហព្រះរាជអាជ្ញា។ លោកស្រីបាននិយាយរួចហើយ អំពីការជម្លៀសពីភ្នំពេញទៅស្រុកបាទី ហើយលោកស្រីក៏បាននិយាយនៅពេលមុននេះអំពីការចុះឈ្មោះរបស់អ្នកដែលត្រូវជម្លៀស គឺថាលោកស្រីត្រូវប្រាប់ឈ្មោះ ប្រាប់អំពីការងារ និងកន្លែងដែលលោកស្រីធ្វើដំណើរមក។ អ្វីដែលខ្ញុំចង់សួរលោកស្រីជាដំបូង គឺថានៅពេលដែលលោកស្រីនៅក្នុងស្រុកបាទី តើលោកស្រីមានសង្កេតឃើញថា មានអ្វីកើតឡើងចំពោះអ្នកជម្លៀសដែលប្រាប់គេថា គាត់ជាទាហាន ឬក៏ជានគរបាល ឬក៏ជាមន្ត្រីពីសម័យ លន់ នល់ ដែរឬទេ? តើមានអ្វីកើតឡើងដែរឬទេ?

[១៤:៥៨:០៩]

**លោកស្រី ទឹង សុខា៖**

**ឆ៖** ចាស សូមគោរពសហព្រះរាជអាជ្ញា។ ពេលដែលទៅដល់ភ្នំ -- ទៅដល់ស្រុកបាទីហ្នឹងភ្លាម អ្នកភ្នំពេញបានទៅនៅតាមផ្ទះអ្នកមូលដ្ឋានចាស់ ហើយតាមផ្ទះខ្លះ អ្នកមូលដ្ឋានចាស់ដឹង ដឹងថាអ្នកនេះទាហាន អ្នកនោះជាប៉ូលីសអីនៅជាមួយគាត់។ ដល់បានមក ៣, ៤ថ្ងៃមកទៀត ស្រាប់តែឃើញស្ងាត់ៗអស់ទៅ អ្នកហ្នឹងមិនដឹងចេញទៅណាទៀតទេ ខ្ញុំអត់ដឹងទេ។ តែដល់ប្រហែលជា១ខែអីហ្នឹងបានឮពីសម្ដីគេហ្នឹង គេនិយាយបន្តគ្នាយ៉ាងស្ងាត់ហ្នឹងថា គេយកទៅនៅភូមិមួយជុំគ្នាហើយ បួនប្រាំពាន់នាក់ ថាអីចឹងណា មួយភូមិក្រាំងលាវហ្នឹង។

[១៤:៥៩:០៦]

**ស៖** តើលោកស្រីធ្លាប់ ឬក៏ធ្លាប់ឃើញថា មនុស្សទាំងអស់នេះត្រូវបានគេយកចេញពីកន្លែងដែលលោកស្រីរស់នៅដែរឬទេ?

**ប្រធានអង្គជំនុំ៖**

លោកស្រីកុំអាលទាន់ឆ្លើយតប!

សូមអញ្ជើញលោកមេធាវីអន្តរជាតិការពារក្តីលោក នួន ជា!

**លោក ហ្សាស្តេី ប៉ោ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំជំទាស់ទៅលើសំណួរនេះទាក់ទងទៅនឹងទម្រង់នៃការសួរថាតើដើមបណ្តឹងរដ្ឋប្បវេណីបានឃើញអំពីមនុស្សដែលត្រូវបានគេយកចេញឬក៏អត់? ដូច្នេះ ខ្ញុំជំទាស់ទៅនឹងព្រះរាជអាជ្ញា។ ឲ្យព្រះរាជអាជ្ញាបែងចែកជាសំណួរពីរ ថាតើ ទី១បានឃើញ? ឬក៏ទី២ បានឮអំពីការយកមនុស្សចេញពីតំបន់ដែលគាត់រស់នៅ។ ធ្វើដូច្នេះដើម្បីកុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់មានការយល់ច្រឡំ។

**លោក ខេល លីសាក់៖**

សំណួរ លោកប្រធានខ្ញុំគិតថា ដើមបណ្តឹងរដ្ឋប្បវេណីប្រហែលជាមិនមានការឆ្ងល់ ឬក៏មិនមានការមិនច្បាស់លាស់អ្វីទាក់ទងទៅនឹងចំណុចទាំងអស់នេះទេ យើងអាចធ្វើការសួរទៅលើដើមបណ្តឹងរដ្ឋប្បវេណី ថាតើគាត់យល់ច្បាស់អំពីសំណួរខ្ញុំ ឬក៏អត់?

**លោក ហ្សាស្តេី ប៉ោ៖**

*(គ្មានការបកប្រែ)*

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

**លោក ហ្សាស្តេី ប៉ោ៖**

ការជំទាស់របស់ខ្ញុំគឺមិនទាន់សម្រេចនៅឡើយ។ ដូច្នេះខ្ញុំចង់ឲ្យមានការសម្រេចថាតើការជំទាស់របស់ខ្ញុំយ៉ាងដូចម្តេចដែរ មុននឹងយើងអនុញ្ញាតឲ្យដើមបណ្តឹងរដ្ឋប្បវេណីធ្វើការឆ្លើយតបទៅនឹងសំណួរនេះ។

**ប្រធានអង្គជំនុំ៖**

តំណាងសហព្រះរាជអាជ្ញាមានអីតបទៅនឹងសេចក្តីជំទាស់ទេ? ឥឡូវមានការជំទាស់ហើយ។ តាមធម្មតា បើលោកមិនមានការ សេចក្តីជំទាស់ទេក៏លោកត្រូវឆ្លើយដែរ ដើម្បីថាលោកមិនមានសេចក្តីអ្វីតបទៅនឹងសេចក្តីជំទាស់ទេ ដើម្បីឲ្យអង្គជំនុំជម្រះសម្រេចលើបញ្ហាជំទាស់នេះ។ យើងធ្វើរបៀបនេះជារៀងរហូតទៅវាងាយស្រួលជាង។

[១៥:០១:២០]

**លោក ខេល លីសាក់៖**

លោកប្រធាន សាក្សីគាត់មានសិទ្ធិក្នុងការផ្តល់សក្ខីកម្មទាក់ទងទៅនឹងអ្វី ដែលគាត់ឮ អ្វីដែលគាត់បានឃើញជាការឆ្លើយតបទៅនឹងសំណួរ។ ហើយសំណួរនេះ វាមានលក្ខណៈសាមញ្ញមិនមែនជាការបន្លំ ឬក៏មិនច្បាស់លាស់អ្វីនោះទេ។

ខ្ញុំចង់សួរថាតើគាត់បានឮ ឬក៏គាត់បានឃើញអំពីការយកមន្ត្រីសម័យ -- មន្ត្រី លន់ នល់ ឬក៏ទាហាន លន់ នល់ ទៅឬក៏អត់? នេះគឺជាសំណួររបស់ខ្ញុំ។

[១៥:០១:៥៤]

*(ចៅក្រមពិភាក្សាគ្នា)*

[១៥:០២:១៨]

**ប្រធានអង្គជំនុំ៖**

បាទ សេចក្តីជំទាស់ និងសំអាងហេតុនៃសេចក្តីជំទាស់របស់មេធាវីអន្តរជាតិការពារក្តីលោក នួន ជា មិនសមស្របទេ។ សេចក្តីជំទាស់គ្មានប្រសិទ្ធភាព។ សាក្សី -- ដើមបណ្តឹងរដ្ឋប្បវេណីអាចឆ្លើយតបទៅនឹងសំណួរដែលសួរឡើងដោយតំណាងសហព្រះរាជអាជ្ញាចុងអម្បាញ់មិញនេះ។ ហើយប្រសិនបើលោកស្រីមិនចងចាំទេ អាចសុំឲ្យតំណាងសហព្រះរាជអាជ្ញាតាំងសំណួរសាជាថ្មីម្តងទៀត។

**លោកស្រី ទឹង សុខា៖**

**ឆ៖** ចាស នាងខ្ញុំចង់សុំឲ្យលោកព្រះរាជអាជ្ញាមេត្តាម្តងទៀតចាស។

**សួរដោយលោក ខេល លីសាក់៖**

**ស៖** លោកស្រីបានបញ្ជាក់ថា មានអតីតទាហាន នគរបាល និងមនុស្សដែលជាប់ពាក់ព័ន្ធជាមួយនឹងរបបលន់ នល់ ដែលបានបង្ហាញខ្លួននៅស្រុកបាទីនោះ។ តើលោកស្រីធ្លាប់ឮ ឬលោកស្រីធ្លាប់

ឃើញថាតើមានអ្វីកើតឡើងចំពោះមនុស្សទាំងអស់នេះដែរឬទេ?

**ឆ៖** ចាស សូមជម្រាបលោកព្រះរាជអាជ្ញា សូមជម្រាបលោកប្រធាន ពេលដែលខ្ញុំទៅដល់ ខ្ញុំនៅផ្ទះបងប្អូនមួយក្រុមទៅ ហើយមានផ្ទះបងប្អូនផ្សេងទៀត -- ឃើញមនុស្សច្រើន។ ដល់ខ្ញុំទៅបងៗហ្នឹងថា ហ្នឹងសុទ្ធតែពួកប៉ូលិស ហើយពួកទាហាន ដែលឃើញរញៀវអង្គុយលើកាំជណ្ដើរក្នុងផ្ទះហ្នឹង គឺអត់មានទាន់ គាត់ភ័យខ្លួនអីទេ ហើយខ្ញុំក៏អត់ដឹងថាមានរឿងអីកើតឡើងដែរ។ ឃើញថាក្រោយមកទៀតឮគេថា "ពួកដែលប៉ូលិស ពួកទាហានដែលមកនៅញុំាអង្ករជាមួយគាត់ហ្នឹង គេយកទៅនៅម្ដុំផ្សេង" ហើយវាអស់ៗហើយ បាត់ៗឃើញគាត់ហ្នឹងទៅ។ ខ្ញុំ -- ភូមិគេហ្នឹង វាមានចម្ងាយគ្នាប្រហែលជាឆ្លងមាត់បឹងពីខាងណោះមកបឹងខាងណេះ ពេលខ្ញុំមកបឹងខាងណេះឃើញច្រើនរញៀវៗខ្លះសប្បាយរីករាយណាស់ និយាយជាមួយអ្នកមូលដ្ឋានចាស់ហ្នឹង។ ប៉ុន្តែដល់ក្រោយមកឮថា "អឺ នេះគេនេះធ្វើទាហាន នេះខាងប៉ូលិស នេះខាងស្ទីអ៊ីចឹង"។ ហើយក៏គេសើចលេងទេ ដូចជារាប់រកគ្នា ប៉ុន្តែដល់ក្រោយមកទៀតប្រហែលជា ២, ៣ថ្ងៃមកថា "គេយកទៅវិញបាត់ហើយ គេយកទៅដាក់កន្លែងភូមិណាមួយនោះ ប៉ុន្តែមិនដឹងជាវ៉ៃអីយ៉ាងៗ ខ្ញុំអត់ទេ គ្រាន់តែឮថាយកទៅអីហ្នឹងច្រើនណាស់ គេប្រមូល គឺមិនមែនតែផ្ទះគាត់ទេ ប្រមូលពីណាៗមកច្រើន" ចាស។

[១៥:០៥:៥៣]

**សៈ** សូមអរគុណចំពោះចម្លើយរបស់លោកស្រី។ ផ្នែកទី២ ដែលខ្ញុំចង់ចោទសួរទៅលើលោកស្រីផងដែរ គឺពាក់ព័ន្ធទៅនឹងពេលវេលា ដែលលោកស្រីត្រូវបានគេផ្លាស់ពីស្រុកបាទី ទៅពោធិ៍សាត់ ហើយបន្ទាប់មកទៀតទៅបាត់ដំបង។ សំណួររបស់ខ្ញុំគឺថា តើមានមេដឹកនាំជាន់ខ្ពស់នៃរបបខ្មែរក្រហមមកធ្វើទស្សនកិច្ចនៅតំបន់លោកស្រីដែរឬទេ គឺនៅពេលដែលប្រជាជនត្រូវបានគេផ្លាស់ទីពីបាទីទៅពោធិ៍សាត់នោះ តើដែលមានឃើញមេដឹកនាំជាន់ខ្ពស់មកតំបន់ដែលលោកស្រីស្នាក់នៅដែរឬទេ?

**ឆ៖** ចាស ដូចជាជម្រាបម្ដងទៀត។ ឃើញអាមុនពីបាទីហ្នឹង មុននឹងចេញដំណើរហ្នឹងឃើញ ឬក៏ដល់ពេលទៅខាងៗស្រុកៗបាត់ដំបងហ្នឹងបានឃើញ? លោកចង់ដឹងឃើញនៅបាទីនេះ ឬក៏ឃើញឯខាងនោះ? សូមទោស។

**សៈ** សំណួររបស់ខ្ញុំគឺពាក់ព័ន្ធនៅពេលដែលលោកស្រីនៅស្រុកបាទី មុនពេលចាកចេញពីស្រុកបាទី តើលោកស្រីធ្លាប់ឃើញមានមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមមកតំបន់លោកស្រីស្នាក់នៅនោះដែរឬទេ?

[១៥:០៦:៣២]

**ឆ៖** ចាស ខ្ញុំជម្រាប។ នៅថ្ងៃដែលពួកខ្ញុំជីកប្រឡាយ ជីកអី អ៎! លើកទំនប់ លើកអីហ្នឹងឃើញមានហ្សុីបមួយ មានអ្នកជាន់ខ្ពស់អីចឹង យើងក៏អត់បាននៅមើលយូរដែរ គេបើកឡានកាត់ពីផ្លូវជាតិលេខ៣ លើខ្នងទំនប់ហ្នឹងទៅកើត។ ដល់ទៅខាងកើត គេប្រាប់ថា ហ្នឹងហើយ តាម៉ុក។ គេថាអីចឹង។ ដូចថាគេអ្នកៗខ្សឹបខ្សៀវគ្នាក្នុងសម្ដីតិចតួចណ៎ះ។ ប៉ុន្តែ តាម៉ុក កាលនុ៎ងគាត់នៅក្មេងទេ។ ហើយឃើញមាននីរសារ ហើយនិងឡានហ្សុីបចិនហ្នឹង។ ហើយបាត់ទៅ យើងអត់ឃើញអីទៀតទេចាស។ សូមអស់។

**ស៖** តើ តាម៉ុក មកធ្វើទស្សនកិច្ចនៅតំបន់លោកស្រីហ្នឹងនៅពេលណាដែរ? ហើយតើគាត់មកតំបន់លោកស្រីស្នាក់នៅហ្នឹងគឺប្រហែលជាប៉ុន្មានថ្ងៃ ឬក៏ប៉ុន្មានខែដែរ មុនពេលដែលគេជម្លៀសប្រជាជនចេញពីបាទីទៅពោធិ៍សាត់នោះ?

**ឆ៖** តាមខ្ញុំស្មានពេលវេលាក៏មិនជាច្បាស់ ប៉ុន្តែពេលក្រោយពីកាប់ព្រៃ អ៎! ដូចថា ដាក់ជីស្រែជីអីហើយ សល់កម្លាំង គេឲ្យមកលើកទំនប់ ហើយដល់ពេលយើងកំពុងលើកហ្នឹង ឃើញមានយន្តរថយន្តហ្នឹងវា*ប៉ាស់សេ*អី ដូចថា ឆ្លងកាត់ហ្នឹង។ ហើយបានគេឆ្លងកាត់ទៅបាត់ទៅ ក្រោយមកបានមានជម្លៀស។ ក្រោយមកបានពួកខ្ញុំត្រូវធ្វើដំណើរទៅជាលើកទី២។ គេ -- ខ្ញុំឃើញមុន។

[១៥:០៨:២៣]

**ស៖** តើលោកស្រីចាំដែរឬទេថា វាមានរយៈពេលប្រហែលប៉ុន្មានដែរ មុនពេលដែលលោកស្រីត្រូវបានគេជម្លៀស គឺថាធៀបជាមួយនឹងពេលដែលលោកស្រីឃើញ តាម៉ុក នោះ?

**ឆ៖** ជម្រាបប្រសាសន៍ ខ្ញុំបានឃើញមុខគាត់អត់ច្បាស់ទេ។ ពីឃើញឡានហ្នឹងជិះទៅ ហើយពេលគាត់ទៅផុតទៅ បានមានកងគេហ្នឹង គេបញ្ជាក់ថា ហ្នឹង តាម៉ុក ហ្នឹងហើយ ប្រធានភូមិភាគហើយគេថាអីចឹង។ ហើយពេលរយៈហ្នឹងមក ប្រហែលជា ខ្ញុំមិនដឹងពិតប្រាកដទេ ប៉ុន្តែប្រហែលជា១ខែជាងអីហ្នឹង ជាង១ខែ ១ខែកន្លះអីហ្នឹង *អង់ពីរង* ចាស។ សូមទោស ប៉ុណ្ណឹងចាស ខ្ញុំមិនអាចដឹងច្បាស់។

**ស៖** សូមអរគុណលោកស្រី ដែលបានឆ្លើយបំភ្លឺទៅលើបញ្ហានេះ។ ចំណុចចុងក្រោយដែលខ្ញុំចង់សាកសួរលោកស្រី គឺពាក់ព័ន្ធទៅនឹងរយៈពេលដែលលោកស្រីចាកចេញពីភ្នំពេញ -- រស់នៅក្នុងខែមេសា ឆ្នាំ៧៥ គឺថាតើមុនខែមេសា ឆ្នាំ៧៥ហ្នឹង តើលោកស្រីមករស់នៅទីក្រុងភ្នំពេញបានរយៈពេលប្រហែលប៉ុន្មានដែរ?

**ឆ៖** មុនខែមេសា ឆ្នាំ៧០ -- មើល៍ អំមិញៗខ្ញុំតាមដានអត់ច្បាស់។ សូមម្តងទៀត មុន៧៥ ខ្ញុំ

មកនៅពីភ្នំពេញអង្កាល់ អ៊ីចឹង? ខ្ញុំសូមជម្រាបឲ្យលោកមានប្រសាសន៍សាជាថ្មី។

[១៥:១០:០៥]

**ស៖** បាទ ពិតជាត្រឹមត្រូវហើយលោកស្រី។ តើលោកស្រីមករស់នៅទីក្រុងភ្នំពេញប្រហែលជាប៉ុន្មានឆ្នាំដែរ មុនពេលដែលខែមេសា ឆ្នាំ៧៥នោះ?

**ឆ៖** ចាស សូមជម្រាបលោកប្រធាន ខ្ញុំមកនៅទីក្រុងភ្នំពេញ តាំងពីឆ្នាំ៥៩ –១៩៥៩– ខ្ញុំមកនៅរៀននៅទីក្រុងហ្នឹងរហូតដល់បានធ្វើការងារ ដល់៧៥តែម្តង ចាស។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំចំពោះលោកស្រី គឺចង់សួរលោកស្រី លោកស្រីបានពណ៌នាអំពីស្ថានភាពរស់នៅ និងម្ហូបអាហារដែលមាននៅក្នុងទីក្រុងភ្នំពេញ គឺមុនពេលដែលលោកស្រីត្រូវបានគេជម្លៀសឆ្នាំ៧៥ នោះ។ ប្រសិនបើប្រៀបធៀបទៅនឹងស្ថានភាព និងចំណីអាហារនៃការរស់នៅរបស់លោកស្រីក្រោយការជម្លៀសហ្នឹង តើពេលមុនជម្លៀស និងក្រោយការជម្លៀសហ្នឹង វាមានស្ថានភាពបែបណាដែរ?

[១៥:១១:២៤]

**ឆ៖** មុនការជម្លៀស យើងរស់នៅញុំាបាយបរិបូរ គ្រប់គ្រាន់ រៀនសូត្រ មានលទ្ធភាព ទៅរៀនធាក់កង់អីឲ្យអ៊ីចឹងដែរដូចគ្នាហ្នឹង ហើយនៅរស់នៅជាមួយបងផង ជាមួយបងប្អូនហ្នឹង ចាស រស់នៅ រៀនសូត្រ បានធ្វើការងារ ហើយបាន -- ដំបូងឆ្នាំ៦៥ ខ្ញុំជាប់ឌីប្លូម ខ្ញុំទៅរៀនបណ្តុះបណ្តាលគ្រូ គ្រូកំពង់កន្ទួត ដល់ក្រោយពីហ្នឹង ខ្ញុំចេញធ្វើការងាររដ្ឋទៀត ខ្ញុំចេញធ្វើការងាររដ្ឋ ដល់មក៧៤, ៧៥ ហ្នឹង ខ្ញុំចូលជាសាស្ត្រាចារ្យខាងអក្សរសាស្ត្រដែរ អក្សរសាស្ត្រ ចាស។ ដូច្នេះ ការរស់នៅសប្បាយទេ ខ្ញុំអត់មាន ដូចថា ខ្វះខាតអីទេ ល្មមមួយរស់ធម្មតា។ មានលទ្ធភាពរៀនសូត្រ មានលទ្ធភាពសប្បាយចិត្ត មានកូន សប្បាយចិត្ត ថែរក្សាកូនបាន មានលុយកាក់អីត្រឹមត្រូវ អត់មានខ្វះ ចាស។ ខុសអំពីអានេះ ពេលចេញមកហ្នឹង ទាំងអស់ ចោលអីវ៉ាន់ទាំងអស់នៅភ្នំពេញ។ ពេលយើងចេញ៧៥ គឺចោលអស់រលីង ទាំងផ្ទះ ទាំងរបស់ទាំងរបរនៅលើផ្ទះហ្នឹង ដែលយើងសម្រាប់ប្រើប្រាស់រាប់ឆ្នាំមកហ្នឹង ចាស។

[១៥:១២:៥៧]

**លោក ឌេល លីសាក់៖**

សូមអរគុណលោកស្រីដែលបានឆ្លើយតបទៅនឹងសំណួររបស់ខ្ញុំ។

លោកប្រធានខ្ញុំមិនមានសំណួរអ្វីបន្តទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ បាទ ជាបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

**លោក ហ្សាស្តេ ប៉ោ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក ហ្សាស្តេ ប៉ោ៖**

**ស៖** សូមជម្រាបសួរលោកស្រី សុខា។ ខ្ញុំឈ្មោះ ហ្សាស្តេ ប៉ៅ។ ខ្ញុំជាមេធាវីការពារក្តីអន្តរ-ជាតិរបស់លោក នួន ជា ហើយខ្ញុំមានសំណួរមួយចំនួន ដើម្បីសាកសួរទៅលើលោកស្រីនៅថ្ងៃនេះ។ ខ្ញុំនឹងមិនចំណាយពេលៗឲ្យលើសពី១៥នាទីនោះឡើយ។ ខ្ញុំនឹងនិយាយឲ្យបានយឺតៗ ហើយប្រសិនបើលោកស្រីមានបញ្ហា ឬក៏មានមិនយល់ច្បាស់អំពីសំណួររបស់ខ្ញុំ សូមលោកស្រីជម្រាបមកខ្ញុំ។ ខ្ញុំសូមចាប់ផ្តើម ដោយសួរលោកស្រីពាក់ព័ន្ធទៅនឹងភ្នំពេញ មុនខែមេសា ឆ្នាំ៧៥។

ថ្ងៃនេះ លោកស្រីបានបញ្ជាក់ថា "មានមនុស្សជាច្រើនមកស្នាក់នៅផ្ទះរបស់លោកស្រី ដែលក្នុងនោះ រួមមានសាច់ញាតិមកពីខេត្តកំពង់ស្ពឺផងដែរ"។ តើខ្ញុំនិយាយបែបនេះ ត្រឹមត្រូវដែរឬទេ?

**លោកស្រី ទឹង សុខា៖**

**ឆ៖** ចាស ត្រឹមត្រូវ ចាស។

[១៥:១៤:៤៥]

**ស៖** តើសាច់ញាតិដែលមកពីខេត្តកំពង់ស្ពឺហ្នឹង គាត់មកស្នាក់នៅផ្ទះរបស់លោកស្រីចាប់តាំងពីពេលណាមកដែរ លោកស្រីអាចប្រាប់បានដែរឬទេ?

**ឆ៖** ពីដំបូង សូមទោស សូមជម្រាប។ ពីដំបូងលោកមាន អាក្មួនកំលោះមួយមកសម្រាកនៅផ្ទះខ្ញុំដើម្បីរៀន ពីព្រោះខាងត្រាំខ្នារហ្នឹង ៗវាមានសង្គ្រាមកប៉ាល់ហោះទៅ ខ្មែរក្រហមទៅអ៊ីចឹង ចេះច្រឡូកច្រឡំ អាក្មួនកំលោះហ្នឹង ក៏ខ្ញុំឲ្យមករៀននៅភ្នំពេញមក មករៀននៅសាលាក្បាលថ្នល់។ ម្តាយហ្នឹងឲ្យមក ដល់បន្តិចទៅ ដល់បានក្រោយពីហ្នឹង ឮថាយន្តហោះទម្លាក់គ្រាប់បែកលើផ្ទះវាហើយ ផ្ទះវានៅឯខាងសន្ទ្រានហ្នឹង ទម្លាក់ហើយងាប់កូនអស់ប្អូន។ ក៏ខ្ញុំបាត់ដំណឹងខាងនុំង ខ្ញុំអត់ដែលដឹងតាមដានអីទេ អាក្មួនកំលោះនៅនឹងខ្ញុំទៅ។ ហើយដល់បានប្រហែលជា១ខែកន្លះ ក្រោយមកទៀត បានលេចឪពុក

ហើយនិងម្ដាយវាហ្នឹងរត់មកជាមួយនឹងកូនបីនាក់ ប្រុសពីរ ស្រីមួយ។ មកនៅនឹងផ្ទះខ្ញុំហ្នឹងតែម្ដង មកគេងមកគ្រែអីឲ្យគាត់សម្រាកអីចឹង។ នៅខាងលើជាមួយខ្ញុំ។ គាត់មិនអាចទៅស្រុកវិញ ព្រោះផ្ទះគាត់រលាយទៅជាខ្ទេចខ្ទីអស់ហើយ ហើយកូនបាត់ស្លាប់តែមួយពេលអស់បីបួននាក់ទៀត គាត់បាត់ស្មារតីគាត់បាក់ស្បាត គាត់លែងចង់ទៅវិញ គាត់មកនៅផ្ទះខ្ញុំ ដោយសារមានកូនប្រុសមួយនៅខ្ញុំដែរ។ ដូច្នេះគាត់អ្នកកំពង់ស្ពឺហ្នឹង គឺមួយគ្រួសារហ្នឹងចាស។

[១៥:១៦:៣៥]

**ស៖** លោកស្រីបាននិយាយថា កូនប្រុសនោះបានមកស្នាក់នៅផ្ទះលោកស្រី តើលោកស្រីចាំទេថាកូនប្រុសហ្នឹង ឬក៏បុរសម្នាក់ហ្នឹងមកស្នាក់នៅផ្ទះលោកស្រីហ្នឹងនៅឆ្នាំណាដែរ? ចាប់តាំងពីពេលណាមកដែរ?

**ឆ៖** វាមកនៅថ្នាក់ទី៤ វាមក វាចូលថ្នាក់ទី៤នៅសាលាក្បាលថ្នល់ ហើយដល់ពេលថ្នាក់ទី៥ វាបែកអីចឹងទៅ អ៎! ទី៤ ហើយទី៣។ កាលជំនាន់នុ៎ង វាអត់ទាន់បានប្រលងឌីប្លូមផងចាស វាត្រូវបែក។ ដូច្នេះវាមកនៅរយៈជាមួយខ្ញុំតែប្រហែលជាង១ឆ្នាំហ្នឹង ឬក៏ជិត២ឆ្នាំហ្នឹងចាស។ ថ្នាក់ទី៤ ហើយនិងទី៣ ដើម្បីប្រលងឌីប្លូមចាស។ ប្រហែលជាឆ្នាំ៧០ សូមទោស ចិតសិបប៉ុន្មានអីចេះកូនខ្ញុំចូល ប្រហែលជាឆ្នាំ៧៤ វាមកហ្នឹង កូនហ្នឹង។ វាមកក្នុងឆ្នាំ៧៤ ហ្នឹង ៧៥បែក ចាស។ តែប៉ុណ្ណឹងបានទេ លោកជម្រាបលោកមេធាវី?

[១៥:១៧:៥៥]

**ស៖** សូមអរគុណលោកស្រីដែលបានឆ្លើយ។ លោកស្រីក៏បានបញ្ជាក់អំពីមនុស្សដទៃទៀតដែលមកស្នាក់នៅផ្ទះលោកស្រី ដែលមកពីទួលគោក តើលោកស្រីចាំដែរឬទេ ថាពួកគាត់ហ្នឹង គាត់មកស្នាក់នៅផ្ទះលោកស្រីហ្នឹងនៅឆ្នាំណាដែរ?

**ឆ៖** ចាស អ្នកមកពីទួលគោកហ្នឹង គឺថ្ងៃ១៦ មេសា គឺបានមកសម្រាកតែ១យប់ទេ ដែលបែកខ្ញែកគ្នាអស់ទៅហ្នឹង។ នេះមកជ្រកកោនដោយសារអង្កាល់ហ្នឹង គេរើពីខាងជើងនុ៎ងមកខ្លាំង វាមានប្រយុទ្ធគ្នាខាងកប់ស្រូវ ខាងអី គេទម្លាយខ្សែត្រៀមខាងហ្នឹងហើយ គ្នានៅៗគេហៅបឹងប៉ាយាបហ្នឹងត្រូវរត់មកនៅខ្ញុំពីថ្ងៃ១៦។ ចាស ១៦ ទេ ចាស។ បានមួយរយៈ បាន១ថ្ងៃ១យប់ទេ។

**ស៖** នៅក្នុងតំបន់ដែលលោកស្រីរស់នៅក្នុងទីក្រុងភ្នំពេញនោះ ថាតើមានមនុស្ស ឬក៏មានជនភៀសខ្លួនជាច្រើនដែលគាត់មកស្នាក់នៅ គឺអ្នកមកពីខេត្តមកស្នាក់នៅតំបន់លោកស្រីហ្នឹង តើមានមនុស្ស

ច្រើនដែរឬទេ?

[១៥:១៩:២១]

**ឆ៖** ចាស លោកមានមនុស្សច្រើន ប៉ុន្តែមិនមែននៅនឹងផ្ទះខ្ញុំទេ គេទៅជួលផ្ទះក្បែរហ្នឹងនៅទៅ។ ព្រោះមិនអាចធ្វើការរកស៊ីអីកើតទៀតទេ ពេលសង្គ្រាមនៅខាងត្រាំខ្នារ នៅខាងអីហ្នឹង វាកាន់តែសន្ធាប់ ហើយខ្លាចផង នាំគ្នាមកទៅ។ អ្នកណាមានលទ្ធភាពទៅជួលផ្ទះគេនៅក្បែរៗហ្នឹងទៅ មកព្រោះមាន ឪពុកមានៅម្តុំហ្នឹងហើយ គ្នាជាទីពឹងហើយ ប្រាប់ថាទៅជួលនេះនៅទៅ ឯងធ្វើម៉េចធ្វើឱ្យបានស្រួល ទៅ។ ក៏គេអត់នៅលើដំបូលផ្ទះជាមួយខ្ញុំ ក្នុងផ្ទះជាមួយខ្ញុំបានដែរ។ អ៊ីចឹងគេនៅតាមផ្ទះផ្សេងទៀត។ ច្រើនៗណាស់ចាស មិនតិចទេចាស។ រត់មក មិនមែនតែពីត្រាំខ្នារ ពីកោះធំ ពីអីក៏មានដែរ ឡើងមក នៅហ្នឹង ម្តុំៗហ្នឹង អ្នកប្លែកៗ។

**ស៖** លោកស្រីបាននិយាយថា មានមនុស្សមកពីក្រៅទីក្រុងភ្នំពេញ មកស្នាក់នៅជាមួយសាច់ញាតិនៅទីក្រុងភ្នំពេញ។ ហើយលោកស្រីក៏បានបញ្ជាក់ថា អ្នកដែលមកពីក្រៅទីក្រុងភ្នំពេញហ្នឹងបាន មកជួលផ្ទះនៅភ្នំពេញផងដែរ។ តើលោកស្រីដឹងដែរឬទេ ថាមានជនភៀសខ្លួនដែលគ្មានលុយជួលផ្ទះ ឬក៏មិនមានសាច់ញាតិនៅទីក្រុងភ្នំពេញ ដើម្បីមកស្នាក់នៅជាមួយនោះ ដូច្នេះហើយពួកគាត់ត្រូវរស់នៅ ក្នុងស្ថានភាពផ្សេង។ តើលោកលោកស្រីដឹងថាមានមនុស្សបែបនោះដែរឬទេ?

[១៥:២០:៥៤]

**ឆ៖** ចាស ប្រាកដជាមានលោក។ អ្នកខ្លះមកស្រវារកធាក់ស៊ីក្លូ ដើម្បីបានលុយចិញ្ចឹមមាត់រាល់ ថ្ងៃទៅ ទិញម្ហូប ទិញអីទៅ អត់មានសម្បត្តិទ្រព្យអីច្រើនមកទេ។ មកទទេៗខ្លួនហ្នឹង ពេលដែលមកផ្លាស់ ខ្លួនមកនៅម្តុំហ្នឹងចាស។ មកនៅម្តុំហ្នឹង ជាសាច់ញាតិខ្ញុំ ខ្ញុំដឹងថាបងមួយហ្នឹង គាត់ធាក់ស៊ីក្លូយកលុយ ទប់ទល់ ព្រោះវាសង្គ្រាមហ្នឹងវាធ្ងន់ធ្ងរហើយ គ្នាអត់បានយកដើមឈើ ដើមព្រៃមកកើតទេ ពីព្រោះ អ្នកស្រែមានតែអ៊ីចឹង។ ដល់អ៊ីចឹងពិបាកណាស់ ជួនកាលផ្ទះយើងអាចចែករំលែកអីបន្តិចបន្តួចទៅឱ្យគ្នា វិញបាន ក៏ឱ្យទៅ។ ដូចចេញពីភ្នំពេញអីហ្នឹង អង្ករអីមកទិញយកពីខ្ញុំដោយសារវា ខ្ញុំទិញទុកហើយ ដល់ពេលចេញទៅ ខ្ញុំថាអ្នកណាយកបានទៅយកទៅកូន។ ដឹកឱ្យតែរួចទៅ យកទៅស៊ីតាមផ្លូវ អាហ្នឹង ជាអង្ករដែលខ្ញុំទិញទុក មានតែជួយចែករំលែកគ្នាប៉ុណ្ណឹងទេ។ ហើយគេរស់នៅពិបាកណាស់ អ្នកដែល រត់មកហ្នឹងចាស។

[១៥:២២:០១]

**ស៖** ខ្ញុំសាកសួរលោកស្រី ថាតើលោកស្រីដឹងដែរឬទេថាមានមនុស្សដែលមកពីភូមិ ឬក៏មកពីឃុំដែលនៅក្រៅភ្នំពេញ ហើយគាត់មិនអាចយកអ្វីមកតាមខ្លួនចូលទីក្រុងភ្នំពេញទេ? តើពួកគាត់ហ្នឹងអាចយកស្រូវអង្ករពីជនបទ យកមកតាមខ្លួនចូលមកភ្នំពេញបានដែរឬទេ?

**ឆ៖** ចំពោះអ្នកណាដែលជាមិនមែនក្រុមញាតិបងប្អូនដែលមកក្បែរខ្ញុំអី ក៏ខ្ញុំមិនសូវដឹងដែរ ប៉ុន្តែគ្រាន់ឃើញមនុស្សជនភៀសខ្លួនពីក្រៅចូលមកក្នុងមានច្រើន ត្រង់គេរស់នៅស្ថានភាពប៉ុន្មាន ខ្ញុំអត់ដឹងដែរ ព្រោះខ្ញុំជាប់តែមើលការខុសត្រូវ ហើយនិងរៀនសូត្រអីខ្លួនដែរ។ ខ្ញុំជួយបានតែអាកូនប្រុស និងបងស្រីហ្នឹង ហើយនិងមួយយប់ដែលគេរត់មកហ្នឹង។ យើងឲ្យមុង យើងឲ្យសម្លៀកបំពាក់គេទៅអាមួយយប់មុនបែកហ្នឹង ដូច្នេះ ខ្ញុំមិនដឹងទាំងអស់ទេ ការខ្វះខាតរបស់គេចាស។

**ស៖** នៅពេលដែលលោកស្រីនិយាយថា លោកស្រីចែករំលែកអង្ករជាមួយមនុស្ស -- ជាមួយអ្នកដទៃហ្នឹង គឺថាដោយសារពួកគាត់មិនមានស្រូវអង្ករខ្លួនឯង ឬក៏យ៉ាងម៉េច?

**ឆ៖** គាត់អត់មានអង្ករយកពីស្រែមកច្រើនទេ យ៉ាងច្រើនគាត់បានដូចថាមួយការ៉ុង កន្លះការ៉ុងអី។ រួចមករាប់ខែទៅ វាតែងតែញ៉ាំអស់ហើយ។ ដូច្នេះ គាត់ត្រូវប្រឹងប្រែងស្រវារកដោយខ្លួនគាត់។ ខ្ញុំក៏ជាជីវភាពជាមន្ត្រីកណ្ដាលទេ។ ដូច្នេះវាអាច ខ្ញុំ គេអត់មានសុំយើងទេ គេខំរកៗដោយខ្លួនគេ។ ខ្ញុំជួយចិញ្ចឹមកូនបានមួយអីអ៊ីចឹង ហើយអ្នកផ្សេងទៀត យើងមិនមែនបានយកទៅឲ្យគេគ្រប់គ្នាទេ ខ្ញុំអត់មានលទ្ធភាពទេចាស។

[១៥:២៤:២៧]

**ស៖** ខ្ញុំយល់អំពីបញ្ហាទាំងអស់នេះ។ មនុស្សជាច្រើនបានផ្ដល់សក្ខីកម្មអំពីបញ្ហាតម្លៃអង្ករដែលវាកើនឡើងខ្ពស់មុនថ្ងៃ១៧ មេសា ឆ្នាំ១៩៧៥នោះ។ តើលោកស្រីអាចប្រាប់បានដែរឬទេ តាមការចងចាំរបស់លោកស្រី ថាតើតម្លៃអង្ករពិតជាកើនឡើងខ្ពស់មុនខែមេសា ឆ្នាំ៧៥មែន។ តើមែនដែរឬទេ?

**ឆ៖** ចាស លោកមិនមែនតែអង្ករទេ អ្វីក៏ឡើងខ្លាំងដែរក្នុងពេលដែលស្រុកសង្គ្រាមជាប់ដៃគ្នា គឺអង្ករហ្នឹងប្រាកដជាឡើង ប៉ុន្តែខ្ញុំវាមានមុខការខ្ញុំជាអ្នកធ្វើការ គេបើកមកតាមអ៊ីឡូ។ អ៊ីឡូហ្នឹងប្រជាជនទៅទិញតាមអ៊ីឡូហ្នឹង។ គេហៅថា អ៊ីឡូហ្នឹងជាប្លុក ព្រោះជំនួយអាមេរិកាំងមក គេឲ្យចែកតាមក្រុម ១០ខ្នង ៥០ខ្នងអីហ្នឹង គេទិញយកមក។ ហើយខ្ញុំទិញនៅតាមសាលាក៏ទិញ ហើយទិញអាអ៊ីឡូហ្នឹងបានខ្លះៗតាមបញ្ជីគ្រួសារហ្នឹង ខ្ញុំមាននៅសល់ប្រហែលអង្ករពីរបីបាវហ្នឹងដែលនៅលើផ្ទះចាស។ ដូច្នេះវាថ្លៃពិតជាថ្លៃហើយ សូមលោកជ្រាប។ ថ្លៃណាស់ ស្រុកសង្គ្រាម។

**សៈ** តើលោកស្រីចង់បញ្ជាក់ថា លោកស្រីទិញអង្ករដែលគេបែងចែកដោយពួកអាមេរិកាំង តើលោកស្រីចង់មានប្រសាសន៍បែបនេះមែនដែរឬទេ?

[១៥:២៦:១២]

**ផៈ** ចាស ខ្ញុំចង់ថាដែលគេបែងចែកអង្ករតាមៗក្រុម ១០ខ្នង វានៅក្នុងភ្នំពេញហ្នឹង មានក្រុម ១០ខ្នង ៥០ខ្នង ហើយយើងនៅក្នុងក្រុមណា គេទៅទិញពីក្រុមហ្នឹង អង្ករហ្នឹង។ ហើយបើយើងចង់ទិញក្រៅជាឯកជនផ្សេងៗទៀត សុទ្ធតែលួចលាក់ អ៊ូ! មិនមែនលួចលាក់ទេដូចថា ស្គាល់គេអ្នកណាមានលុយច្រើនទិញបានច្រើន ស្រេចតែគេ។ អាហ្នឹងអ៊ីចឹង។ ហើយខ្ញុំវាមានពេលខ្លះក៏ទិញតាមអ៊ីឡូ ពេលខ្លះខ្ញុំដឹកពីសាលារៀន បើកតាមសាលារៀនហ្នឹង បើកហ្នឹងប្រាក់ខែយើងបង់ឲ្យទៅ កាត់តាមហ្នឹងមក។ អ៊ីចឹងខ្ញុំក៏គ្មានអ្វីក្រៅជម្រាបបន្ថែមពីហ្នឹង ខ្ញុំដឹងអត់អស់ទេពីរឿងការបែងចែកហ្នឹង អាហ្នឹងដឹងថាវាថ្លៃអ៊ីចឹងហើយអង្ករ។ ចាស អង្ករ ប្រេងកាតក៏ថ្លៃ អ៊ំ! ប្រេងសាំង -- ប្រេងកាត នាំគ្នាទៅបន្តុកន្ទុយគ្នាទិញប្រេងកាត។ ចាស សូមទោស វាច្រើនមុខណាស់ចាស។

**សៈ** ឥឡូវនេះ ខ្ញុំយល់ច្បាស់ជាងមុន ដែលថាមានទីតាំងជាច្រើននៅក្នុងប្លុកនីមួយៗ ដែលគេលក់អង្ករនោះ។ ប៉ុន្តែខ្ញុំគិតថា ខ្ញុំឮលោកស្រីនិយាយថាប្លុក ឬក៏តំបន់នីមួយៗគឺបង្កើតឡើងដោយពួកអាមេរិក។ ដូច្នេះសំណួររបស់ខ្ញុំចង់សួរថា ថាតើចំណុចៗដែលលក់អង្ករហ្នឹង គឺបង្កើតឡើងដោយពួកអាមេរិក ឬមួយក៏ទីតាំងហ្នឹងនេះគេលក់អង្កររបស់អាមេរិក?

[១៥:២៨:០៥]

**ផៈ** តាមដែលខ្ញុំទិញមកមានអង្ករហ្នឹងជាជំនួយរបស់ -- គ្រាប់អង្ករមកពីក្រៅ មិនមែនអង្ករអ្នកបាត់ដំបងទេ អង្ករជំនួយ គេហៅ "អង្ករជំនួយ"ៗចាស។ ហើយគេបែងចែកលក់ដូរមិនដឹងមកពីអាមេរិកាំងអ្នកបែងទេ ខ្ញុំអត់យល់ទេ ខ្ញុំអត់ដឹងទេ ខ្ញុំដឹងតែមានក្រុមអ៊ីឡូហ្នឹងនៅត្រង់ណា យើងទិញតាមត្រង់ហ្នឹង គេឲ្យយើងទិញតាមត្រង់ហ្នឹងចាស។

**សៈ** លោកស្រីបានបញ្ជាក់ច្បាស់ហើយ ដូច្នេះសូមអរគុណលោកស្រី។ លោកស្រីបានមានប្រសាសន៍ថា "លោកស្រីមានការងារល្អមុនពេលជម្លៀសពីទីក្រុងភ្នំពេញ។ លោកស្រីមានលុយកាក់គ្រប់គ្រាន់ ហើយលោកស្រីអាចទិញអង្ករ ទិញម្ហូបអាហារ ទិញប្រេងកាត ប្រេងសាំង ទោះបីថាតម្លៃវាឡើងខ្ពស់ក៏ដោយ។ គឺថាទោះបីថាតម្លៃនោះវាខ្ពស់កប់ពពកក៏ដោយ"។ តើខ្ញុំសន្និដ្ឋានដែលថាជនភៀសខ្លួនភាគច្រើនដែលមកពីខេត្ត មកពីក្រៅទីក្រុងភ្នំពេញហ្នឹង គឺមិនមានហិរញ្ញវត្ថុ មិនមានលុយកាក់ដើម្បី

ទិញស្រូវ អង្ករនោះដែរឬទេ?

ដោយសារព្រះរាជអាជ្ញាគាត់ងើបឈរដូច្នេះខ្ញុំស្នើសុំឲ្យលោកស្រីផ្អាកបន្តិចសិន ប៉ុន្តែខ្ញុំចង់ឲ្យលោកស្រីផ្តល់យោបល់ ផ្តល់ចម្លើយក្នុងនាមជាបទពិសោធន៍ផ្ទាល់ខ្លួនរបស់លោកស្រី មិនមែនជាសាក្សីនោះទេ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

[១៥:២៩:៥៦]

**លោក ឌេល លីសាក់៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ព្រោះថាគាត់ប្រើប្រាស់ពាក្យដែលថា តើអាចសន្និដ្ឋានបានដែរឬទេ ហើយគាត់ស្នើសុំឲ្យដើមបណ្តឹងរដ្ឋប្បវេណីគាត់ធ្វើសេចក្តីសន្និដ្ឋានទៅលើជនភៀសខ្លួនដទៃទៀត ដូច្នេះ ខ្ញុំគិតថាគួរតែជាការកត់សម្គាល់។ ប្រសិនបើជាការកត់សម្គាល់របស់ដើមបណ្តឹងរដ្ឋប្បវេណី ខ្ញុំមិនមានការជំទាស់អ្វីនោះទេ។

**លោក ហ្សាស្តេី ប៉ោ៖**

ខ្ញុំសូមរៀបចំសំណួរខ្ញុំសាជាថ្មី។

**សួរដោយលោក ហ្សាស្តេី ប៉ោ៖**

**ស៖** លោកស្រី សុខា លោកស្រីបានពិព័ណនាអំពីការទំនាក់ទំនង -- អំពីទំនាក់ទំនងរបស់លោកស្រី ជាមួយនឹងជនភៀសខ្លួនដែលមកពីក្រៅទីក្រុងភ្នំពេញ ហើយលោកស្រីបានចែករំលែកនូវស្រូវអង្ករ ហើយចែករំលែកនូវមុងជាមួយពួកគាត់។ ដូច្នេះ បានន័យថាលោកស្រីបានធ្វើទំនាក់ទំនងលោកស្រីធ្លាប់និយាយជាមួយប្រជាជនដែលជម្លៀសចូលមកទីក្រុងភ្នំពេញនោះ។ ផ្អែកទៅតាមការដឹងរបស់លោកស្រីផ្ទាល់ តើលោកស្រីអាចនិយាយបានដែរឬទេថា ប្រជាជនដែលគេចចូលមកទីក្រុងភ្នំពេញហ្នឹង គាត់មានលទ្ធភាពទិញស្រូវអង្ករ ទិញម្ហូបអាហារដែលមានតម្លៃខ្ពស់កប់ពពកនោះបានដែរឬទេ?

[១៥:៣១:១៦]

**ឆ៖** លោកមានប្រសាសន៍សួរមកខ្ញុំ ខ្ញុំមិនច្បាស់ទេ ពីព្រោះខ្ញុំមិនមែនជាអ្នកគ្រប់គ្រងអ្នកភៀសខ្លួនទេ ខ្ញុំគ្រប់គ្រងតែញាតិតិចតួចមកពីនេះមួយគ្រួ ពីរគ្រួ អ៊ីចឹងខ្ញុំចេះតែចែកបាន ដូចជា អារី មួយដែល

គ្នារត់ពីទួលគោកមក ខ្ញុំឲ្យមុងមួយទៅ មុងផ្ទះខ្ញុំហ្នឹង ដែលខ្ញុំធ្លាប់ប្រើហ្នឹង។ ខ្ញុំមិនមែនទៅបានរបស់ច្រើន អីទៅចែកគេទេ គឺថាគ្នាអត់មានអាវទម្ងន់មក ខ្ញុំទៅរើអាវទម្ងន់របស់ខ្ញុំឲ្យទៅគ្នាពាក់ទៅ។ អាហ្នឹងខ្ញុំ ចែករំលែកបែបហ្នឹង។ ចាស ខ្ញុំមិនបានអង្គរណារាប់គោនអី រាប់បាវអីទុកឲ្យទេ ប៉ុន្តែដល់ថ្ងៃចេញនេះ! ថ្ងៃចេញពីភ្នំពេញនេះ! ដែលខ្ញុំបានឲ្យ អាខន អ្អែង បងប្អូនអ្អែង ប្រាំមួយ-ប្រាំពីរនាក់, ប្រាំ-ប្រាំមួយនាក់ អ្អែងហ្នឹង អ្អែងយកទៅមួយបាវទៅ។ អ្អែងដាក់ដឹកកង់ធ្វើម៉េចឲ្យតែបាន។ ចំពោះខ្ញុំយកប៉ុណ្ណេះ ខ្ញុំគ្មាន កម្លាំងយកច្រើនទេ សម្រាប់ខ្លួនខ្ញុំ។ ខ្ញុំអាណិតវា ព្រោះម្ដាយវាដាច់ជើងដោយសារគ្រាប់ផ្លោងពេលព្រឹក ថ្ងៃ១៧ ហ្នឹង។ ប្អូនឈឺទៀត ហើយអត់មានលុយច្រើនទៀត ឪពុកធាក់ស៊ីក្លូទៀត អ៊ីចឹងយកទៅ ចែករំលែកបានតែប៉ុនៗហ្នឹងទេ អត់មានអ្វីច្រើនទេ ខ្ញុំជាគ្រូបង្រៀន ប្ដីជាសាស្ត្រាចារ្យមានមែន ប៉ុន្តែមិនមែនចាក់ចូលហូរហៀរទេ គឺលុយសម្រាប់គ្រប់គ្រងគ្រួសារខ្ញុំ តែចែករំលែកឲ្យគេផងដែរ។

[១៥:៣២:៣២]

ដល់ពេលគាត់ដាច់ជើង ខ្ញុំចែករំលែកលុយ ព្រោះគាត់គ្មានលុយឲ្យពេទ្យមកដេរជើងឲ្យគាត់។ ត្រង់ហ្នឹងសូមលោកមេធាវីមេត្តាជ្រាប ចាស។ ខ្ញុំមិនដឹងអ្នកណាទិញបានស្អីញ៉ាំ មិនបានអីញ៉ាំគ្រប់គ្នាទេ នៅក្រៅពីផ្ទះខ្ញុំ នៅក្រៅពីដំបូលផ្ទះខ្ញុំ។ ដែលគេរត់មក គេនៅអីណាអីណី ខ្ញុំអត់ទៅចែកគេឯណាឆ្ងាយពីផ្ទះខ្ញុំហ្នឹងទេ។ ដែលផ្ទះខ្ញុំក្នុងរង្វង់គ្រួសារហ្នឹងដែលខ្ញុំចែករំលែកបាន ព្រោះគ្មានសមត្ថភាពដែរដូចគ្នា តែខ្ញុំត្រូវតែមានប្រាក់ខ្លះៗសន្សំសំចៃបន្តិចបន្តួចៗ បង្ការការខ្វះខាតៗ។ ចាស ជម្រាបប្រសាសន៍លោកប៉ុណ្ណឹង។

**ស៖** សូមអរគុណលោកស្រី ខ្ញុំយល់អ្វីដែលលោកស្រីចង់និយាយ។ ខ្ញុំមានសំណួរពីរបីបន្ថែមទៀតទាក់ទងទៅនឹងជនភៀសសឹក នៅពេលនោះតើលោកស្រីមានបានឮអំពីជនភៀសសឹកដែលស្នាក់នៅសណ្ឋាគារកាំបូឌីយ៉ាណាដែរឬទេ?

**ឆ៖** ដែលៗចាស ឮដែលឮម្ដង ឮដូចថាមានភៀសសឹកមកដែរ ប៉ុន្តែខ្ញុំអត់មានលទ្ធភាពច្រើនយកទៅចែកនៅប្អូកនុងទេ ខ្ញុំអត់មានទេ។ មានតែយកទៅវត្តប្រយូវង្ស ជនភៀសសឹក ម្ដាយខ្ញុំថាកូនអើយមានអីបន្តិចៗយកមក ដល់អ៊ីចឹងខ្ញុំឲ្យគាត់ទៅៗ ទៅវត្តប្រយូវង្សហ្នឹងចែកទៅ បានជាអាវមួយជាអាវពីរអីស្រេចតែហ្នឹងទៅ គាត់ថាធ្វើបុណ្យអ៊ីចឹង។ ដូច្នេះ ខ្ញុំអត់មានសោហ៊ុយណាច្រើនទៅទេ មានតាមលទ្ធភាពរបស់ខ្ញុំ។ ខ្ញុំសូមជម្រាបតែប៉ុណ្ណឹង។

[១៥:៣៤:១៨]

**ស៖** សូមអរគុណ។ មុនពេលដែលខ្ញុំបន្តទៅចំណុចមួយទៀត ខ្ញុំចង់បញ្ជាក់ឲ្យបានច្បាស់។ ខ្ញុំមិនមែនចង់និយាយថាលោកស្រីមិនបានជួយដល់ប្រជាជននោះទេ ប៉ុន្តែលោកស្រីបានជួយទៅតាមអ្វីដែលលោកស្រីអាចជួយទៅបាន។ នេះគឺជារឿងដ៏ល្អបំផុត។ អ្វីដែលខ្ញុំចង់សាកសួរលោកស្រី គឺគ្រាន់តែចង់ដឹងអំពីទិដ្ឋភាពជាទូទៅ ចង់ដឹងពីស្ថានភាពជាទូទៅរបស់ជនភៀសសឹកដែលមកនៅទីក្រុងភ្នំពេញ ដូច្នេះ សូមលោកស្រីមេត្តាកុំគិតថា ការសាកសួររបស់ខ្ញុំជាការចោទប្រកាន់ ឬក៏ជាការវាយតម្លៃទៅលើអាកប្បកិរិយា ឬក៏សន្តានចិត្តរបស់លោកស្រីអ្វីឲ្យសោះ។ ដូច្នេះ ខ្ញុំចង់បញ្ជាក់ឲ្យលោកស្រីយល់អំពីចេតនារបស់ខ្ញុំ។ ពាក់ព័ន្ធទៅនឹងជនភៀសសឹកនៅសណ្ឋាគារកាំបូឌីយ៉ាណានោះ លោកស្រីបាននិយាយថា លោកស្រីបានឮអំពីបញ្ហាទាំងអស់នេះ។ តើលោកស្រីបានឃើញអំពីស្ថានភាពរស់នៅរបស់ពួកគេ នៅក្នុងសណ្ឋាគារកាំបូឌីយ៉ាណា ឬក៏នៅជុំវិញសណ្ឋាគារកាំបូឌីយ៉ាណាហ្នឹងដែរឬទេ?

**ឆ៖** ចាស ខ្ញុំអត់បានទៅដល់កាំបូឌីយ៉ាណា ទេ ព្រោះផ្ទះខ្ញុំនៅទួលទំពូង មានតែម្ដាយខ្ញុំទៅធ្វើបុណ្យនៅវត្តប្រយូវង្ស គាត់ប្រាប់ថា "ជនភៀសសឹកច្រើនណាស់ កូនហើយ អត់ណាស់"។ អ៊ីចឹង ក៏ខ្ញុំពេលគាត់ទៅវត្ត ឲ្យទៅ គាត់យកទៅចែកយ៉ាងម៉េចៗស្រេចលើកគាត់។ ហើយខ្ញុំអត់បានទៅខ្លួនឯង ព្រោះខ្ញុំខ្លាចខ្លាំងណាស់ ដែលពេលគេផ្ដោងគេអី ខ្ញុំមិនសូវបានចេញទៅណា ណាមួយខ្ញុំជាប់រៀនផង ចាស។ ក្នុងឆ្នាំនុំង គឺខ្ញុំកំពុងប្រឹងប្រែងរៀនសូត្រទេ មិនមានឱកាសដើរលេង ទៅអើតនេះបន្តិច ទៅអើតនោះបន្តិច ខ្ញុំអត់មានអ៊ីចឹងទេ។

[១៥:៣៦:១៣]

**ស៖** តើលោកស្រីដឹងដែរឬទេ ថាមានការជួយ ឬក៏ភ្នាក់ងារសង្គ្រោះដែលធ្វើការងារដើម្បីធ្វើជួយសង្គ្រោះជនភៀសសឹកនៅទីក្រុងភ្នំពេញដែរឬទេ នៅពេលនោះ?

**ឆ៖** សូមទោស កន្លែងហ្នឹង ខ្ញុំដូចអត់ដឹងគេចាត់ចែងយ៉ាងម៉េចទេ ខាងផ្នែកសុខាភិបាល ខាងផ្នែកក្រសួងកាកបាតក្រហមអី គេមិនដឹងចែកយ៉ាងម៉េចទេ ប៉ុន្តែគ្រាន់តែថា មានប្រកាសតាមវ៉ាដ្យូ រកអំណោយឈាម អ្នកណាបានធ្វើអំណោយឈាម ព្រោះត្រូវរបួស ត្រូវអីអ៊ីចឹង គេទៅធ្វើអំណោយឈាមទៅ។ គេអ្នកណាមានលទ្ធភាព គេក្លាហាន ហើយក៏សុខភាពគេល្អ គេធ្វើអំណោយឈាម ប៉ុន្តែត្រង់ថា តើមានរចនាសម្ព័ន្ធណាទៅជួយហ្នឹង គឺខាងកាកបាតក្រហម ឬក៏ក្រសួងសង្គមកិច្ចអីទេ។ ខ្ញុំខាងគ្រូបង្រៀន ចាស។

**ស៖** លោកស្រីបានបញ្ជាក់ថា សមាជិកគ្រួសាររបស់លោកស្រីបានឃើញជនភៀសសឹកនៅតាមវត្តមួយចំនួន ហើយនិងជនភៀសសឹកដែលនៅជុំវិញសណ្ឋាគារកាំបូឌីយ៉ាណា តើលោកស្រីដឹងដែរឬទេ ថាមានទីតាំងណាផ្សេងទៀតដែលមានជនភៀសសឹកស្នាក់នៅ ក្រៅពីទីតាំងពីរដែលខ្ញុំរៀបរាប់ពីខាងលើកនោះ តើមានទីតាំងផ្សេងទៀតទេ ក្នុងទីក្រុងភ្នំពេញ?

**ឆ៖** ខ្ញុំអត់សូវដឹងផង ចាស រឿងហ្នឹង។ អាហ្នឹងខ្ញុំភ្លេចអស់ហើយ វាច្រើនរឿងទៅ ខ្ញុំក៏មិនបានតាមដានអីថា កន្លែងណាខ្លះៗ ប៉ុន្តែដឹងថាមនុស្សភៀសមកហ្នឹង វាកន្លែងសង្គ្រាម ដល់ពេលចប់ទៅគេត្រឡប់ទៅវិញ អ្នកខ្លះមានលទ្ធភាព គេទិញដីមួយដុំនៅក្នុងភូមិហ្នឹងទៅ គេអត់ទៅវិញទេ។ ចាស សូមជម្រាបប៉ុណ្ណឹង ខ្ញុំមិនដឹងថា មានប៉ុន្មានកន្លែងជំរំភៀសខ្លួនទេ អង្កាល់នៅភ្នំពេញហ្នឹង។

[១៥:៣៨:៣៩]

**ស៖** តើលោកស្រីខ្លួនឯងផ្ទាល់ តើលោកស្រីមានស្គាល់អ្នកណាម្នាក់ដែលគាត់ធ្វើការងារពាក់ព័ន្ធទៅនឹងការជួយសង្គ្រោះដល់ជនភៀសសឹកដែលគេ ដែលអ្នកធ្វើការហ្នឹង ដែលគាត់ដឹងអំពីស្ថានភាពជនភៀសសឹកហ្នឹង។ ខ្ញុំចង់សួរថា ជាឧទាហរណ៍អ្នកដែលធ្វើការជាមួយភ្នាក់ងារសង្គ្រោះ ឬក៏ធ្វើការជាមួយក្រសួងសុខាភិបាល ឬក៏ក្រសួងនានា ដែលធ្វើការងារផ្នែកជួយសង្គ្រោះដល់ជនភៀសសឹកនោះ តើលោកស្រីមានស្គាល់អ្នកណាម្នាក់ដោយផ្ទាល់ដែរឬទេ?

**ឆ៖** ខ្ញុំដូចអត់បានស្គាល់អ្នកណាផង ចាស។ ឮតែថាខាងសាលារៀន ឆ្នាំ៧០ គេមានមកបង្រៀន*សឺគួរីស* ដល់ពួកសាលារៀនឲ្យជួយ ក្រែងលោមានអ្នកបាក់ដៃបាក់ជើងអី ជួយសង្គ្រោះគេបាន ប៉ុន្តែត្រង់ជីវភាព ជាបែងចែកអង្ករ ជាបែងចែកស្អីជួយហ្នឹង អត់ៗមានអ្នកណា ខ្ញុំអត់ស្គាល់អ្នកណាទេ មានតែ -- គេហៅថាលះបង់ដោយឡែកៗពីគ្នា ដោយខ្លួនឯងផ្ទាល់ ឬក៏ដោយគ្រួសារណាគេផ្ទាល់ អត់មានប្រជុំគ្នា ថាយកទៅចែកឯណេះ យកទៅចែកឯណោះទៀតទេ ខ្ញុំអត់ដឹងទេ កន្លែងហ្នឹង។

**ស៖** ខ្ញុំយល់ថា ខ្ញុំយល់អំពីអ្វីដែលលោកស្រីបាននិយាយ។ ដូច្នេះតើខ្ញុំអាច តើអាចនិយាយបានដែរឬទេថា លោកស្រីធ្លាប់មានទំនាក់ទំនងជាមួយនឹងជនភៀសសឹកដែលមកទីក្រុងភ្នំពេញ ប៉ុន្តែលោកស្រីមិនដឹងអំពីទិដ្ឋភាពជារួម ឬក៏ទិដ្ឋភាពទាំងស្រុងនៃស្ថានភាពរស់នៅរបស់ជនភៀសសឹក ដែលមកទីក្រុងភ្នំពេញមុនខែមេសា ឆ្នាំ៧៥ ទេ? តើខ្ញុំអាចនិយាយបែបនេះបានដែរឬទេ?

**ឆ៖** ចាស លោកអាចនិយាយបាន ប៉ុន្តែខ្ញុំចង់ជម្រាបលោកថា ខ្ញុំដឹងតែបងប្អូនដែលរត់មកលើផ្ទះយើង មកកន្លែងយើង ត្រង់ថានៅទីណាផ្សេងពីក្រៅពីគ្រួសារខ្ញុំ ខ្ញុំអត់ដឹងអស់ទេ គ្រាន់តែឃើញថា

មនុស្សជាច្រើនបានរត់ហើយ បានរត់ពីក្រៅមក បានដំណាំ ដូចថាដំណាំដំណោចអីញ៉ាំសុទ្ធឡើងថ្លៃទាំងអស់។ មនុស្សច្រើនចូលមកហ្នឹង។ ខ្ញុំមិនដឹងទៅខាងណាៗទេ ខ្ញុំអត់មានឱកាសដើរទៅស្រាវជ្រាវទេណាលោក។ ខ្ញុំដឹងក្នុងគ្រួសារខ្ញុំហ្នឹងទេ ដែលបងប្អូនមកពីណា បងរត់មកពីណាៗ ជិតខាងអីដល់ថ្ងៃ១៧ហ្នឹងបែកគ្នាអស់វិញទៅ។ មានតែគ្រួសារអ្នកកំពង់ស្ពឺហ្នឹងមួយទេ ព្រោះកូនគាត់មកនៅញ៉ាំបាយរៀនជាមួយខ្ញុំហ្នឹងក៏ទៅជាមួយគ្នាហ្នឹង។

[១៥:៤១:៣៥]

**ស៖** សូមអរគុណលោកស្រី។ ខ្ញុំនឹងបន្តទៅប្រធានបទបន្តទៀត ហើយខ្ញុំសូមអភ័យទោសដែលខ្ញុំសួរលោកស្រីមានរយៈពេលវាងឃ្យូរបន្តិច ព្រោះថារឿងរ៉ាវដែលកើតឡើងគឺវាមានលក្ខណៈគួរឲ្យចាប់អារម្មណ៍។ ដូច្នេះហើយទើបខ្ញុំសួរឲ្យលោកស្រីធ្វើការពន្យល់ឲ្យបានច្បាស់។ ខ្ញុំមានសំណួរមួយទៀតដែលត្រូវសួរបន្ត។ បន្ទាប់ពីលោកស្រីចាកចេញពីទីក្រុងភ្នំពេញនៅថ្ងៃ១៧ មេសា ៧៥ លោកស្រីធ្វើដំណើរអស់រយៈពេលច្រើនថ្ងៃ ហើយចុងក្រោយលោកស្រីមកដល់ភូមិមួយ។ ខ្ញុំឮលោកស្រីបាននិយាយថា គឺព្រឹកនេះលោកស្រីនិយាយថា "ប្រជាជនមូលដ្ឋានអាចផ្តល់អង្ករ និងម្ហូបអាហារដល់លោកស្រី"។ តើខ្ញុំស្តាប់លោកស្រីហ្នឹងច្បាស់ដែរឬទេ? គឺថាតើអ្វីដែលខ្ញុំនិយាយហ្នឹង វាដូចអ្វីដែលលោកស្រីបញ្ជាក់កាលពីព្រឹកដែរឬទេ?

**ឆ៖** ចាស ត្រឹមត្រូវហើយ ខ្ញុំទៅដល់ហ្នឹង គឺផ្ទះដែលខ្ញុំចូលនៅហ្នឹង គេឲ្យយើងៗញ៉ាំ ផ្តល់ឲ្យយើងញ៉ាំ ជួនកាលទីគាស់ដំឡូងអីបានដំឡូងឈើ ដំឡូងអីឲ្យយើងញ៉ាំ។ យើងថាយើងឃ្លានត្នោតអីគាត់កាប់ហ្នឹងក្នុងនាមជាបងប្អូន។ ដំបូងឡើងហ្នឹងមិនទាន់ៗធ្វើសហករណ៍រួមអីទេ គឺមកផ្ទះគាត់ហើយ គាត់ជួនកាលគាត់មកបើកកែវខ្ញុំ គាត់ឃើញមានផ្អកសល់ ឲ្យបងមក ហ្នឹងក្នុងនាមជាបងប្អូន។ គាត់មកសុំយើង យើងសុំគាត់។ ដូច្នេះជាការផ្តល់គ្នាទៅវិញទៅមកក្នុងមនោសញ្ចេតនាសាច់ញាតិហ្នឹងចាស ដំបូងពេលមកដល់ភូមិថ្នល់ដាច់។

[១៥:៤៣:៣៥]

**លោក ហ្សាស្តើ ប៉ោ៖**

ខ្ញុំមិនមានសំណួរអ្វីបន្ថែមទៀតទេ ចំពោះលោកស្រី សុខា។ ខ្ញុំក្នុងនាមឲ្យមេធាវីការពារក្តីលោកនួន ជា សូមជូនពរឲ្យលោកស្រីធ្វើដំណើរទៅវិញប្រកបដោយសុវត្ថិភាព ហើយខ្ញុំសូមប្រគល់វេទិកាបន្តទៅដល់មេធាវីការពារក្តីក្រុមផ្សេងទៀត។ សូមអរគុណ លោកស្រី សុខា។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះដើមបណ្តឹងរូបនេះ។

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម សួស្តីតំណាងអយ្យការ សួស្តីសហភាគា ហើយសួស្តីលោកអ្នកទាំងឡាយដែលចូលរួមសវនាការនៅក្នុងបន្ទប់ និងនៅក្រៅបន្ទប់។

សួស្តីអ្នកស្រី ទឹង សុខា! ខ្ញុំ អាង ឧត្តម ហើយខាងស្តាំខ្ញុំគឺលោក ម៉ៃខល កាណាវាស។ យើងខ្ញុំទាំងពីរនាក់ជាសហមេធាវីការពារក្តីលោក អៀង សារី។ នៅពេលនេះ យើងខ្ញុំមិនមានសំណួរនឹងសួរអ្នកស្រីទេ។ ប៉ុន្តែយ៉ាងណាក្តី តាងនាមលោក អៀង សារី យើងខ្ញុំសូមថ្លែងអំណរគុណលោកស្រីដែលបានឡើងមកផ្តល់សក្ខីជួយតុលាការក្នុងការស្វែងរកការពិត។ សូមលោកស្រីបានសេចក្តីសុខសប្បាយពេលត្រឡប់ទៅវិញ។ ហើយសូមអរគុណលោកប្រធាន។

[១៥:៤៤:៥៩]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន!

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ក្នុងនាមលោក ខៀវ សំផន ក្រុមមេធាវីលោក ខៀវ សំផន អត់មានសំណួរសម្រាប់អ្នកស្រី ទឹង សុខា ទេ។ បាទ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណច្រើន។

អង្គជំនុំជម្រះ ចុងក្រោយនេះគឺសូមផ្តល់វេទិកាជូនទៅលោកស្រី ទឹង សុខា ដើម្បីមានឱកាសក្នុងការថ្លែងរៀបរាប់អំពីទុក្ខសោកវេទនា ឬក៏ព្យសនកម្មដែលលោកស្រីបានជួបប្រទះនៅក្នុងអំឡុងកម្ពុជាប្រជាធិបតេយ្យ។ ដូចអ្វីដែលលោកអង្គជំនុំជម្រះបានជម្រាបជូនលោកស្រីរួចហើយ ប្រសិនបើលោកស្រីមានបំណងធ្វើដូច្នេះ។

[១៥:៤៥:៥៦]

**លោកស្រី ទឹង សុខា៖**

ចាស សូមអរគុណលោកប្រធាន សូមអរគុណសហព្រះរាជអាជ្ញា ព្រមទាំងលោក លោកស្រីមេធាវីទាំងអស់ដែលបានតាមដានសវនាការក្នុងពេលថ្ងៃនេះ។ ដូច្នេះ ខ្ញុំមានសេចក្តីត្រេកអរដែលលោកប្រធានតុលាការមេត្តាឲ្យខ្ញុំធ្វើសេចក្តីថ្លែងការណ៍ខ្លះអំពីព្យសនកម្មដែលខ្ញុំទទួលរងនៅចន្លោះឆ្នាំ១៩៧៥មកដល់ឆ្នាំ១៩៧៩ និងបង្កឡើងដោយរបបខ្មែរក្រហម។

ខ្ញុំសូមជម្រាបដល់លោកប្រធានថា ពាក្យពេចន៍ទាំងអស់ដែលរៀបរាប់នៅក្នុងសេចក្តីថ្លែងការណ៍នេះ គឺសុទ្ធសឹងជាការពិត សុទ្ធសឹងតែជាពាក្យសច្ចៈ ដោយគ្មានការបំផ្លើសណាមួយឡើយ។ ផ្ទុយទៅវិញ គឺខ្ញុំ នាងខ្ញុំទៅវិញទេដែលបានព្យាយាមបំភ្លេចចោលនូវរឿងរ៉ាវជាច្រើន ដោយសារថា ពុំនោះសោតទេ វានឹងវែងពេក វាធ្ងន់ធ្ងរពេក សាហាវពេក និងគួរឲ្យអៀនខ្មាសខ្លាំងណាស់ផង។

[១៥:៤៧:១១]

វាគឺជាមហាវិនាសកម្មមួយដែលគួរឲ្យសោកស្តាយ ហើយវាពិតជាពិបាកក្នុងការស្វែងរកពាក្យណាមកដាក់ឲ្យសមល្មម ដើម្បីរៀបរាប់អំពីព្រឹត្តិការណ៍ទាំងអស់នោះ ដែលយើងបានឆ្លងកាត់។ វាគឺជារឿងមួយដែលហួសពីការស្រមៃ និងពុំអាចទទួលយកបាន។ យើងបានខិតខំរស់នៅក្រោយឆ្នាំ១៩៧៩មកទៀត យើងបានជួបជុំបងប្អូនសាច់ញាតិរបស់យើងខ្លះ ប៉ុន្តែយើងក៏បានទទួលដំណឹងជាពិសេសអំពីការបាត់បង់បងប្អូនរបស់យើង ដែលត្រូវបានគេសម្លាប់ វាយធ្វើបាប បង្អត់អាហារ និងធ្វើទារុណកម្មនៅទីកន្លែងផ្សេងៗដែលពួកគេជម្លៀសយកទៅទាំងដំណាក់កាលទី១ និងទាំងដំណាក់កាលទី២ទៅវិញ។

នៅពេលដែលមានការជម្លៀសចេញពីភ្នំពេញនៅថ្ងៃ១៧មេសា ៧៥ ពេលនោះវាប្រៀបបានទៅនឹងគ្រាប់បែកខ្យល់ផ្គោងមកបំបែកក្រុមគ្រួសាររបស់អ្នកភ្នំពេញអីចឹង។ ពួកយើងវង្វេងគ្នា ពួកយើងត្រូវបែកបាក់គ្នាក្នុងរយៈពេលមួយប៉ប្រិចភ្នែក។ ពួកយើងបែកពីបងប្អូន ពីមិត្តភក្តិ ហើយយើងខ្ញុំបានបាត់បង់នូវទ្រព្យសម្បត្តិទាំងអស់មួយរំពេច។ យើងបាត់ដឹងដំណឹងរបស់ពួកគេរហូតដល់សព្វថ្ងៃនេះ។

[១៥:៤៨:៣៧]

ដំណាក់កាលទី២នៃការជម្លៀស គឺប្រហែលជាខែកញ្ញា ឆ្នាំ១៩៧៥ ខ្លួនទទេ ឃ្លាតឆ្ងាយពីស្រុកភូមិកំណើត ពីញាតិសន្តាន និងពីមិត្តភក្តិជិតស្និទ្ធ គេបានឲ្យពួកយើងទៅនៅក្នុងព្រៃលិចទឹក មិនស្គាល់ទីតាំង ហើយគ្មានអ្វីហូបទេ គ្មានផ្ទះ គ្មានជម្រក អត់ស្គាល់អត់ភូមិចាស់ណាម្នាក់សោះ។

កាលពីដំបូង ពួកយើងរស់នៅតាមដងផ្លូវរថភ្លើងនៅគោកត្រុំ។ ពួកយើងគ្មានសម្ភារៈដើម្បីកាប់

គាស់ព្រៃទេ។ ពេលនោះចំពេលរដូវភ្លៀង ហើយភ្លៀងធ្លាក់យ៉ាងពេញបន្ទុក។ យើងគ្មានសិទ្ធិសេរីដើរហើរទេ។ ពួកយើងរស់នៅក្នុងចំណោមអ្នកជម្លៀសដូចៗគ្នា ហើយពួកយើងជាអ្នកអត់ដូចគ្នាទៀត។ ដូច្នេះពួកយើងទាំងអស់គ្នាស្លាប់ដោយគ្មានបាយហូប។ ស្លាប់ដោយជំងឺគ្មាថ្នាំសង្កូវអ្វីសោះតែម្តង។ ដំណាក់កាលនេះ ខ្ញុំកាន់តែមើលឃើញច្បាស់ហើយ គិតថា វាជាវិធីសម្លាប់រង្គាល ជាពិសេសគឺសម្លាប់ជនជម្លៀសពីភ្នំពេញដោយយកទៅចាក់ចោលឲ្យលំបាកវេទនា និងទុកស្លាប់ក្នុងព្រៃនេះតែម្តង។

[១៥:៤៩:៥៦]

ពួកគេឲ្យយើងស្លាប់ដោយគ្មានចេញឈាម ពួកយើងមានសភាពស្លេកស្លាំង និងស្វិតក្រញង់តែម្តង។ យើងរស់នៅដូចជាសត្វព្រៃ ស៊ីសត្វម្រើមព្រះ ស៊ី -- មានពេលខ្លះស៊ីជីងចក់ ឬដើមប្រោះស្វា ស៊ីគល់ត្រកួន ឫសកំប្លោក។ល។ ពួកគេ -- យើងរស់នៅ -- និយាយឲ្យខ្លីឲ្យតែជួបអ្វីក៏ហូបឲ្យបានតែពេញពោះ ស្លឹកថ្នឹងដែលមានរសជាតិជូរ ប្រែរជាមានរសជាតិផ្អែម។ យើងឃ្លានស្ទើរស្លាប់ ភ្នែកប្រែល្អក់មានសភាពដូចសាកសព សំឡេងខ្សោយព្រឺខ្សាវៗ។ នេះគឺមហាគុកឥតជញ្ជាំងមួយ លើសពីសត្វព្រៃនៅភ្នំតាម៉ៅ ដែលគេចិញ្ចឹមគេឲ្យសាច់ គេឲ្យអាហារជានិច្ច។ វាពិតជាសាហាវឃោរឃៅខ្លាំងណាស់។ នៅក្នុងឆ្នាំ១៩៧៦ ខ្ញុំបានបាត់បង់កូនស្រី បាត់បង់ឪពុកក្មេក ប្អូនថ្លៃពីរនាក់ ប្តីខ្ញុំធ្វើអត្តឃាត កូនស្រីរបស់ខ្ញុំម្នាក់ទៀតបាត់បង់សំឡេង គឺគ។

[១៥:៥១:២២]

ដូច្នេះដំណាក់កាលទី២ នេះគឺ -- នៃការជម្លៀសនេះគឺពិតជាមានការលំបាកខ្លាំងណាស់។ ខ្លាំងលើសពីកាលលើកទី១ទៅទៀត។ ការជម្លៀសទាំងពីរលើកនេះ គឺពិតជាមានមហាទុក្ខហួសប្រមាណ ពួកយើងមានសភាពទ្រុឌទ្រោម រាងកាយ កម្លាំងខ្សោយ ទាំងស្មារតី ទាំងកម្លាំង វាជាមហាទុក្ខសោកដែលបានដក់ទុកក្នុងខួរក្បាលរបស់ខ្ញុំ។ នៅពេលដែលខ្ញុំបាត់បង់កូនស្រី គឺជាពេលខ្លោចផ្សាបំផុតសម្រាប់ខ្ញុំស្ទើរឲ្យខ្ញុំស្ទើរឆ្កួតវង្វេងស្មារតី។ កូនខ្ញុំបានស្រែកហៅខ្ញុំ ពីរម៉ាត់ប៉ុណ្ណោះមុននឹងផុត។ មុននឹងៗស្លាប់។ ពេលដែលខ្ញុំឃើញគេមករើសយកសាកសពកូនស្រីរបស់ខ្ញុំ មិនដឹងជាគេ -- ខ្ញុំមិនដឹងជានិយាយអ្វីកើតឡើយ ខ្ញុំមិនដឹងជារៀបរាប់ប្រាប់ទៅកាន់អ្នកណាឡើយ ពីព្រោះជាការឈឺចាប់របស់ -- ចំពោះការឈឺចាប់របស់ខ្ញុំនេះ។ គេដាក់កូនស្រីខ្ញុំក្នុងអង្រឹងតែមួយដែលមានខ្មោចប្រាំបីនាក់។ ពេលដែលស្វាមីរបស់ខ្ញុំបានធ្វើអត្តឃាត ខ្ញុំសែនរន្ធត់ខ្លាំងណាស់ ព្រោះឃើញសាកសពគាត់ព្យួរនៅឯដំបូលផ្ទះ យូរបន្ទ្រេតក្នុងខ្យល់។ ខ្ញុំយំៗ ដោយគ្មានទឹកភ្នែកហូរ។ ខ្ញុំចង់យំឲ្យស្រាកស្រាន្តនូវការឈឺចាប់របស់ខ្ញុំខ្លាំង

ណាស់ ប៉ុន្តែខ្លាចគេដឹង។ យើងក៏អាចស្លាប់ទៀតដោយគេអាចចោទយើងពីរឿងអ្វីមួយ។ ខ្ញុំរន្ធត់លើសពេលណាៗទៅទៀត ខ្ញុំស្ទើរតែឆ្កួតទៅហើយ។ ការឈឺចាប់ទាំងអស់នេះបានដក់ជាប់នៅជាមួយខ្ញុំរហូតដល់ថ្នាក់ខ្ញុំខ្លួនឯងផ្ទាល់ក៏ចង់សម្លាប់ខ្លួនឯងដែរ ខ្ញុំខឹងនឹងខ្លួនឯងដែលអសមត្ថភាព មិនអាចជួយបងប្អូនបាន។

[១៥:៥៣:១៩]

ពុំមានការសង្ឃឹម -- ខ្ញុំមានការអស់សង្ឃឹមជាខ្លាំង។ កាលពីមុន ខ្ញុំបាននិយាយប្រាប់ខ្លួនឯងថា "ខ្ញុំត្រូវតែធ្វើយ៉ាងណា ដើម្បីមើលថែរក្សាកូនរបស់ខ្ញុំឲ្យបានល្អ" ក៏ប៉ុន្តែនៅទីបំផុតកូនរបស់ខ្ញុំស្លាប់នៅនឹងដៃ នៅនឹងភ្នែករបស់ខ្ញុំ។ ខ្ញុំថែមទាំងបានសុំឲ្យប្តីរបស់ខ្ញុំសម្លាប់ខ្ញុំទៀតផង ខ្ញុំមិនចង់រស់នៅក្នុងស្ថានភាពលំបាកឃោរឃៅបែបនេះតទៅទៀតទេ។ ប្តីខ្ញុំបានឱបខ្ញុំហើយប្រាប់ខ្ញុំថា "ខ្លួនសុទ្ធតែឆ្អឹង" បានន័យថាបន្តិចទៀតគង់តែស្លាប់ដែរ បែបចង់មានប្រសាសន៍អ៊ីចឹង។

សូមលោកប្រធានមេត្តាជ្រាប នេះគ្រាន់តែជារឿងសង្ខេបតែប៉ុណ្ណោះ។ ដោយសារថាខ្ញុំមិនអាចរៀបរាប់សាច់រឿងទាំងអស់នេះនៅពេលនេះបានទេ។ រួមសេចក្តីមក ស្មារតីរបស់ខ្ញុំមានការប៉ះទង្គិចខ្លាំងបំផុត។ ខ្ញុំពិតជាមិនចង់រស់នៅក្នុងស្ថានភាពឈឺចាប់ជាថ្មីម្តងទៀតទេ។ ប៉ុន្តែស្លាកស្នាមទាំងអស់នោះមិនអាចរលត់បាត់ពីការចងចាំរបស់ខ្ញុំសោះឡើយ។ ការចងចាំរបស់មនុស្សមិនមែនដូចជាការលុបសំឡេងពីខ្សែអាត់ដែលយើងអាចលុបបានដោយងាយៗនោះទេ។ ខ្ញុំនៅតែដេកស្រក់ទឹកភ្នែក ពេលណាខ្ញុំនឹកដល់កូន នឹកដល់ឪពុកម្តាយដែលបែកទៅ ខ្ញុំនៅតែញ័រចំប្រប់។ ពេលខ្លះខ្ញុំយំទោះជានៅទីកន្លែងណាក៏ដោយ។ ខ្ញុំបានងាកទៅរកធម៌ព្រះពុទ្ធដើម្បីជួយសម្រាលទុក្ខសោករបស់នាងខ្ញុំមួយខណៈៗបានតែប៉ុណ្ណោះ។ ប៉ុន្តែនិយាយអំពីការបាត់បង់ជាសម្ភារៈវិញ ខ្ញុំបានបាត់បង់ទ្រព្យសម្បត្តិទាំងអស់របស់ខ្ញុំ ប្លុករួមទាំងផ្ទះរបស់ខ្ញុំមួយផង ទាំងអស់មានតម្លៃ ៩២៥,១ តម្លឹងមាស។ ខ្ញុំបាត់បង់កូនស្រីរបស់ខ្ញុំ ឪពុកម្តាយ បងប្អូន សរុបចំនួនប្រាំបីនាក់។ បងប្អូនជីដូនមួយសរុបចំនួន ២៥នាក់ ផុតពូជ។ ជីទួតមួយសរុបចំនួន ប្រាំបីនាក់ មិត្តភក្តិជិតស្និទ្ធ សរុបចំនួនប្រាំបីនាក់។

[១៥:៥៥:៤៣]

ក្រោយពេលចប់របបខ្មែរក្រហម ខ្ញុំស្ទើរតែអស់សមត្ថភាព ក្នុងការបំពេញកិច្ចការ ធ្វើការងារតែដដែលៗ ដោយមិនអាចអភិវឌ្ឍន៍ខ្លួនបាន។

ខ្ញុំនៅតែយល់សប្តិ៍អាក្រក់ មមើមមាយ ដើមទ្រូងញ័រ ថប់ដង្ហើម អស់សេចក្តីក្លាហាន។ ចង់គេង

លុះត្រាតែមានថ្នាំទើបខ្ញុំអាចគេងលក់។ ខ្ញុំចង់ឲ្យដំណើរការក្តីនេះអាចឲ្យមនុស្សជំនាន់ក្រោយចងចាំ និងយល់ឲ្យច្បាស់អំពីសម័យនោះ។

នៅទីបញ្ចប់នេះ នាងខ្ញុំសូមលោកប្រធាននៃអង្គជំនុំជម្រះដ៏ស័ក្តិសិទ្ធិ ជួយផ្តល់នូវយុត្តិធម៌ឲ្យដល់នាងខ្ញុំ ដល់ក្រុមគ្រួសារនាងខ្ញុំ និងដល់ជនរងគ្រោះទាំងឡាយ ទាំងអ្នកនៅរស់រានមានជីវិត និងទាំងអ្នកដែលបាត់បង់ជីវិតទៅ ឲ្យគេមាន -- ឲ្យគេបានអស់ចិត្ត ឲ្យបានពេញចិត្ត និងឲ្យបានសុខស្ងប់តរៀងទៅ។ សូមអរគុណ។ សូមជម្រាបលា។

[១៥:៥៦:៥៧]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះសូមអរគុណចំពោះលោកស្រីទឹង សុខា។ ការស្តាប់សក្ខីកម្មរបស់លោកស្រីរហូតដល់ពេលនេះបានចប់ហើយ។ ហើយវត្តមានរបស់លោកស្រីនៅអង្គជំនុំជម្រះនៃ អ.វ.ត.ក នេះលែងមានភាពចាំបាច់ទៀតហើយ។ សក្ខីកម្មរបស់លោកស្រី នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្តីនេះ។

លោកស្រី ទឹង សុខា អាចវិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់លោកស្រី ឬក៏គោលដៅណាដែលលោកស្រីមានបំណងចង់ទៅបានហើយ។ សូមលោកស្រីជួបតែសំណាងល្អ មានសេចក្តីសុខ សេចក្តីចម្រើន ហើយធ្វើដំណើរវិលត្រឡប់ទៅវិញប្រកបដោយសុវត្ថិភាព។

ហើយអង្គជំនុំជម្រះក៏សូមជម្រាបដែរថា នៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្តាប់សក្ខីកម្មសាក្សី អ៊ំ! ដើមបណ្តឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCW-108។ សូមភាគី និងសាធារណជនជ្រាប។

មន្ត្រីរដ្ឋបាលតុលាការ សម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការជូនដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញចុះ។ ហើយដូចគ្នានេះដែរ ដើមបណ្តឹងរដ្ឋប្បវេណីបម្រុងដែលមានរហស្សនាម TCCW-108 ឲ្យជូនគាត់វិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏កន្លែងដែលគាត់ស្នាក់នៅវិញ ហើយនិងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់បន្ទប់រង់ចាំសម្រាប់សាក្សី អ្នកជំនាញ នៅព្រឹកថ្ងៃស្អែកនេះឲ្យបានមុនម៉ោងប្រាំបួន។

លោកស្រី ទឹង សុខា អាចចាកចេញពីបន្ទប់សវនាការវិលត្រឡប់ទៅវិញបានហើយ!

*(ដើមបណ្តឹងរដ្ឋប្បវេណីចាកចេញបន្ទប់សវនាការ)*

[១៥:៥៨:៤៦]

**ប្រធានអង្គជំនុំ៖**

ជាចុងក្រោយនេះ សម្រាប់ថ្ងៃនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅភាគីណាដែលមានបំណងធ្វើការកត់សម្គាល់លើសក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណី ទឹង សុខា ដែលបានផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះ។ ប្រសិនបើមានបំណងគឺសូមអញ្ជើញ។

បាទ ទំនងជាមិនមានទេ។ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមត្រូវសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ សវនាការត្រូវលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំពីរពាន់ដប់--

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ យើង មុននឹងយើងបញ្ចប់សវនាការនេះ ខ្ញុំមានសំណួរមួយ ដើម្បីសុំការបំភ្លឺអំពីសហមេធាវីនាំមុខតំណាងឲ្យដើមបណ្តឹងរដ្ឋប្បវេណី។ នៅក្នុងរបៀបវារៈដែលបានគ្រោងទុកសម្រាប់សប្តាហ៍នេះ អង្គជំនុំជម្រះគ្រោងនឹងស្តាប់ដើមបណ្តឹងរដ្ឋប្បវេណីរូប ដែលមាន TCCP-213 ដែលត្រូវបានចាត់ទុកថា TCW-527។ ដើម្បីរៀបចំឯកសារសម្រាប់សក្ខីកម្មរបស់ដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ ខ្ញុំសួរសំណួរមួយពាក់ព័ន្ធទៅនឹងភាពពាក់ព័ន្ធនៃសក្ខីកម្មនៃដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។

ចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលស្នើឡើងដោយសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីនោះ ខ្ញុំចង់ដឹងថា តើនៅដំណាក់កាលនៃនីតិវិធីនេះ ខ្លួននៅតែចាត់ទុកថា មានភាពពាក់ព័ន្ធក្នុងការស្តាប់បុគ្គលរូបនេះដែរឬទេ? ពីព្រោះថា យើងមានដីកាបំបែកនីតិវិធីហើយ ហើយយើងក៏សវនាការតែលើសំណុំរឿង០០២/០១។ ដូច្នេះ សូមឲ្យសហមេធាវីនាំមុខបំភ្លឺអំពីចំណុចនេះ។

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកចៅក្រម ខ្ញុំគិតថា ខ្ញុំប្រហែលមិនអាចបំភ្លឺអ្វីបានច្រើនទេ ពាក់ព័ន្ធទៅនឹងចំណុចនេះ នៅថ្ងៃនេះ នោះ។ ពីព្រោះថា ខ្ញុំមិនមែនជាមេធាវីដែលនឹងសួរដើមបណ្តឹងរដ្ឋប្បវេណីរូបនេះនោះទេ។ ប៉ុន្តែនៅពេលដែលលើកបញ្ហា ខ្ញុំព្យាយាមបំភ្លឺ ហើយនៅពេលស្អែកព្រឹកនោះ យើងនឹងផ្តល់ព័ត៌មានពាក់ព័ន្ធទៅនឹងដើមបណ្តឹងរដ្ឋប្បវេណីរូបនេះ។ ដូច្នេះ យើងធ្វើតាមលទ្ធភាពដែលអាចធ្វើបាន នៅស្អែកព្រឹកនេះ លោកចៅក្រម។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមបញ្ជាក់ថា យើងមិនចំណាយពេលមួយថ្ងៃសម្រាប់តែសាក្សីរូបនោះទេ។ យើងធ្វើម៉េចដើម្បីឱ្យទទួលបានព័ត៌មានឱ្យបានច្បាស់លាស់ ដើម្បីកុំឱ្យមានការចំណាយពេល ខាតពេលវេលាច្រើន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកចៅក្រម។

បាទ ដំណើរការសវនាការសម្រាប់ថ្ងៃនេះ ដល់ពេលសមល្មមសម្រាកហើយ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។

[១៦:០២:២៦]

សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃពុធ ទី០៥ ខែធ្នូ ឆ្នាំ២០១២ ចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹកទៅ ហើយនៅព្រឹកថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មដើមបណ្ដឹងរដ្ឋប្បវេណីដែលមានរហស្សនាម TCCP-108 ដូចបានជម្រាបអម្បាញ់មិញនេះ។ ហើយបង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូប ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងឱ្យនាំខ្លួនគាត់ត្រឡប់មកកាន់បន្ទប់សវនាការនេះវិញ នៅព្រឹកថ្ងៃស្អែកឱ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ទុកឱ្យគាត់នៅក្នុងបន្ទប់ឃុំខ្លួន នៅក្រោមសាលសវនាការនេះ ដែលមានរៀបចំឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួម និងតាមដានសវនាការពីចម្ងាយ។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*